**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឈ.ង៉ាន់ តុលា**

**ក.ថន វិច្ឆិកាណារី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉ែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **វ៉ាន់ តុលា** និង **ថន វិច្ឆិកាណារី** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ក្រុម P4A1 ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមថ្លែងអំណរគុណ និងសម្តែងនូវការគោរពដឹងគុណចំពោះ

**លោកឪពុក អ្នកម្តាយ** ទាំងពីរដែលលោកទាំងពីរជាអ្នកមានគុណ បានចិញ្ចឹមបីបាច់ ថែរក្សា ផ្តល់ជាជម្រក សម្លៀកបំពាក់ ចំណីអាហារ និងបានបញ្ជូនកូនទៅសាលាដើម្បីទទួលបានចំណេះដឹង។ មិនតែប៉ុណ្ណោះលោកក៏បានទូន្មានប្រៀនប្រដៅកូនដើម្បីឱ្យកូនបានក្លាយជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អក្នុងសង្គម។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការសិក្សារបស់និស្សិត និងខិតខំបង្រៀន បង្ហាត់បង្ហាញដើម្បីឱ្យនិស្សិតគ្រប់រូបទទួលបានចំណេះដឹង និងក្លាយជាធនធានមនុស្សក្នុងសង្គម។

លោកសាស្ត្រាចារ្យ**បណ្ឌិត ឈុន ណារ៉េត** ដែលជាសាស្ត្រាចារ្យណែនាំ ដោយបានចំណាយពេលវេលា ក៏ដូចជាកម្លាំងកាយចិត្តក្នុងការណែនាំ បង្ហាញផ្លូវ ផ្តល់មតិយោបល់ និងត្រួតពិនិត្យសារណាស្រាវជ្រាវនេះយ៉ាងយកចិត្តទុកដាក់។

រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ ដែលបានផ្តល់នូវកិច្ចសម្ភាសន៍ និងបានផ្តល់នូវឯកសារដែលមានសារៈសំខាន់ជាច្រើននៅក្នុងការសិក្សា ស្រាវជ្រាវប្រធានបទមួយនេះ។

ក្រុមហ៊ុន ស៊ីនទ្រី និងក្រុមហ៊ុន 800Super-GAEA ដែលបានផ្តល់នូវកិច្ចសម្ភាសន៍ និងបានផ្តល់នូវឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទរបស់ក្រុមយើងខ្ញុំ។

ជាចុងក្រោយ យើងខ្ញុំសូមគោរពជូនពរដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូប បណ្ឌិត ឈុន ណារ៉េត សូមឱ្យជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាដែលមានប្រជាជនរស់នៅយ៉ាងច្រើនកុះករ។ ការកើនឡើងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយមកនេះ ដែលនាំឱ្យប្រជាពលរដ្ឋមានជីវភាពកាន់តែប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស រួមទាំងការលូតលាស់នៃវិស័យឧស្សាហកម្ម ក៏ដូចជាការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញបានធ្វើឱ្យមានការកើនឡើងនូវបរិមាណសំរាម និងសំណល់រឹងជាច្រើន។ សំណល់ដែលកើតចេញពីរោងចក្រឧស្សាហកម្ម អាជីវកម្ម និងផ្ទះរបស់ប្រជាពលរដ្ឋនីមួយៗ មានការកើនឡើងយ៉ាងឆាប់រហ័ស ដែលនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

ផលប៉ះពាល់ នៃការកើនឡើងនៃសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ គឺបណ្ដាលមកពីកំណើននៃប្រជាពលរដ្ឋរស់នៅច្រើនក្នុងរាជធានី ព្រមទាំងកង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋនូវក្នុងការវេចខ្ចប់ ការញែក និងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។ ទន្ទឹមនឹងនោះដែរ កង្វះខាតក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹងក៏ជាហេតុចម្បងមួយផងដែរ។

ដើម្បីដោះស្រាយបញ្ហានេះ គឺចាំបាច់ត្រូវតែមានវិធានការចំពោះការគ្រប់គ្រងសំរាម និងសំណល់រឹងឱ្យបានល្អ។ ដោយសារតែមើលឃើញពីភាពចាំបាច់នៃការគ្រប់គ្រងសំរាម និងសំណល់រឹងនេះហើយ ទើបក្រុមរបស់យើងខ្ញុំបានជ្រើសយកប្រធានបទ "ការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ"នេះមកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីជាការយល់ដឹងបន្ថែម និងបានជាឯកសារសម្រាប់ជាការស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយ ក៏ដូចជាបានជាចំណេះដឹងដល់មនុស្សទូទៅ។

បើទោះបីជាយើងខ្ញុំបានពិនិត្យខ្លឹមសារ និងពាក្យពេចន៍ទាំងមូលនៃសារណានេះហើយក៏ដោយ តែយើងខ្ញុំជឿជាក់ថាឯកសារមួយនេះនៅតែមានការខ្វះខាត មិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ អាស្រ័យហេតុនេះ សូមសាស្ត្រាចារ្យ មិត្តនិស្សិត និងអ្នកអានទាំងអស់ សូមការអភ័យទោសរាល់កំហុសឆ្គងដែលកើតមានឡើងដោយចេតនាក្តី អចេតនាក្តី ហើយខ្ញុំសូមទទួលនូវរាល់មតិរិះគន់ក្នុងការស្ថាបនាជានិច្ច។

យើងខ្ញុំសង្ឃឹមថា ឯកសារនៃការស្រាវជ្រាវនេះនឹងបានជាចំណេះដឹងបន្ថែមដល់អ្នកស្រាវជ្រាវ និងអ្នកអានគ្រប់រូប៕

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

១. លំនាំបញ្ហា ........................................ ១

២. ចំណោទបញ្ហា ........................................ ៣

៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ ៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........................................ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៤

**ជំពូកទី១**

**រំលឹកទ្រឹស្តី**

**១.១. លិខិតគតិយុត្ត របាយការណ៍ និងទ្រឹស្តីពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ** ........................................ ៥

១.១.១. លិខិតគតិយុត្ត ........................................ ៥

១.១.២.របាយការណ៍ ........................................ ៧

១.១.៣. សំយោគការសិក្សាពីមុនៗ ........................................ ៨

**១.២. សញ្ញាណទូទៅនៃការគ្រប់គ្រង** ........................................ ៩

១.២.១. និយមន័យ ........................................ ..៩

១.២.២. មុខងារនៃការគ្រប់គ្រង ........................................ ៩

១.២.៣. កម្រិតនៃការគ្រប់គ្រង ........................................ ១០

**១.៣. និយមន័យ និងប្រភពនៃសំរាម និងសំណល់រឹង** ........................................ ១១

១.៣.១. និយមន័យសំរាម និងសំណល់រឹង ........................................ ១១

១.៣.២. ប្រភពនៃសម្រាម សំណល់រឹង ........................................ ១៣

## ជំពូកទី២

## ការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ

**២.១. និដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ** ........ ១៤

**២.២.រដ្ឋបាលរាជធានីភ្នំពេញ** ........ ១៤

២.២.១. ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់ ........ ១៤

២.២.២.ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ........ ១៥

២.២.៣.ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់ ........ ១៥

**២.៣. រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ** ........ ១៥

២.៣.១. រចនាសម្ព័ន្ធ ........ ១៦

២.៣.២.តួនាទី និងភារកិច្ច ........ ១៧

**២.៤. ស្ថាប័នឯកជន** ........ ១៨

២.៤.១. ក្រុមហ៊ុន ស៊ីនទ្រី ........ ១៨

២.៤.១.១. ប្រវត្តិ ........ ១៨

២.៤.១.២. រចនាសម្ព័ន្ធ ........ ១៨

២.៤.១.៣. តួនាទី និងភារកិច្ច ........ ១៩

២.៤.១.៤. កម្មវិធីប្រមូលសំរាម ........ ១៩

២.៤.១.៥. គ្រឿងចក្រ ឧបករណ៍ និងកម្លាំងប្រតិបត្តិករ ........ ១៩

២.៤.១.៦. ចក្ខុវិស័យ ........ ២០

២.៤.២. ក្រុមហ៊ុន 800 Super-GAEA ........ ២០

២.៤.២.១. ប្រវត្តិ ........ ២០

២.៤.២.២. រចនាសម្ព័ន្ធ ........ ២០

២.៤.២.៣. តួនាទី និងភារកិច្ច ........ ២១

២.៤.២.៤. កម្មវិធីបញ្ចេញសំរាម សំណល់រឹង ........ ២១

២.៤.២.៥. គ្រឿងចក្រ ឧបករណ៍ និងកម្លាំងប្រតិបត្តិករ ........ ២១

២.៤.២.៦. ចក្ខុវិស័យ ........ ២២

**២.៥.ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញចោលសំរាម សំណល់រឹង** ..... ២២

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. សមិទ្ធផលរបស់អង្គភាព** ........ ២៤
៣.១.១. សមិទ្ធផលរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ ........ ២៤
៣.១.២.សមិទ្ធផលរបស់ក្រុមហ៊ុន ស៊ីនទ្រី ........ ២៤
៣.១.៣.សមិទ្ធផលរបស់ក្រុមហ៊ុន 800Super/GAEA ........ ២៦
**៣.២. បញ្ហាប្រឈមរបស់អង្គភាព** ........ ២៧
៣.២.១. បញ្ហាប្រឈមរបស់រដ្ឋាករស្វយ័ត គ្រប់គ្រងសំរាម និងសំណល់រឹង ........ ២៧
៣.២.២. បញ្ហាប្រឈមរបស់ក្រុមហ៊ុន ស៊ីនទ្រី ........ ២៧
៣.២.៣. បញ្ហាប្រឈមរបស់ក្រុមហ៊ុន 800 Super/GAEA ........ ២៨
**៣.៣. បញ្ហាប្រឈមនៃលទ្ធផលសិក្សា** ........ ២៨
៣.៣.១. បញ្ហាប្រឈមនៃការសិក្សាទ្រឹស្តី ........ ២៨
៣.៣.២. លទ្ធផលនៃការសម្ភាសន៍អ្នកជំនាញ ........ ៣០
៣.៣.៣. លទ្ធផលនៃការសម្ភាសន៍ក្រុមគោលដៅ ........ ៣២
៣.៣.៤. លទ្ធផលនៃករណីសិក្សា ........ ៣៣
៣.៣.៥. សំយោគ ........ ៣៥
**៣.៤. ដំណោះស្រាយ** ........ ៣៦
**សេចក្តីសន្និដ្ឋាន** ........ ៣៧
**អនុសាសន៍** ........ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅទន្លេធំ៣ ជាប់ដៃទន្លេ៤ នៃទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ នៅផ្នែកខាងស្តាំខាងមុខព្រះបរមរាជវាំង។ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នយោបាយ និងវប្បធម៌។ ហើយរាជធានីភ្នំពេញ គឺជាច្រកចូលមួយដ៏សំខាន់នៃបណ្តាប្រទេសផ្សេងៗនៅលើពិភពលោក ជាតំបន់បេតិកភណ្ឌដ៏សម្បូរបែប។ រាជធានីភ្នំពេញប្រមូលផ្តុំទៅដោយសំណង់អគារធំៗជាច្រើន រួមមានផ្សារទំនើបដែលធំជាងគេនៅក្នុងប្រទេសកម្ពុជា អាគារពាណិជ្ជកម្ម សាកលវិទ្យាល័យ រោងចក្រធំៗ ព្រលានយន្តហោះ កំពង់ផែ និងសំណង់អាគារជាច្រើនទៀត។ រាជធានីភ្នំពេញ ជារាជធានីដែលមានកំណើនប្រជាជនផ្លាស់ប្តូរ ដូចបណ្តាទីក្រុងទេសចរណ៍អាស៊ានដទៃទៀតផងដែរ។ បរិមាណភោជនីយដ្ឋាន និងសណ្ឋាគារបានរីករាលដាលគួរឲ្យកត់សម្គាល់ នៅប៉ុន្មានឆ្នាំកន្លងទៅនេះ មិនត្រឹមតែប៉ុណ្ណោះកំណើនភ្ញៀវទេសចរបានកើនឡើងយ៉ាងគំហុក ពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយសារតែមានអ្វីៗសម្បូរបែប និងជាបណ្តុំនៃកន្លែងការងារដូចនេះហើយ ទើបមានប្រជាជនជាច្រើនកំពុងរស់នៅក្នុងរាជធានីភ្នំពេញ ទាំងប្រជាជនដែលមានដើមកំណើតនៅទីនោះផ្ទាល់ និងប្រជាជនដែលដែលបានផ្លាស់ប្តូរពីខេត្តទៅរស់នៅទីនោះ។ ស្របទៅនឹងស្ថានភាពដែលកំពុងមានការរីកចម្រើន ប្រជាជនមានជីវភាពប្រសើរជាងមុន។ ដូច្នេះរាល់ការចំណាយក្នុងការទិញរបស់របរប្រើប្រាស់ ហូបចុកក្នុងជីវភាពប្រចាំថ្ងៃក៏មានការកើនឡើង។ របស់របរប្រើប្រាស់ កាកសំណល់អាហារទាំងនេះបង្កើតបានជាសំរាមជាច្រើននៅក្នុងរាជធានីភ្នំពេញ។ បញ្ហាកង្វះការយល់ដឹង ក៏ដូចជា ចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងការញែក ការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងការបោះចោលសំរាមផ្តេសផ្តាសនៅតាមទីសាធារណៈបានធ្វើឲ្យសំរាមកើនឡើង និងមានផលប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ បរិស្ថាន និងសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះផងដែរ កាកសំណល់ដែលចេញពីរោងចក្រ ឧស្សាហកម្ម ផ្សារ ផ្សារទំនើប ភោជនីយដ្ឋាន សណ្ឋាគារ ក៏ជាផ្នែកមួយដែលនាំឲ្យសំរាមមានការកើនឡើងនៅក្នុងរាជធានីភ្នំពេញ។ ដើម្បីដោះស្រាយបញ្ហានេះបាន គឺត្រូវតែមានការគ្រប់គ្រងសំរាមឲ្យបានល្អ និងត្រឹមត្រូវ។

សេវាប្រមូល និងដឹកជញ្ជូនសំរាមគិតចាប់តាំងពីឆ្នាំ២០០២ រហូតមកដល់ឆ្នាំ២០២០ គឺមានតែក្រុមហ៊ុនស៊ីនទ្រីប៉ុណ្ណោះ ដែលជាអ្នកធ្វើប្រតិបត្តិការ។ ដែលនៅចន្លោះរយៈពេលនោះក្រុមហ៊ុនស៊ីនទ្រី បានផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងរាជធានីភ្នំពេញ ដែលមិនមានជាបញ្ហាប្រឈមអ្វីធ្ងន់ធ្ងរនោះទេ ព្រោះថាកាលនោះ ចំនួនប្រជាជនមិនសូវមានច្រើន ហើយការបង្កើតសំរាមក៏នៅមានកម្រិតតិច។ តែបច្ចុប្បន្ន ក្រុមហ៊ុនស៊ីនទ្រីតែម្នាក់ឯងមិនអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិការប្រមូល និងដឹកជញ្ជូនសំរាមនៅក្នុងរាជធានីភ្នំពេញទាំងមូលអស់ទេ ព្រោះថាក្រឡាផ្ទៃរាជធានីភ្នំពេញកាន់តែរីកធំជាងមុន ចំនួនប្រជាជនកាន់តែច្រើនជាង

មុន ហើយការបង្កើតបរិមាណសំរាម ក៏មានការកើនឡើងដូចគ្នា។ ដោយមើលឃើញពីបញ្ហានេះហើយទើប បច្ចុប្បន្ន រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ដែលបន្ទាប់ពីមានការកំណែទម្រង់រួចមកមានក្រុមហ៊ុនចំនួនបីដែលទទួលបានសិទ្ធិក្នុងការផ្តល់សេវា សម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ហើយមានការបែងចែកជាបីតំបន់ក្នុងការធ្វើប្រតិបត្តិការ។ បន្ទាប់ពីមានការកំណែទម្រង់នេះ គឺទទួលបានការសាទរជាខ្លាំងពីប្រជាពលរដ្ឋក្នុងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ។

កន្លងមានលិខិតបទដ្ឋានគតិយុត្តជាច្រើន ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រង សំរាមសំណល់រឹងនេះ ដែលមានដូចជា អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត-ក្រុង។ ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តទាំងអស់នេះ គឺក្នុងន័យធ្វើយ៉ាងណាឱ្យការគ្រប់គ្រង សំរាមសំណល់រឹងមានភាពប្រសើរជាងមុន ជាពិសេសគឺនៅក្នុងរាជធានីភ្នំពេញ។ ទាក់ទងទៅនឹងប្រធានបទនេះផងដែរ កន្លងមកមានសិស្សច្បងជាច្រើនបានជ្រើសរើសយកប្រធានបទនេះដើម្បីយកមកសរសេរជាសារណា ដែលគោលដៅនៃការជ្រើសរើសប្រធានបទនេះ គឺពួកគាត់ចង់ស្វែងយល់ពីប្រធានបទនេះកាន់តែច្បាស់ និងបានជាស្ពានដែសម្រាប់មនុស្សគ្រប់រូបស្វែងយល់បន្ថែមអំពីបញ្ហាសំរាម សំណល់រឹងនេះ ហើយក៏ជាការចូលរួមក្នុងការចែករំលែកពីការគ្រប់គ្រងសំរាមដើម្បីឱ្យការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញកាន់តែមានភាពល្អប្រសើរ។

បើទោះបីជាមានការកំណែទម្រង់ និងមានការផ្សព្វផ្សាយចែករំលែកយ៉ាងណាក៏ដោយ ការគ្រប់គ្រងសំរាម សំណល់រឹងនៅ តែជាបញ្ហាសំខាន់មួយសម្រាប់រាជធានីភ្នំពេញ។ បរិមាណសំរាមដែលបានចាក់ចោលក្នុងទីលានចាក់សំរាមប្រចាំខែ បានកើនឡើងទ្វេដងក្នុងរយៈពេលមួយទស្សវត្សរ៍ចុងក្រោយនេះ។ប្រសិនជាសំណល់រឹងបន្តកើនឡើងក្នុងល្បឿនដូចសព្វថ្ងៃជាពិសេសនៅទីក្រុងធំៗមួយចំនួនដូចជា ក្រុងភ្នំពេញដែលផលិតសំរាមជាមធ្យម ២,២១៦តោនជារៀងរាល់ថ្ងៃ។ សំរាមជាច្រើនអាចកែច្នៃដើម្បីប្រើប្រាស់ឡើងវិញ ប៉ុន្តែមានតែសំរាមជាង២០% ប៉ុណ្ណោះដែលត្រូវបានកែច្នៃឡើងវិញ។ កាកសំណល់ទាំងអស់ត្រូវបានប្រមូលដោយក្រុមហ៊ុនឯកជន ហើយយកទៅចាក់ចោលនៅទីលានចាក់សំរាម ដោយមិនមានបែងចែកសំណល់សម្រាប់កែច្នៃឡើងវិញ ឬប្រើប្រាស់ឡើងវិញឡើយ។ ហេតុផលចំបងស្តីពីបញ្ហានេះក៏ព្រោះតែចំណេះដឹងរបស់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិត លើការអនុវត្តវិធីសាស្ត្រទាំង៣ ក្នុងការកាត់បន្ថយប្លាស្ទិក (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) រួមទាំងកម្រិតយល់ដឹងអំពីការកែច្នៃសំរាមឱ្យទៅជាថាមពលអគ្គីសនី។ ខណៈរដ្ឋបាលរាជធានីភ្នំពេញ បានកំពុងខិតខំប្រឹងប្រែងយ៉ាងច្រើន ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង ការដោះស្រាយបញ្ហាការកើនឡើងនៃសំណល់ដ៏គំហុកនេះ គឺជាកិច្ចការដ៏លំបាកមួយ។ ការប្រមូល ការដឹកជញ្ជូន និងការចាក់ចោលសំរាមត្រូវតែពង្រឹង ប៉ុន្តែគោលការណ៍៣Rs ក្នុងការកាត់បន្ថយប្លាស្ទិក (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើង

វិញ) និងត្រូវជំរុញការទុកដាក់សំរាមឲ្យបានត្រឹមត្រូវផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការនៃគ្រប់ភាគីពាក់ព័ន្ធ ដែលបង្កើតសំណល់ទាំងអស់គ្នា។

ដោយសារតែមើលឃើញពីភាពចាំបាច់នៃការគ្រប់គ្រងសំរាមបែបនេះហើយ ទើបក្រុមរបស់យើងខ្ញុំ សម្រេចជ្រើសរើសយកប្រធានបទ «ការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ» យកមកធ្វើការស្រាវជ្រាវ និងចងក្រងជាឯកសារ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់បន្ថែមទៀតពីការគ្រប់គ្រងសំរាមក្នុងរាជធានីភ្នំពេញ។

## ២. ចំណោទបញ្ហា

បញ្ហាសំរាម គឺជាបញ្ហាដ៏សំខាន់មួយ ដែលកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងរាជធានីភ្នំពេញ។ បរិមាណនៃសំរាមកាន់តែមានការកើនឡើងកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើឲ្យមានផលប៉ះពាល់ជាខ្លាំងក្នុងការរស់នៅរបស់ មនុស្ស សត្វ និងជីវៈមានជីវិត។ បញ្ហានេះ គឺតម្រូវឱ្យមានការគ្រប់គ្រងសំរាមឱ្យបានត្រឹមត្រូវ បើពុំដូច្នេះទេបញ្ហានេះនូវតែបន្តកើតមានឡើងជាដដែល ហើយកាន់តែខ្លាំងឡើងៗ។ ដូច្នេះហើយ ខ្លឹមសារនៃប្រធានបទនេះនឹងឆ្លើយតបទៅនឹងសំនួរសំខាន់ៗដូចខាងក្រោម៖

- តើមានទ្រឹស្តីអ្វីខ្លះដែលពាក់ព័ន្ធនិងការគ្រប់គ្រងសំរាម និងសំណល់រឹង?
- តើស្ថាប័នណាខ្លះ ដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងសំរាម និងសំណល់រឹង?
- តើស្ថាប័នទាំងនោះមានតួនាទី និងភារកិច្ចអ្វីខ្លះពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម និងសំណល់រឹង?
- តើការគ្រប់គ្រងសំរាម សំណល់រឹងមានបញ្ហាប្រឈម និងដំណោះស្រាយអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះមានគោលបំណង

- ដើម្បីយល់ដឹងពីទ្រឹស្តីពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង
- ដើម្បីឱ្យយល់ដឹងពីរបៀបនៃការគ្រប់គ្រងសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ
- ស្វែងយល់អំពីតួនាទី និងភារកិច្ចរបស់ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង
- ស្វែងយល់ពីបញ្ហាប្រឈម ដំណោះស្រាយនៃការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានដែនកំណត់ និងវិសាលភាពគ្រប់ដណ្តប់តែលើការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ នៅឆ្នាំ២០២១-២០២២ប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមានសារៈប្រយោជន៍តិច ឬច្រើន។ ដំបូងនៅក្នុងការស្រាវជ្រាវឯកសារនៃប្រធានបទនេះធ្វើក្រុមរបស់យើងខ្ញុំទទួលបាននូវចំណេះដឹងថ្មី និងមានប្រយោជន៍យ៉ាងខ្លាំង។ បន្ទាប់មកវាក៏បានផ្ដល់ជាសារៈប្រយោជន៍ដល់អ្នកស្រាវជ្រាវ អ្នកអាន និងសាធារណៈជនគ្រប់រូបដែលបានអាននូវស្នាដៃនេះ។ សារៈប្រយោជន៍ទាំងនេះ មានដូចជា៖

- បានជាឯកសារតម្កល់សម្រាប់សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវសម្រាប់អាន និងធ្វើការស្រាវជ្រាវ
- យល់ដឹងពីការគ្រប់គ្រងសំរាម និងសំណល់រឹង ដូចជាការញែក ការទុកដាក់ និងការចោលសំរាម
- សាធារណៈជនអាចទទួលបានចំណេះដឹងកាន់តែច្បាស់ពីផលប៉ះពាល់នៃសំរាម
- យល់ដឹងពីដំណោះស្រាយក្នុងការកាត់បន្ថយសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ
- យល់ដឹងពី គោលការណ៍៣Rs ក្នុងការកាត់បន្ថយប្លាស្ទិក (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) និងរួមចំណែកឱ្យការគ្រប់គ្រងសំរាមកាន់តែមានប្រសិទ្ធភាពជាងមុន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសរសេរកិច្ចការសារណានេះឡើង យើងខ្ញុំបានធ្វើការស្រាវជ្រាវទៅលើឯកសារដូចជា៖

- ព្រះរាជក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីណែនាំ
- សៀវភៅ
- របាយការណ៍
- កិច្ចសម្ភាសន៍
- និងប្រព័ន្ធអ៊ីនធើណែត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធស្រាវជ្រាវក្រោមប្រធានបទ “**ការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ**” នេះត្រូវបានចងក្រងចែកចេញជាបីជំពូកសំខាន់ៗដូចខាងក្រោមនេះ៖

- ជំពូក១ រំលឹកទ្រឹស្តី
- ជំពូក២ ការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ
- ជំពូក៣ បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. លិខិតគតិយុត្ត របាយការណ៍ និងទ្រឹស្តីពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

### ១.១.១. លិខិតគតិយុត្ត

**ក.អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង**

នៅខែមេសា ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើត និងប្រកាសឱ្យប្រើប្រាស់អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងគោលបំណងកំណត់ការគ្រប់គ្រងសំណល់រឹង។ អនុក្រឹត្យនេះជាមូលដ្ឋានច្បាប់សម្រាប់កំណត់នូវការបោះចោលសំរាម ការទុកដាក់ ការប្រមូល ការដឹកជញ្ជូន ការកែច្នៃនិងការចាក់ពីលំនៅដ្ឋាន និងសំរាមដែលគ្រោះថ្នាក់។

ក្នុងអនុក្រឹត្យនេះតម្រូវឱ្យក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយប្រសិទ្ធភាព។[1]

**ខ.អនុក្រឹតស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន**

នៅក្នុងនោះដែរ នៅខែសីហា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើត និងប្រកាសឱ្យប្រើប្រាស់អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។ អនុក្រឹត្យនេះជា មូលដ្ឋានច្បាប់សម្រាប់កំណត់នូវការបោះចោលសំរាម ការទុកដាក់ ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការចាក់ពីលំនៅដ្ឋាន និងសំរាមដែលគ្រោះថ្នាក់ ព្រមទាំងហាមឃាត់នូវការបោះចោល ឬចាក់សំរាម សំណល់រឹងរាយប៉ាយតាមដងផ្លូវសាធារណៈទីប្រជុំជន ទីផ្សារ កន្លែងកម្សាន្ត តាមឆ្នេរ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ប្រព័ន្ធលូ។

ជារួមអនុក្រឹត្យលេខ១១៣ នេះ មានគោលបំណងដូចខាងក្រោម៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធនានា ដែលធ្វើការក្នុងផ្នែកគ្រប់គ្រងសំរាម
- ប្រគល់ភារកិច្ចក្នុងការគ្រប់គ្រងសំរាម ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- កំណត់វិធានការចាំបាច់នានា សំដៅលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពការងារគ្រប់គ្រងសំរាម

---
[1] រ៉ុន ជូឌី និងទ្រី វិណ្ណឌី(ការគ្រប់គ្រងសំរាម នៅក្នុងរាជធានីភ្នំពេញ) ទំព័រ៩ ឆ្នាំ២០១៩

- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍ និងការអនុវត្តការងារគ្រប់គ្រងសំរាមនៅតាមមូលដ្ឋាន។

បន្ថែមពីលើអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលរាជធានីភ្នំពេញ ( សាលាក្រុង ) បានចេញនូវសេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ដើម្បីឱ្យការអនុវត្តថ្មីនៃប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សេចក្តីណែនាំនេះ មានគោលបំណងធ្វើការណែនាំអំពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ។[2]

**គ.ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត-ក្រុង**

បន្ថែមទៅលើអនុក្រឹត្យស្តីពី ការគ្រប់គ្រងសំណល់រឹង ក្រោយមកនៅឆ្នាំ២០០៣ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ បានចេញប្រកាសអន្តរក្រសួងលេខ៨០ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះមានគោលបំណងជំរុញកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការអនុវត្តដោយប្រសិទ្ធភាពនូវវិធានការគ្រប់គ្រងសំរាម នៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន សំដៅឱ្យបាននូវកិច្ចការពារសុខភាពសាធារណៈ សោភ័ណភាព គុណភាពបរិស្ថាននិងជីវៈចម្រុះ។ សេចក្តីប្រកាសបានកំណត់យ៉ាងច្បាស់ថា ការបោះចោល ឬការចាក់ចោលសំរាម សំណល់រឹងរាយប៉ាយតាមដងផ្លូវសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកម្សាន្ត តាមឆ្នេរ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ប្រព័ន្ធលូប្រព័ន្ធប្រលាយកសិកម្មត្រូវហាមឃាត់ដាច់ខាត។

ជារួមប្រកាសអន្តរក្រសួងលេខ៨០នេះ ផ្តល់ទៅឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធនានានូវតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ដាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់ ដើម្បីធានានូវសោភ័ណភាព និងបរិស្ថានស្អាត
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្ន ឱ្យបានសមរម្យ ដោយគ្មានការរំខានដល់ចរាចរណ៍ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- ដាក់ស្លាកហាមចោលសំរាម និងអប់រំឱ្យមានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។ល។

ដើម្បីពង្រឹងការអនុវត្តច្បាប់ និងកែលម្អភាពអវិជ្ជមានទាក់ទងទៅនឹងការគ្រប់គ្រងសំរាម នៅដើមឆ្នាំ២០១០សាលារាជធានីភ្នំពេញ បានចាប់ផ្តើមធ្វើការផាកពិន័យ ទៅលើបុគ្គលទាំងឡាយណាដែលបោះចោល

[2] រ៉ុន ជូឌី និងទ្រី វិណ្ណឌី( ការគ្រប់គ្រងសំរាម នៅក្នុងរាជធានីភ្នំពេញ ) ទំព័រ១០ ឆ្នាំ២០១៩

សំរាមក្រៅធុងនៅតាមសួនច្បារសាធារណៈ និងបានជំរុញការគ្រប់គ្រងសំរាមសើម និងស្ងួតនៅតាមទីផ្សារមួយចំនួននៅរាជធានីភ្នំពេញ។[3]

### ១.១.២.របាយការណ៍

របាយការណ៍ស្តីពីវឌ្ឍនភាពការងារនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២១។

**ក. ការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង**

ជាមួយនឹងមធ្យោបាយប្រតិបត្តិការ និងកម្លាំងដែលប្រតិបត្តិករទាំង០៣បានរៀបចំ ធ្វើឲ្យការអនុវត្តការងារផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ក៏ដូចជាការបោសសម្អាតថ្នល់ ការលាងថ្នល់ បានត្រឹមត្រូវតាមកម្មវិធី និងពេលវេលាដែលបានកំណត់ក្នុងតំបន់នីមួយៗប្រកបដោយមានលក្ខណៈល្អប្រសើរ ដោយទទួលបានការសាទរពីប្រជាពលរដ្ឋ។ ទន្ទឹមនឹងការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ប្រតិបត្តិករទាំង ០៣ បានរៀបចំសិក្ខាសាលា ស្តីពីការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងគោលបំណងផ្សព្វផ្សាយអនុក្រឹត្យលេខ ១១៣ អនក្រ.កប សេចក្តីណែនាំ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ដោយក្នុងនោះមានដូចខាងក្រោម៖

- ក្រុមហ៊ុន 800 Super-GAEA (Cambodia) Co., Ltd បានធ្វើសិក្ខាសាលាសរុបចំនួន៣៥លើក (ថ្នាក់ខណ្ឌ១២លើក ថ្នាក់សង្កាត់១៨លើក និងសាលារៀន៥លើក) និងមានការចែកខិតប័ណ្ណផ្សព្វផ្សាយតាមខ្នងផ្ទះសរុបចំនួន ៣២២៦៥ផ្ទះ និងបានដាក់ពង្រាយធុងសំរាមចំនួន ១៩១ធុង។
- ក្រុមហ៊ុន Mizuda Sanitation (Cambodia) Co., Ltd បានធ្វើសិក្ខាសាលាសរុបចំនួន១២លើក និងបានដាក់ពង្រាយធុងសំរាមចំនួន ៥០០០ធុង។
- ក្រុមហ៊ុន CINTRI/Everbright បានធ្វើសិក្ខាសាលាសរុបចំនួន៩លើក (ថ្នាក់ខណ្ឌ៤លើក ថ្នាក់សង្កាត់៥លើក) និងបានដាក់ពង្រាយធុងសំរាមចំនួន ៦៥១ធុង។

**ខ. បរិមាណសំរាម សំណល់រឹងដែលបានប្រមូល និងដឹកជញ្ជូនដោយប្រតិបត្តិករទាំង០៣**

បន្ទាប់ពីអនុវត្តន៍ការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមតាមកម្មវិធីថ្មីឃើញថា បរិមាណសំរាម ដែលបានដឹកទៅចាក់នៅទីលានចាក់សំរាមដង្កោ មានការកើនឡើងជាមធ្យមប្រមាណជា៣.០៥០តោន/ថ្ងៃ ដែលកាលពីមុនមានប្រមាណ២.៧០០តោន/ថ្ងៃ ប៉ុណ្ណោះ។

**គ. ការទុកដាក់សំរាម នៅទីលានចាក់សំរាមដង្កោ**

[3] រ៉ុន ជូឌី និងទ្រី វិណ្ណឌី(ការគ្រប់គ្រងសំរាម នៅក្នុងរាជធានីភ្នំពេញ) ទំព័រ៩ ឆ្នាំ២០១៩

ក្រោយពីទទួលបាលគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងបរិក្ខា សម្រាប់រយៈពេល០២ឆ្នាំ (២០២១-២០២២) ទីលានចាក់សំរាមដង្កោ បានពង្រឹងកិច្ចប្រតិបត្តិការបច្ចេកទេសក្នុងការឈូសឆាយ និងទុកដាក់សំរាម សំណល់រឹងដែលបានដឹកមកចាក់ប្រចាំថ្ងៃ ដោយបែងចែកក្រុមការងារជា០២វេន (វេនថ្ងៃ និងវេនយប់) គ្រឿងចក្រសរុប១២គ្រឿង (ប៊ូលដូស័រ៩គ្រឿង និងអ៊ិចស្កាវ៉ាទ័រ៣គ្រឿង) ជញ្ជីងថ្លឹងសំរាម៣កន្លែង ទីតាំងចាក់សំរាម៤កន្លែង។ ចាប់តាំងពីត្រីមាសទី២ ឆ្នាំ២០១៩ រហូតទល់បច្ចុប្បន្ននេះ ដំណើរការប្រតិបត្តិការនៅទីលានមានលក្ខណៈល្អប្រសើរ ដោយចរន្តនៃការចូលចាក់សំរាមមានប្រក្រតីភាពធម្មតា ដោយមិនមានកកស្ទះនោះទេ។

**ឃ. ការងារប្រមូលចំណូលថ្លៃសេវាសំរាម សំណល់រឹង**

ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ បានដាក់អនុវត្តនូវតារាងកម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹង(ថ្មី) នៅរាជធានីភ្នំពេញ ដោយក្នុងនោះ បានធ្វើការកែតម្លៃក្នុងប្រព័ន្ធបង់ប្រាក់ស្វ័យប្រវត្តិ ដែលជាប្រភេទផ្ទះស្នាក់នៅធម្មតា សរុបចំនួន ២៦៤.៥៤១ ទីតាំង។ ទន្ទឹមនឹងនេះ ដើម្បីជំរុញ និងបង្កើនប្រមូលចំណូលថ្លៃសេវាសំរាម សំណល់រឹង ក្រុមការងារបានចុះពិនិត្យទីតាំង និងដោះស្រាយជាមួយអតិថិជនលើការងារដូចខាងក្រោម៖

- បានចុះពិនិត្យទីតាំងសរុប ២.២៦៣ទីតាំង
- កំណត់ឡើងវិញចំនួន ៧.៩៤៤ទីតាំង
- ចេញលិខិតទារបំណុលអតិថិជន ១.៤៨៩ទីតាំង
- បានកំពុងធ្វើការបញ្ចូលទិន្នន័យអតិថិជនថ្មី ដែលបានមកពីទិន្នន័យរបស់អគ្គីសនីកម្ពុជា (អតិថិជនតភ្ជាប់បណ្តាញថ្មី) ចំនួន ៦៩.៧៨៥ទីតាំង និងសេវាករឯកជន ចំនួន ៤២.២២៦ទីតាំង។ សម្រាប់ការបញ្ចូលទិន្នន័យទាំងអស់នេះ នឹងគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២២ខាងមុខ។
- បានកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងថ្មី ដែលប្រព័ន្ធនឹងផ្តល់ភាពងាយស្រួល និងអត្ថប្រយោជន៍ ដូចជាការទូទាត់ថ្លៃសេវាសំរាមបានឆាប់រហ័ស ការគ្រប់គ្រងទិន្នន័យអតិថិជន ការធ្វើស្វ័យប្រកាស ការស្នើ/ការផ្លាស់ប្តូរសេវាសំរាម ការរាយការណ៍ពីភាពយឺតយ៉ាវរបស់ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូន ការទទួលព័ត៌មាន និងការស្នើសុំផ្សេងៗពាក់ព័ន្ធនឹងសេវាសំរាម តាមរយៈប្រព័ន្ធsoftwareនិងMobile Application។ ប្រព័ន្ធគ្រប់គ្រងថ្មីនេះក៏ជាយន្តការតាមដាន ត្រួតពិនិត្យលើការផ្តល់សេវាសំរាមទាំងមូលរវាងរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនប្រមូលសំរាម និងប្រជាពលរដ្ឋ។[4]

### ១.១.៣. សំយោគការសិក្សាពីមុនៗ

[4] របាយការណ៍ស្តីពីវឌ្ឍនភាពនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជននៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែ ធ្នូឆ្នាំ២០២១

តាមការសិក្សាទៅលើការស្រាវជ្រាវពីមុនៗមក ការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ គឺនៅមិនទាន់បានល្អនៅឡើយទេ ដែលមានឧបសគ្គជាច្រើនដែលកើតឡើងនៅក្នុងការគ្រប់គ្រងដែលតម្រូវឱ្យមានការខិតខំរកនូវដំណោះស្រាយបន្ថែមទៀតដើម្បីជម្នះនូវឧបសគ្គទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយការគ្រប់គ្រងសំរាម សំណល់រឹងកាន់តែមានភាពប្រសើរ ដោយសារតែរដ្ឋាភិបាលបានចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីផ្តល់ជាភាពងាយស្រួលក្នុងការប្រមូលសំរាម។ នៅក្នុងនោះដែររដ្ឋក៏បានអនុញ្ញាតឱ្យមានការចូលរួមពីវិស័យឯកជននៅក្នុងការផ្តល់សេវា ប្រមូល សម្អាត និងដឹកជញ្ជូនសំរាម ដែលជួយឱ្យការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញកាន់តែមានភាពប្រសើរឡើង។

នៅក្នុងនោះ បញ្ហាសំខាន់ៗដែលបានកើតមានឡើងចំពោះការគ្រប់គ្រងសំរាម សំណល់រឹង គឺបញ្ហាកង្វះចំណេះដឹងរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹង ការញែក ការវេចខ្ចប់ ការទុកដាក់សំរាម សំណល់រឹង និងការមិនទាន់យល់ដឹងរបស់ប្រជាពលរដ្ឋទៅលើលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹង។ មានការកើនឡើងនៃសំរាម សំណល់រឹងយ៉ាងច្រើននៅរាជធានីភ្នំពេញ តែសំរាមទាំងនោះមានភាគតិចប៉ុណ្ណោះដែលបានយកទៅកែច្នៃ នេះក៏ជាបញ្ហាមួយផងដែរដែលកើតមានឡើងនៅក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។ និងបញ្ហាសំខាន់មួយទៀត គឺទីលានចាក់សំរាម ដោយសារតែសំរាមកាន់តែមានការកើនឡើង ធ្វើឱ្យទីលានចាក់សំរាមមិនអាចទ្រទ្រង់បាន។ ដែលទាំងនេះសុទ្ធតែជាបញ្ហាប្រឈមដែលភាគីពាក់ព័ន្ធត្រូវចូលរួមដោះស្រាយ។

ចំណែកឯដំណោះស្រាយទៅលើបញ្ហានេះវិញ គឺត្រូវមានការអប់រំ ផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការញែក ការវេចខ្ចប់ ការទុកដាក់ និងយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង។ នៅក្នុងនោះផងដែរក៏ត្រូវមានការរៀបចំប្រព័ន្ធនៃការគ្រប់គ្រងទីលានចាក់សំរាម ឱ្យបានត្រឹមត្រូវ និងតាមស្តង់ដារ។ ជាងនេះទៅទៀត ក៏ត្រូវមានការរៀបចំប្រព័ន្ធការងារគ្រប់គ្រង និងប្រើប្រាស់ឡើងវិញទៅលើការកែច្នៃសំរាម សំណល់រឹង ដើម្បីយកទៅប្រើប្រាស់ឱ្យមានប្រយោជន៍ ដូចជាការយកទៅធ្វើជីកំប៉ុស្តិ៍ និងចំណីសត្វជាដើម។

## ១.២. សញ្ញាណទូទៅនៃការគ្រប់គ្រង

### ១.២.១. និយមន័យ

ការគ្រប់គ្រង (Management) គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពអោយទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ ។[5]

### ១.២.២. មុខងារនៃការគ្រប់គ្រង

[5] https://sokankeng.wordpress.com/2013/12/03/(ចូលមើលចុងក្រោយ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២)

មុខងារនៃការគ្រប់គ្រងមាន៤គឺ៖

❖ ការធ្វើផែនការPlanning:

គិតពីការធ្វើផែនការនៅក្នុងតួនាទីគ្រប់គ្រង គឺគិតថាតើដំណើរការនៃគោលដៅនិងសកម្មភាពសមស្រប ណាគួរជ្រើសយក ដើម្បីបន្តទៅមុខសកម្ម ហើយបន្ទាប់មកកំណត់ថាតើត្រូវប្រើយុទ្ធសាស្ត្រអ្វីខ្លះ សកម្មភាពអ្វី ធនធានអ្វីខ្លះដើម្បីសម្រេចគោលដៅ។

❖ ការរៀបចំOrganizing:

នេះជាដំណើរការនៃការបង្កើតទំនាក់ទំនងរវាងកម្មករនិយោជិតដែលអនុញ្ញាតឱ្យកម្មករនិយោជិតធ្វើការ ជាមួយគ្នាដើម្បីសំរេចបានគោលដៅរបស់អង្គភាព ដោះស្រាយទំនាស់និងសម្រួលបញ្ហា ជួយគាំទ្រពេលមាន វិបត្តិ។

❖ ដឹកនាំLeading

មុខងារនេះពាក់ព័ន្ធនឹងការបង្ហាញចក្ខុវិស័យ បង្កើនថាមពល និងបំផុសលើកទឹកចិត្តមនុស្សក្នុងក្រុម ដោយប្រើចក្ខុវិស័យ បង្កើនឥទ្ធិពលវិជ្ជមាន សិល្បៈបញ្ចុះបញ្ចូលនិងជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យផលិតភាពការងារកើន និងគ្រប់គ្នាធ្វើការបានដោយរលូន។

ខណៈពេលដែលអ្នកគ្រប់គ្រងតែងតែចាត់ទុកការងាររបស់ពួកគេថាជាភារកិច្ចតម្រង់ទិសទស្សនៈនិងតាម ដានបុគ្គលិក តាមពិតវាជាការគិតខុស។

❖ ការត្រួតពិនិត្យControlling:

វាយតម្លៃថាតើអ្នកកំពុងតែសំរេចគោលដៅរបស់អ្នកបានល្អប្រសើរធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត សកម្មភាពចាត់វិធានការយ៉ាងដូចម្តេច។ ដាក់ដំណើរការឱ្យបានត្រឹមត្រូវដើម្បីជួយអ្នកបង្កើតស្តង់ដារដូច្នេះអ្នក អាចវាស់ប្រៀបធៀបនិងធ្វើការសម្រេចចិត្ត។

ការគ្រប់គ្រងគឺជាវិន័យដែលមានសំណុំមុខងារទូទៅ៤ យ៉ាងនេះជាចំណុចដំបូងនិងចាំបាច់។ ការរៀបចំ ផែនការ ការរៀបចំបុគ្គលិក ការដឹកនាំពួកគេ និងការត្រួតពិនិត្យ។ មុខងារទាំង ៤ នេះគឺជាផ្នែកមួយនៃការអនុវត្តពី វិធីក្លាយជាអ្នកគ្រប់គ្រងដែលជោគជ័យ។

ការយល់ដឹងអំពីមុខងារនៃការគ្រប់គ្រងទាំង៤នេះច្បាស់នឹងជួយអ្នកគ្រប់គ្រងនានា ផ្តោតការខិតខំប្រឹង ប្រែងលើសកម្មភាពប្រចាំថ្ងៃ ដែលខ្លួនទទួលបានលទ្ធផល។[6]

### ១.២.៣. កម្រិតនៃការគ្រប់គ្រង

កម្រិតនៃការគ្រប់គ្រងមាន ៣ រួមមានដូចតទៅ ៖

---

[6] https://clubniset.wordpress.com/2011/05/31 ( ចូលមើលចុងក្រោយ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២ )

អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ (Top Managers) គឺជាក្បាលម៉ាស៊ីនបញ្ជា និងទទួលខុសត្រូវទូទៅលើរាល់ប្រតិបត្តិការទាំងអស់របស់អង្គភាព អ្នកគ្រប់គ្រងនេះគឺជាអ្នកផ្តួចផ្តើម បង្កើតរូបមន្តយុទ្ធសាស្រ្តក្នុងដំណើរការប្រតិបត្តិការរបស់អង្គភាពគេក៏ត្រូវសំដែងផងដែរនូវភាពជាអ្នកដឹកនាំ ចាត់តាំង ពង្រឹងកម្មវិធីធ្វើការងារ តាមដានត្រួតពិនិត្យ វាយតំលៃ និងជំរុញសកម្មភាពការងារឱ្យបានសំរេចនូវគោលដៅដែលបានដាក់ចេញ ។ ជាទូទៅគេមានឈ្មោះថា ប្រធាន អនុប្រធាន នាយក ឬ នាយករង...។

អ្នកគ្រប់គ្រងថ្នាក់កណ្តាល (Middle Managers) គឺជាអ្នកដែលទទួលខុសត្រូវផ្ទាល់លើអ្នកគ្រប់គ្រងថ្នាក់ទាប គឺជាអ្នកគ្រប់គ្រងនៅតាមបណ្តា ផ្នែកជំនាញនីមួយៗ ឧទាហរណ៍ ផ្នែកគណនេយ្យហិរញ្ញវត្ថុ...សំខាន់ជាងនេះទៀត អ្នកគ្រប់គ្រងកណ្តាលជាអ្នកទទួលខុសត្រូវលើការអនុវត្តផែនការ និងគោលនយោបាយតាមផ្នែករបស់អង្គភាព ដើម្បីប្រមូលផ្តុំជាគោលដៅរួមសំដៅសម្រេចផែនការរួម ។

អ្នកគ្រប់គ្រងថ្នាក់ទាប (Lowest Managers) គឺជាអ្នកដឹកនាំផ្ទាល់នូវរាល់សកម្មភាពការងាររបស់និយោជិក វាជាជំហ៊ានដំបូងនៃការគ្រប់គ្រងរបស់គេ គឺដឹកនាំសកម្មភាពការងាររបស់និយោជិកប្រចាំថ្ងៃ ដើម្បីអនុវត្តន៍តាមផែនការដែលបានដាក់ចុះ ដូចនេះអ្នកគ្រប់គ្រងថ្នាក់ទាបត្រូវតែពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យផ្ទាល់លើការកែតម្រូវ ឬដោះស្រាយរាល់បញ្ហាដែលទាក់ទងទៅនឹងការងារនោះ ប្រការនេះអ្នកគ្រប់គ្រងថ្នាក់ទាបត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដំណើរការការងាររបស់អង្គភាព ។ ឧទាហរណ៍ ប្រធានក្រុម ប្រធានផ្នែក ។[7]

## ១.៣. និយមន័យ និងប្រភពនៃសំរាម និងសំណល់រឹង

### ១.៣.១.និយមន័យសំរាម និងសំណល់រឹង

សំរាម គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

សំណល់រឹង៖ គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កម្ទេចកម្ទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។[8]

សំណល់ទីប្រជុំជន៖ សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬ បង្កើតពីសកម្មភាពអាជីវកម្ម ឬ សេវាកម្ម ដែលមិនមានផ្ទុកសារធាតុពុល ឬ សំណល់គ្រោះថ្នាក់។

សំណល់រឹងឧស្សាហកម្ម៖ សំដៅដល់សំណល់ដែលបានបន្សល់ ឬ បង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬ សហគ្រាស ដែលមិនមានផ្ទុកសារធាតុពុល ឬ សំណល់គ្រោះថ្នាក់ ។

[7] https://sokankeng.wordpress.com/2013/12/03/(ចូលមើលចុងក្រោយ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២)

[8] អនុក្រឹត្យ លេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ទំព័រ១ ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

សំណល់គ្រោះថ្នាក់៖ សំដៅដល់វត្ថុធាតុរឹង រាវ និងឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចម្លងជំងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្ករឱ្យមានជំងឺមហារីក ឬ សារធាតុគីមីពុលដទៃផ្សេងទៀត ដែលបង្កអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អាគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មផ្សេងៗ។

ការទាញយកធនធាន ៖ សំដៅដល់សកម្មភាពជម្រើស ឬ ប្រើប្រាស់សំរាម សំណល់រឹង ធ្វើជាជីកំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬ សារប្រយោជន៍នានា។

ការកែច្នៃ៖ សំដៅដល់សកម្មភាព ឬដំណើការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

ការប្រើប្រាស់ឡើងវិញ៖ សំដៅដល់សកម្មភាព ឬដំណើរការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយរក្សាទ្រង់ទ្រាយដើម ។

ការញែក៖ ជាការបែកចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើត សម្រាប់គោលបំណងការទាញយកធនធាន ឬ ដើម្បីសុវត្ថភាពក្នុងការយកទៅចាក់នៅទីលាន។

ទីលាន ៖ សំដៅដល់ទីកន្លែងដែលអជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថាន សម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

ការធ្វើប្រព្រឹត្តិកម្ម៖ សំដៅដល់សកម្មភាព ឬ វិធានការណ៍នៅក្នុងគោលបំណងធ្វើអោយប្រសើរឡើងនៅការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលរួមមាន៖ ការបន្ថយទំហំ បរិមាណសំរាមសំណល់រឹងមុនការយកទៅចាក់ដូចជាការ ដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដកយក ការដុតនៅក្នុងឡ ឬកម្ទេចចោលការរំលាយជាតិពុល សារធាតុគ្រោះថ្នាក់ ឬ ភ្នាក់ងារចម្លងជំងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនយកទៅចាក់ចោលនៅទីលាន។

ទីប្រជុំជន៖ សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជន ផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

ទីតាំង៖ គឺសំដៅដល់កន្លែងផលិកម្ម អាជីវកម្ម សេវាកម្ម អារគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជ-កម្ម។[៩]

[៩] រ៉ុន ជូឌី និងទ្រី វិណ្ណឌី(ការគ្រប់គ្រងសំរាម នៅក្នុងរាជធានីភ្នំពេញ) ទំព័រ៦ និង៧ ឆ្នាំ២០១៩

**១.៣.២. ប្រភពនៃសំរាម សំណល់រឹង**

សំរាម សំណល់រឹង មានប្រភពចេញមកពីគ្រប់ទីកន្លែងដូចជា រោងចក្រឧស្សាហកម្ម សិប្បកម្ម សាលារៀន មន្ទីរពេទ្យ ទីផ្សារ និងតាមលំនៅដ្ឋានរបស់ប្រជាជនជាដើម។ល។ រីឯ កាកសំណល់ផ្ទះបាយមានប្រភពចេញពីគេហដ្ឋាននីមួយៗរបស់ប្រជាជន។[10]

[10] រ៉ុន ជូឌី និងទ្រី វ័ណ្ណឌី( ការគ្រប់គ្រងសំរាម នៅក្នុងរាជធានីភ្នំពេញ ) ទំព័រ៧ ឆ្នាំ២០១៩

# ជំពូកទី២
# ការគ្រប់គ្រងសំរាម សំណល់រឹង ក្នុងរាជធានីភ្នំពេញ

# ជំពូកទី២
# ការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ

## ២.១. ទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ

ភ្នំពេញ ស្ថិតនៅក្នុងតំបន់ខាងត្បូងនៃប្រទេសកម្ពុជា នៅចំណុចប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ។ ទន្លេទាំងនេះផ្តល់នូវ ប្រព័ន្ធអេកូឡូស៊ីទឹកសាប ប្រកបដោយសក្តានុពល ជាធនធានដ៏សំខាន់សម្រាប់លក្ខខណ្ឌ បរិស្ថានប្រកបដោយចីរភាព សោភ័ណភាព ធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុងចម្រើនសម្រាប់ប្រជាជននៅរាជធានី ភ្នំពេញ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ។

រាជធានីភ្នំពេញមានផ្ទៃដីចំនួន ៦៩២,៤៦គីឡូម៉ែត្រក្រឡា ដែលមានខណ្ឌចំនួន១៤ មាន១០៥សង្កាត់ និងមានភូមិចំនួន៩៥៤។ រាជធានីភ្នំពេញមានប្រជាជនសរុបចំនួន ២.១២៩.៣៧១។ នៅក្នុងនោះមានស្រីចំនួន ១.០៩០.១៧៩នាក់។ ដែលមានចំនួនគ្រួសារសរុបចំនួន ៣៩៩.២០៣គ្រួសារ។

មានអាកាសធាតុក្តៅ ពេញមួយឆ្នាំ ដោយគ្រាន់តែមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ ។ នៅក្នុងរាជធានីកម្រិតសីតុណ្ហភាពមានចាប់ពី ១៨ អង្សា ដល់ ៣៨ អង្សាសេ (៦៤ ដល់ ១០០ អង្សាហ្វារិនហាយ) ។

**មានរដូវចំនួនពីរ គឺ ៖**

- រដូវប្រាំង ចាប់ពីខែធ្នូ ដល់ខែឧសភា (រយៈពេល៦ ខែ)
- រដូវវស្សា ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា (រយៈពេល ៦ ខែ)។[11]

## ២.២.រដ្ឋបាលរាជធានីភ្នំពេញ

### ២.២.១. ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់

ទីចាត់ការនេះ គឺជាសេនាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចខាងក្រោម៖

- កសាងគោលការណ៍ និងវិធានការលើការគ្រប់គ្រងកាកសំណល់
- ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់
- អប់រំ ផ្សព្វផ្សាយដល់សាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមក្នុងការគ្រប់គ្រងកាកសំណល់
- សហការដោះស្រាយវិវាទបរិស្ថានដែលបណ្តាលមកពីកាកសំណល់
- គ្រប់គ្រងការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម។

[11] https://phnompenh.gov.kh/phnom-penh-city/facts/ (ចូលមើលចុងក្រោយថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២)

- ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់ មានការិយាល័យចំណុះដូចខាងក្រោម៖
    - ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន
    - ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់។

### ២.២.២.ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន

ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងទិន្នន័យកាកសំណល់
- កសាងផែនការគ្រប់គ្រងកាកសំណល់
- កសាងគោលការណ៍ និងវិធានការលើការគ្រប់គ្រងកាកសំណល់
- ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់
- អប់រំ ផ្សព្វផ្សាយដល់សាធារណៈជន ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមក្នុងការគ្រប់គ្រងកាកសំណល់
- សហការជាមួយជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីកាកសំណល់
- ដោះស្រាយវិវាទបរិស្ថានដែលបណ្តាលមកពីកាកសំណល់។

### ២.២.៣.ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់

ការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងទីលានចាក់សំរាម
- គ្រប់គ្រងសកម្មភាពផ្តល់សេវាកម្ម និងប្រមូលដឹកជញ្ជូនសំរាម
- គ្រប់គ្រងការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម
- គ្រប់គ្រងការបូម និងទុកដាក់កាកសំណល់រាវ។[12]

## ២.៣. រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ

នៅក្នុងរាជធានីភ្នំពេញរយៈពេល១០ទៅ២០ឆ្នាំចុងក្រោយ គឺរាជធានីភ្នំពេញមានការអភិវឌ្ឍលឿន ដែលប្រទេសជាតិមានការអភិវឌ្ឍគ្រប់វិស័យ ជាពិសេសគឺវិស័យសេដ្ឋកិច្ច។ ប្រជាជននៅក្នុងរាជធានីភ្នំពេញក៏មានការកើនឡើង និងក្រឡាផ្ទៃនៃរាជធានីភ្នំពេញក៏មានការកើនឡើង ដែលធ្វើឲ្យបរិមាណសំរាមក៏មានការកើនឡើងដូចគ្នាការកើនឡើងនៃសំរាម សំណល់រឹងនេះធ្វើឲ្យក្រុមហ៊ុនដែលផ្តល់សេវាប្រមូល សម្អាត និងដឹកជញ្ជូនតែមួយ

[12] ហៀង សាង "សហគ្គិភាពរដ្ឋបាលដែនដីនៃកម្ពុជា" ទំព័រ៦៨ ដល់៦៩ បោះពុម្ពឆ្នាំ២០១៨

(ក្រុមហ៊ុន ស៊ីនទ្រី)មិនអាចទ្រទ្រង់បាន។ ដោយមើលឃើញពីស្ថានភាពជាក់ស្តែងថា ក្រុមហ៊ុនតែមួយមិនអាចផ្តល់សេវាបានបន្តទៀត នៅចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានសម្រេចធ្វើកំណែទម្រង់លើការងារគ្រប់គ្រងសំរាមសំណល់រឹងដែលនៅក្នុងកំណែទម្រង់នេះ គឺមានអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកដឹកនាំ។ ក្រសួងសេដ្ឋកិច្ចក៏បានដឹកនាំរដ្ឋបាលរាជធានីភ្នំពេញរៀបចំឲ្យមានការបង្កើតរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញឡើង។រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃលេខ១១៩៩០ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។[13]

### ២.៣.១. រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធនៃរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង មានសមាសភាពដូចជា៖

១. លោក នួន សំណាវុធ ជាអភិបាលរដ្ឋាករ (បន្ថែមលើមុខងារបច្ចុប្បន្ន)

២. លោក កែវចាន់ណារិទ្ធ ជាអភិបាលរងរដ្ឋាករ (បន្ថែមលើមុខងារបច្ចុប្បន្ន)

លោក ឡាយអ៊ើរិន ត្រូវបានតែងតាំងជា អភិបាលរងរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ។

អភិបាល និងអភិបាលរងរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងប្រតិបត្តិការប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹងពីលើក្រុមហ៊ុន ស៊ីនទ្រី នៅក្នុងអំឡុងពេលអន្តរកាល
- រៀបចំប្រព័ន្ធប្រមូល និងបង់ចំណូល
- ទូទាត់ថ្លៃការប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹងដល់ក្រុមហ៊ុនដែលប្រមូលសេវា
- គ្រប់គ្រងប្រតិបត្តិការគ្រប់គ្រងសំរាម និងសំណល់រឹងនៅទីលានចាក់សំរាមរបស់សាលារាជធានីភ្នំពេញ
- រៀបចំកែសម្រួលតារាងកម្រៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញពិនិត្យ និងសម្រេច

[13] កិច្ចសម្ភាសន៍ លោក នួន សំណាវុធ នាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន និងជា អភិបាលរដ្ឋាករស្វយ័ត គ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២

- រៀបចំនីតិវិធីចូលរួមដេញថ្លៃ ដើម្បីស្វែងរកដៃគូដែលមានសមត្ថភាពក្នុងការផ្តល់សេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង ដោយឈរលើគោលការណ៍ប្រកួតប្រជែង ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញពិនិត្យ និងសម្រេច
- សហការជាមួយក្រសួង-ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធ ដើម្បីបង្កើតទីលានសុវត្ថិភាពសម្រាប់ដាក់សំរាម និងសំណល់រឹង
- រៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីត្រួតពិនិត្យ និងតាមដានការងាររបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង
- មានសិទ្ធិស្នើជ្រើសរើស តែងតាំង ដកហូតអំណាច ឬបញ្ឈប់បុគ្គលិក និយោជិតគ្រប់រូបរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង
- ធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង
- បំពេញមុខងារក្នុងវិស័យខាងលើផ្សេងៗទៀត តាមការចង្អុលបង្ហាញពីអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។[14]

### ២.៣.២. តួនាទី និងភារកិច្ច

តួនាទី និងភារកិច្ចរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងមានដូចជា៖

- រៀបចំប្រព័ន្ធប្រមូល និងបង់ចំណូល
- រៀបចំនីតិវិធីឱ្យមានក្រុមហ៊ុនច្រើនចូលរួមដេញថ្លៃ ឈរលើគោលការណ៍ប្រកួតប្រជែង
- ទូទាត់ថ្លៃការប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹងដល់ក្រុមហ៊ុនដែលប្រមូលសេវា
- គ្រប់គ្រង ឃ្លាំមើល ត្រួតពិនិត្យ និងវាយតម្លៃលើក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនៅទីលានចាក់សំរាម និងសំណល់រឹង
- គ្រប់គ្រង ឃ្លាំមើល ត្រួតពិនិត្យ និងវាយតម្លៃលើក្រុមហ៊ុនប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង
- ធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង

[14] ដីកា លេខ ២២៤/១៩ ដក.តត.ធ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ របស់រដ្ឋបាលរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

- បំពេញមុខងារផ្សេងៗទៀតតាមការចង្អុលបង្ហាញពីអាជ្ញាធរអាណាព្យាបាល ឬតាមការចាំបាច់។[15]

## ២.៤. ស្ថាប័នឯកជន

បន្ទាប់ពីមានការកំណែទម្រង់ការគ្រប់គ្រងសំរាម សំណល់រឹងរួចមក មានក្រុមហ៊ុនឯកជនចំនួនបី ដែលទទួលបានសិទ្ធិក្នុងការសម្អាត ប្រមូល និងដឹងជញ្ជូនសំរាមក្នុងរាជធានីភ្នំពេញ។ ដែលក្រុមហ៊ុនទាំងបីនោះបានចាប់ផ្តើមដំណើរការតាំងពីខែកក្កដា ឆ្នាំ២០២១។ ហើយក្រុមហ៊ុនទាំងបីនេះ ក៏កំពុងបំពេញភារកិច្ចរបស់ខ្លួនបានយ៉ាងល្អផងដែរ ក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ដែលទទួលបានការសាទរពីប្រជាពលរដ្ឋយ៉ាងច្រើន។

### ២.៤.១.ក្រុមហ៊ុន ស៊ីនទ្រី

#### ២.៤.១.១.ប្រវត្តិ

ក្រុមហ៊ុន ស៊ីនទ្រី ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២ ដែលការចាប់ផ្តើមដំបូង គឺមានតែសេវាប្រមូលនិងដឹកជញ្ជូនសំរាមប៉ុណ្ណោះ។ ជាក្រុមហ៊ុនតែមួយដែលបានចាប់ផ្តើមធ្វើការប្រមូលសំរាមនៅទូទាំងរាជធានីភ្នំពេញ ចាប់តាំងពីឆ្នាំ២០០២ ដល់ឆ្នាំ២០២០។ តែបន្ទាប់ពីមានការធ្វើកំណែទម្រង់ក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹងមក និងបន្ទាប់ពីមានការដេញថ្លៃដើម្បីទទួលបានសិទ្ធិក្នុងការផ្តល់សេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹង មានក្រុមហ៊ុនពីរផ្សេងទៀតត្រូវបានចូលរួមក្នុងការផ្តល់សេវាដែរ។[16]

#### ២.៤.១.២. រចនាសម្ព័ន្ធ

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនស៊ីនទ្រី ក្នុងនោះមានការិយាល័យសរុបទាំងអស់ចំនួន០៥ ការិយាល័យ រួមមានការិយាល័យរដ្ឋបាល និងធនធានមនុស្ស ការិយាល័យហិរញ្ញវត្ថុ ការិយាល័យព័ត៌មានវិទ្យា ការិយាល័យសំអាតក្រុង ការិយាល័យយានដ្ឋាន និងផ្គត់ផ្គង់។[17]




[15] ប្រកាសលេខ ១១៩៩០ ប្រក ស្តីពីការបង្កើតរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងនៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ របស់ក្រសួងមហាផ្ទៃ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

[16] កិច្ចសម្ភាសន៍ លោក នៅ ឧត្តម អនុប្រធានប្រតិបត្តិនៃក្រុមហ៊ុនស៊ីនទ្រី ថ្ងៃទី២ មិថុនា ឆ្នាំ២០២២ នៅក្រុមហ៊ុន ស៊ីនទ្រី

[17] របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រុមហ៊ុន ស៊ីនទ្រី ទំព័រ១

**២.៤.១.៣. តួនាទី និងភារកិច្ច**

ក្រុមហ៊ុន ស៊ីនទ្រីមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ប្រមូល និងដឹកជញ្ជូនសំណល់ផ្ទះបាយ
- បោស និងលាងសម្អាតផ្លូវ
- ផ្សព្វផ្សាយ ណែនាំដល់ប្រជាពលរដ្ឋពីការញែក ការវេចខ្ចប់ ការទុកដាក់សំរាម និងលិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាសេចក្តីណែនាំផ្សេងៗ។[18]
- ក្រុមហ៊ុន CINTRI (Cambodia)/Everbright (China) នឹងត្រូវផ្តល់សេវា ក្នុងតំបន់ទី៣ ដែលមាន ០៤ខណ្ឌ គឺខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ។

**២.៤.១.៤. កម្មវិធីប្រមូលសំរាម**

**ក. ខណ្ឌកណ្តាលរាជធានី រួមមាន ខណ្ឌចំការមន ខណ្ឌបឹងកេងកង**

ប្រមូលជារៀងរាល់ថ្ងៃ នៅវេនយប់ ម៉ោងបញ្ចេញ ចាប់ពីម៉ោង ១៨:00 ដល់ម៉ោង ២១:00 និងម៉ោងប្រមូលចាប់ពីម៉ោង ២១:00 ដល់ម៉ោង៥ភ្លឺ(គ្របដណ្តប់វិសាលភាពវេនយប់ប្រមាណ ៩៥%)។ លើកលែងការប្រមូលតាមសួនច្បារ និងតំបន់ប្លុកជឿងហែមឬផ្លូវទាល់ ដែលប្រមូលវេនថ្ងៃ តាមកម្មវិធីដូចខាងក្រោម៖

- ទីតាំងសួនច្បារ៖ ប្រមូលចាប់ពីម៉ោង៦ព្រឹកតទៅ។
- ប្រភេទផ្លូវតូចៗ និងផ្លូវជឿងហែម ដែលរថយន្តមិនអាចចូលយកបាន៖ ម៉ោងបញ្ចេញ ១៩:00 ដល់ម៉ោង៦:00 ម៉ោងប្រមូល ចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង១៦:00។

**ខ. ខណ្ឌជាយរាជធានី រួមមាន ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ**

បានកំណែទម្រង់កម្មវិធីប្រមូលដូចខាងក្រោម៖

- ផ្លូវជាតិ និងផ្លូវធំ៖ ប្រមូលជារៀងរាល់ថ្ងៃ នៅវេនយប់ ម៉ោងបញ្ចេញ ចាប់ពីម៉ោង ១៨:00 ដល់ម៉ោង ២១:00 និងម៉ោងប្រមូលចាប់ពីម៉ោង ២១:00 ដល់ម៉ោង៥ភ្លឺ។
- ផ្លូវលំណប ឬផ្លូវតូច៖ ប្រមូល និងដឹកជញ្ជូនជារៀងរាល់០២ថ្ងៃ/ម្តង (កំណត់ថ្ងៃសេស និងថ្ងៃគូ) ម៉ោងបញ្ចេញសំរាម ចាប់ផ្តើមពីម៉ោង ១៩:00 ដល់ ៦:00 និងម៉ោងប្រមូលចាប់ពីម៉ោង ៨:00 ដល់ម៉ោង ១៦:00។

**២.៤.១.៥. គ្រឿងចក្រ ឧបករណ៍ និងកម្លាំងប្រតិបត្តិករ**

[18] កិច្ចសម្ភាសន៍ លោក នៅ ឧត្តម អនុប្រធានប្រតិបត្តិនៃក្រុមហ៊ុន ស៊ីនទ្រីថ្ងៃទី២ មិថុនា ឆ្នាំ២០២២ នៅក្រុមហ៊ុន ស៊ីនទ្រី ទំព័រ២

ក្រុមហ៊ុនមានប្រភេទគ្រឿងចក្រ និងឧបករណ៍ដូចជា រថយន្តគាបសំរាមប្រភេទ៥តោន ប្រភេទ៨តោនហ្វាស័រ រថយន្តបោស រថយន្តលាងផ្លូវ រថយន្តបែន រថយន្តដាំស្ទ័រ រទេះដឹកសំរាម ធុងដាំស្ទ័រ ប្រភេទ៥តោន ប្រភេទ ១០តោន ធុងសំរាម ម៉ូតូអាគុយប្រមូលសំរាម និងកង់បោស។[19]

**២.៤.១.៦.ចក្ខុវិស័យ**

ចង់ក្លាយជាក្រុមហ៊ុនប្រកួតប្រជែងដ៏ធំមួយ និងពង្រីកអាជីវកម្មរបស់ខ្លួនទៅទូទាំងប្រទេស ដើម្បីសម្រេចនូវចក្ខុវិស័យនេះក្រុមហ៊ុនមានវិធានការដូចជា៖

- អភិវឌ្ឍន៍ធនធានមនុស្ស
- បន្តធ្វើបច្ចុប្បន្នភាពគ្រឿងចក្រ។[20]

**២.៤.២. ក្រុមហ៊ុន** 800 Super-GAEA

**២.៤.២.១. ប្រវត្តិ**

ក្រុមហ៊ុន 800Super-GAEA គឺជាក្រុមហ៊ុន២ផ្សេងគ្នា។ ដែលក្រុមហ៊ុន GAEA គឺជាក្រុមហ៊ុនដែលមានដើមកំណើតនៅប្រទេសកម្ពុជា ចំណែកឯក្រុមហ៊ុន800Super មានដើមកំណើតមកពីប្រទេសសិង្ហបុរី។

ក្រុមហ៊ុន GAEA ចាប់ផ្តើមដំណើរការនៅឆ្នាំ២០០៧ ហើយផ្តល់សេវាខាងប្រមូលសំរាម និងបោសសម្អាតថ្នល់។ ធ្វើប្រតិបត្តិការនៅក្នុងក្រុងចំនួន៤ គឺក្រុងសិរីសោភ័ណ ក្រុងសៀមរាប ក្រុងស្ទឹងសែន និងក្រុងកំពត។

ចំណែកឯក្រុមហ៊ុន800Super គឺជាក្រុមហ៊ុនឈានមុខគេក្នុងការប្រមូលសំរាម និងកែច្នៃសំរាមនៅក្នុងប្រទេសសិង្ហបុរី។ បន្ទាប់ពីមានការបម្រែបម្រួល ដែលតម្រូវឱ្យជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមថ្មីនៅក្នុងរាជធានីភ្នំពេញក្រុមហ៊ុន800Super និងGAEAបានសហការគ្នាដើម្បីចូលរួមដេញថ្លៃក្នុងការទទួលបានសិទ្ធិប្រមូលសំរាម។ ហើយក៏ទទួលបានសិទ្ធិក្នុងការប្រមូលសំរាមជាមួយនឹងក្រុមហ៊ុនពីរផ្សេងទៀត ដែលទទួលបានអាជ្ញាប័ណ្ណធ្វើការប្រមូលរយៈពេល១០ឆ្នាំ ហើយចាប់ផ្តើមធ្វើប្រតិបត្តិការនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១។

**២.៤.២.២. រចនាសម្ព័ន្ធ**

រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន800Super/GAEA មាន៖

- CEO
- CEO Advisor
- ជំនួយការ CEO
- ផ្នែកប្រតិបត្តិការ
- ផ្នែកហិរញ្ញវត្ថុ

---

[19] របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រុមហ៊ុន ស៊ីនទ្រី ទំព័រ២

[20] កិច្ចសម្ភាសន៍ លោក នៅ ឧត្តម អនុប្រធានប្រតិបត្តិនៃក្រុមហ៊ុន ស៊ីនទ្រីថ្ងៃទី២ មិថុនា ឆ្នាំ២០២២ នៅក្រុមហ៊ុន ស៊ីនទ្រី

- ផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងបណ្តុះបណ្តាល និង
- ផ្នែកព័ត៌មានវិទ្យា។

**២.៤.២.៣. តួនាទី និងភារកិច្ច**

- ប្រមូលសំណល់ផ្ទះបាយ សំណល់តាមផ្ទះ ទៅតាមកាលវិភាគ និងទីកន្លែង
- សម្អាតផ្លូវថ្នល់ សួនច្បារសាធារណៈ សាលារៀន វត្តអារាម ប្រឡាយទឹក
- ដាក់ធុងសំរាមទៅតាមទីតាំងដែលចាំបាច់
- ចូលរួមកាត់បន្ថយសំរាមនៅក្នុងសហគម។
- ក្រុមហ៊ុន **800 Super/Global Action for Environment Awareness Public Limited** នឹងត្រូវផ្តល់សេវា ក្នុងតំបន់ទី១ ដែលមាន៥ខណ្ឌ គឺខណ្ឌទួលគោក ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ។

**២.៤.២.៤.កម្មវិធីបញ្ចេញសំរាម សំណល់រឹង**

**ក. សំរាមសើម**

ខណ្ឌកណ្តាលរាជធានីភ្នំពេញចំនួន០៥ រួមមានៈ ខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌបឹងកេងកងៈ ក្រុមហ៊ុននឹងប្រមូល ដឹកជញ្ជូនរៀងរាល់ថ្ងៃ នៅពេលយប់ ចាប់ពីម៉ោង៩ ដល់ម៉ោង៥ទាបភ្លឺ ដូច្នេះម៉ោងបញ្ចេញសំរាមមាន៣ម៉ោង គឺ៦-៩យប់។ បញ្ចេញសំរាមខុសពីម៉ោងនេះនឹងទទួលការផាកពិន័យ។

ខណ្ឌជាយរាជធានីចំនួន០៩ រួមមានៈ ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ ខណ្ឌដង្កោខណ្ឌព្រែកព្នៅ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូនដូចខាងក្រោមៈ

- ផ្លូវជាតិៈ ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ នៅពេលយប់ វេលាម៉ោង៩យប់ ដូច្នេះការបញ្ចេញសំរាមត្រូវចាប់ផ្តើមចន្លោះពីម៉ោង៦យប់ រហូតដល់ម៉ោង៩យប់
- ផ្លូវធំៈ ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ថ្ងៃ (ពេលថ្ងៃ វេលាម៉ោង៨ព្រឹក ឬពេលយប់ វាលាម៉ោង៩)
- ផ្លូវរណបៈ ត្រូវប្រមូល និងដឹកជញ្ជូនរៀងរាល់ ២ថ្ងៃ/១ម្តង (ពេលថ្ងៃ វេលាម៉ោង៨ព្រឹក ឬពេលយប់ វាលាម៉ោង៩។

**ខ. សំរាម សំណល់រឹងស្ងួត**

ក្រុមហ៊ុន និងប្រមូល និងដឹកជញ្ជូន ២ដង/១សប្តាហ៍ គឺនៅរៀងរាល់ថ្ងៃចន្ទ និងថ្ងៃសុក្រ។

**២.៤.២.៥. គ្រឿងចក្រ ឧបករណ៍ និងកម្លាំងប្រតិបត្តិការ**

ក្រុមហ៊ុនមានគ្រឿងចក្រ និងឧបករណ៍ដូចជារថយន្តប្រមូលសំរាមចំនួន ៧៤គ្រឿង រថយន្តដាំស្ទួរ ចំនួន ១៤គ្រឿង (ជួលបន្ថែមចំនួន ០៣គ្រឿង) រថយន្តលាងសម្អាតថ្នល់ចំនួន ០៥គ្រឿង ធុងសំរាមចំនួន ១៩១ធុង និងមានកម្លាំងប្រតិបត្តិការចំនួន៦៩៨នាក់។

**២.៤.២.៦. ចក្ខុវិស័យ**

ពង្រីកអាជីវកម្មទៅទូទាំង២៥រាជធានី ខេត្ត និងលើកកម្ពស់ការគ្រប់គ្រងសំរាមនៅកម្ពុជាដើម្បីឱ្យមានការប្រសើរឡើង។[21]

## ២.៥. ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញចោលសំរាម សំណល់រឹង

ការធ្វើកំណែទម្រង់នៃការគ្រប់គ្រងសំរាម និងសំណល់រឹង នៅរាជធានីភ្នំពេញ ចាប់ពីដើមខ្សែរហូតដល់ចុងខ្សែទទួលបានលទ្ធផលគួរជាទីមោទនៈ ក្នុងនោះការដេញថ្លៃជ្រើសរើសក្រុមហ៊ុនថ្មី ដើម្បីផ្តល់សេវាសម្អាតប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ក៏បានធ្វើរួចរាល់ផងដែរ ដែលកន្លងមក ក្រុមហ៊ុនចំនួន៣ ត្រូវបានជ្រើសរើស ហើយបានចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១។ ដើម្បីឱ្យការអនុវត្តប្រព័ន្ធថ្មីនៃការគ្រប់គ្រងសំរាម សំណល់រឹងរាជធានីភ្នំពេញ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រដ្ឋបាលភ្នំពេញ បានធ្វើការណែនាំអំពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងដែលមានចំណុចសំខាន់ៗដូចជា៖

- សំរាម និងសំណល់រឹងមុននឹងបញ្ចេញ ត្រូវសម្រិតទឹកចេញដាក់ចូលទៅក្នុងប្រព័ន្ធលូឱ្យបានត្រឹមត្រូវ
- ត្រូវញែកសំរាម សំណល់រឹង ជា២ប្រភេទ គឺសំរាមសើម និងសំរាមស្ងួត ដោយដាក់នៅក្នុងថង់ដាច់ដោយឡែកពីគ្នា៖
  - សំរាមសើម៖ សំណល់ម្ហូបអាហារ សំណល់សរីរាង្គ ផ្លែឈើ ផ្កា ត្រូវដាក់នៅក្នុងថង់ពណ៌ខ្មៅ
  - សំរាមស្ងួត៖ ក្រដាស ក្រដាសកាតុង ឡាំង គ្រឿងប្លាស្ទិក ហ្វូម ជ័រ ដែក កំប៉ុង ដប...ត្រូវដាក់នៅក្នុងថង់ពណ៌ស
- ហាមវេចខ្ចប់សំណល់ដែលបង្កគ្រោះថ្នាក់ ដូចជាអំបែងកញ្ចក់ និងសំណល់មុតស្រួចនានា លាយឡំជាមួយសំរាមសើម និងសំរាមស្ងួត
- ថង់សំរាម សំណល់រឹង ត្រូវចងមាត់ឱ្យបានជិតត្រឹមត្រូវ និងមិនត្រូវរហែកឡើយ
- ត្រូវទុកដាក់សំរាម សំណល់រឹងរបស់ខ្លួនឱ្យបានត្រឹមត្រូវទៅតាមទីកន្លែងដែលបានកំណត់

[21] កិច្ចសម្ភាសន៍ អ្នកស្រី រ៉ែន សារួម ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងបណ្តុះបណ្តាល នៃក្រុមហ៊ុន 800 ស៊ូគើ-ហ្កា-អ៊ី.យ៉ា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ នៅ White Coffee ទួលគោក

- ហាមចោលសំរាម សំណល់រឹងនៅមាត់អណ្តូងលូ ប្រឡាយ តាមទីសាធារណៈ និងតាមអាងស្តុកទឹក និងហាមដុតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញជាកំហិត
- ចំពោះសំណល់ដើមឈើ និងមែកឈើត្រូវដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ
- ចំពោះសំណល់សំណង់ អាចម៍ដី កំទេចថ្ម ខ្សាច់...ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ
- ចំពោះសំណល់ជាគ្រឿងសង្ហារឹម គ្រឿងអេឡិចត្រូនិក គ្រឿងអគ្គីសនី សំបកកង់ និងវត្ថុកែច្នៃឡើងវិញ បានត្រូវទុកដាក់ដោយឡែកឲ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ។[22]

[22] សេចក្តីណែនាំ លេខ ០២៥/២១ សណន.ស ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងរាជធានីភ្នំពេញ របស់រដ្ឋបាលរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. សមិទ្ធផលរបស់អង្គភាព

### ៣.១.១. សមិទ្ធផលរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ

សមិទ្ធផលរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងមានដូចជា៖

- គុណភាពនៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនបានប្រសើរជាងមុន
- ការបង់ថ្លៃសេវាមានភាពងាយស្រួលជាងមុន ដោយបានកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងថ្មី ដែលប្រព័ន្ធនឹងផ្តល់ភាពងាយស្រួល និងអត្ថប្រយោជន៍ ដូចជាការទូទាត់ថ្លៃសេវាសំរាមបានឆាប់រហ័ស ការគ្រប់គ្រងទិន្នន័យអតិថិជន ការធ្វើស្វ័យប្រកាស ការស្នើ/ការផ្លាស់ប្តូរសេវាសំរាម ការរាយការណ៍ពីភាពយឺតយ៉ាវរបស់ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូន ការទទួលព័ត៌មាន និងការស្នើសុំផ្សេងៗពាក់ព័ន្ធនឹងសេវាសំរាមតាមរយៈប្រព័ន្ធsoftwareនិងMobile Application
- បរិស្ថានស្អាតជាងមុន មានសុខមាលភាពសាធារណៈ និងសោភ័ណភាពរាជធានី។[23]
- ទីលានចាក់សំរាមមានភាពប្រសើរជាងមុន។ ទីលានចាក់សំរាមដង្កោ បានទទួលគម្រោងកែប្រែហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងបរិក្ខារ។ ទីលាននេះក៏បានពង្រឹងកិច្ចប្រតិបត្តិការបច្ចេកទេសក្នុងការឈូសឆាយ និងទុកដាក់សំរាម សំណល់រឹង។ ដំណើរការប្រតិបត្តិនៅទីលានមានភាពល្អប្រសើរដោយចរន្តនៃការចូលចាក់សំរាមមានប្រក្រតីភាពធម្មតា ដោយមិនមានការកកស្ទះនោះទេ។[24]

### ៣.១.២.សមិទ្ធផលរបស់ក្រុមហ៊ុន ស៊ីនទ្រី

**ក.ការបំបាត់ដេប៉ូសំរាមអនាធិបតេយ្យ**

ការលុបបំបាត់ដេប៉ូសំរាមអនាធិបតេយ្យ គឺជាផែនការយុទ្ធសាស្ត្រចម្បងដ៏សំខាន់មួយរបស់ក្រុមហ៊ុនក្នុងគោលបំណងបំបាត់ទាំងស្រុងនូវគំនរសំរាម ឬដេប៉ូសំរាម ក្នុងតំបន់៣ ដែលក្រុមហ៊ុនបានដេញថ្លៃឈ្នះ។ ជាលទ្ធផលយើងបានលុបបំបាត់ទាំងស្រុង ហើយពុំមានដេប៉ូសំរាមអនាធិបតេយ្យរ៉ាំរ៉ៃមានវត្តមានក្នុងតំបន់០៣ (ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ) ទៀតឡើយចាប់ពីឆ្នាំ២០២១នេះទៅ។

**ខ.តំបន់សេវាថ្មី និងការពង្រីកសេវាបន្ថែម**

[23] កិច្ចសម្ភាសន៍ លោក នួន សំណារុធ នាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន និងជា អភិបាលរដ្ឋាករស្វយ័ត គ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២

[24] របាយការណ៍ស្តីពីវឌ្ឍនភាពនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជននៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែ ធ្នូឆ្នាំ២០២១

ក្នុងគោលបំណងអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយតាមកិច្ចសន្យាថ្មីរវាង ក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា) និង រដ្ឋបាលរាជធានីភ្នំពេញ ក្រុមហ៊ុនបានគ្របដណ្តប់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម បាន១០០% ស្មើនឹង២៧សង្កាត់ ក្នុងតំបន់០៣ (ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ)។ បើទោះបីជាហេដ្ឋារចនាសម្ព័ន្ធផ្នែកខ្លះនៃសង្កាត់ព្រែកថ្មី និងសង្កាត់ក្បាលកោះ នៃខណ្ឌច្បារអំពៅ នៅមានបញ្ហាប្រឈមក្តីក៏ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម បាន១០០%។

**គ.កម្មវិធីគម្រោងការលើកកម្ពស់ ការយល់ដឹងសាធារណៈ**

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានីភ្នំពេញលេខ 075/21 PPCH ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ ក្រុមហ៊ុនបានចាប់ផ្តើមអនុវត្តគម្រោងខាងលើចាប់ពីខែវិច្ឆិកា រហូតដល់បច្ចុប្បន្នដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- រៀបចំសិក្ខាសាលាអប់រំក្រោមប្រធានបទ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងចំនួន៤ដង គិតចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១។
- កម្មវិធីចុះចែក Sticker កម្មវិធីប្រមូលសំរាម ខិតប័ណ្ណអប់រំ និងថង់គំរូ ចំនួន៤ដង គិតចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១។
- ចូលរួមក្នុងទិវាបរិស្ថានជាតិ និងបានចែកថង់គំរូដល់អ្នកចូលរួមចំនួន១ដង គិតចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១។
- ប្រារព្ធយុទ្ធនាការសម្អាតបរិស្ថាន និងធ្វើអនាម័យលើមហាវិថីសម្តេច តេជោ ៦០ម និងផ្សព្វផ្សាយ ស្តីពីកម្មវិធីសម្អាត និងប្រមូលចំនួន១ដង គិតចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១។
- បង្កើតក្រុមការងារដោះស្រាយបញ្ហារបស់អតិថិជនតាមប្រព័ន្ធបណ្តាញសង្គម Facebook Telegram។

**ឃ.សកម្មភាពការងារផ្សេងៗជាមួយអាជ្ញាធរមូលដ្ឋាន**

- សហការជាមួយអាជ្ញាធរមូលដ្ឋានតាមខណ្ឌនីមួយៗ

ចុះសហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំខណ្ឌនីមួយៗដើម្បីអនុវត្តនូវភារកិច្ច៖

- ផ្សព្វផ្សាយពីកម្មវិធីសម្អាត ប្រមូល និងដឹងជញ្ជូនសំរាមដល់ផ្ទះប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ និងអាជីវករ សេវាករ ឱ្យចេះញែក វេចខ្ចប់ និងទុកដាក់សំរាម ឱ្យបានត្រឹមត្រូវតាមម៉ោងពេល និងទីកន្លែងកំណត់ ឬតាមរូបភាពឃោសនាតាមឃោសនាសព្ទ ឬចែកខិតប័ណ្ណ អប់រំតាមលំនៅដ្ឋាន និងនៅតាមទីតាំងមួយចំនួនដូចជាទីផ្សារ ចំណតរថយន្ត កន្លែងកម្សាន្ត សួនច្បារ និងតាមភោជនីយដ្ឋាន

- ចុះពិនិត្យមើលទីតាំងគំនរសំរាម ដែលប្រជាពលរដ្ឋបោះចោលខុសម៉ោងពេលកំណត់ និងគំនរសំរាមគរសល់ជាយូរមកហើយនៅតាមដងផ្លូវសាធារណៈ
- ទទួលខុសត្រូវថែរក្សាការពារទីតាំងដេប៉ូសំរាមដែលបានសម្អាតរួចកុំឱ្យកើតមានឡើងវិញ
- ការរៀបចំផែនការបុណ្យជាតិធំៗ។

ចាប់តាំងពីខែកក្កដា រហូតដល់ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុនបានរៀបចំផែនការ និងអនុវត្តការសម្អាត ប្រមូល និងដឹងជញ្ជូនបានយ៉ាងជោគជ័យ ដោយរួមមានពិធីបុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យអុំទូក និងពិធីបុណ្យឆ្លងឆ្នាំសកល ដោយមិនមានការកកស្ទះសំរាម ឬគំនរសំរាម តាមបណ្តាមហាវិថីសំខាន់ៗ ឬផ្លូវតូចៗនោះឡើយ។ ការជោគជ័យនេះគឺអាស្រ័យលើការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរតាមមូលដ្ឋានផងដែរ ក្នុងការសហការ និងសម្រួលគ្នាទៅវិញទៅមក។

**ង.ការចូលរួមការងារសង្គម និងការងារខាងក្រៅ**

- ក្រុមហ៊ុនបានសហការជាមួយនឹងសាលាខណ្ឌ និងមន្ទីរបរិស្ថានខណ្ឌ៖

ចុះធ្វើទិវាបរិស្ថាន ដោយដាក់កម្លាំង និងគ្រឿងចក្រធ្វើការបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមតាមតំបន់កខ្វក់ខ្លាំង តំបន់មានដេប៉ូសំរាមអនាធិបតេយ្យ ដែលបងប្អូនប្រជាពលរដ្ឋបញ្ចេញសំរាមខុសកម្មវិធីប្រមូល ដើម្បីធ្វើការពញ្ញាក់អារម្មណ៍ ដ៏ដូចជាការដាស់តឿន អប់រំទៅដល់បងប្អូនប្រជាពលរដ្ឋ ស្តីអំពីការទុកដាក់សំរាម និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធី។

- ក្រុមហ៊ុនបានចាត់ចែងបុគ្គលិកកម្មករធ្វើពលកម្ម ចាំងស្មៅតាមចិញ្ចើមផ្លូវ ចូកដី ប្រមូលសំរាមតាមប្រឡាយទឹក និងបោសសម្អាតតាមច្រាំងទន្លេ (មុខកោះពេជ្រ) បន្ថែមពីលើតួនាទីភារកិច្ច ក្នុងគោលបំណងចូលរួមចំណែកលើកកម្ពស់អនាម័យបរិស្ថាន សុខមាលភាពសាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ ឱ្យកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។
- ក្រុមហ៊ុនបានចូលរួមប្រជុំជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងជាមួយរដ្ឋបាលខណ្ឌទាំង០៤ ចំនួនប្រហែល៤០លើក (ប្រជុំតាម Zoom និងប្រជុំផ្ទាល់)។[25]

**៣.១.៣. សមិទ្ធផលរបស់ក្រុមហ៊ុន** 800Super/GAEA

ក្រុមហ៊ុន 800Super/GAEAទទួលបានសមិទ្ធផលដូចជា៖

- មានសមត្ថភាពអាចចាប់ផ្តើមបាន
- ប្រមូលសំរាមពីតិច រហូតទៅដល់ចំណុចដែលបានគ្រោងទុក
- សមត្ថភាពបុគ្គលិកមានសមត្ថភាពជាងមុន

[25] របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រុមហ៊ុន ស៊ីនទ្រី ទំព័រ៦

- សម្អាតបានច្រើនទីតាំងជាងមុន
- បានផ្សព្វផ្សាយ ដល់ប្រជាជនពីបញ្ហាសំរាម
- ប្រមូលសំណល់ដែលសល់ពីឆ្នាំមុនៗសំណល់សល់បានច្រើនទីតាំង។[26]

## ៣.២.បញ្ហាប្រឈមរបស់អន្តភាព

### ៣.២.១.បញ្ហាប្រឈមរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង

ទន្ទឹមនឹងលទ្ធផលដែលទទួលបាន រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញបានជួបប្រទះនូវបញ្ហាមួយចំនួន ដូចខាងក្រោមៈ

១. ប្រជាពលរដ្ឋមួយចំនួនតូចនូវបន្តលួចបញ្ចេញ ឬចោលសំរាម ខុសកម្មវិធី និងទីកន្លែងកំណត់

២. សន្ទុះនៃការបង់ថ្លៃប្រមូលសំរាមរបស់អតិថិជននៅមានកម្រិតទាបនៅឡើយ បានប្រមាណជា៣០% នៃទីតាំងទាំងអស់នៅរាជធានីភ្នំពេញ។ យើងអាចដឹងពីលេខសម្គាល់អតិថិជន (ID) ដែលខកខានក្នុងការបង់ ប៉ុន្តែពិបាកក្នុងការចុះរកទីតាំងនោះ គឺត្រូវចំណាយពេលយូរ ដោយមូលហេតុពុំមានព័ត៌មានគ្រប់គ្រាន់ និងព័ត៌មានដែលមានមិនបានធ្វើបច្ចុប្បន្នភាព ព្រោះទិន្នន័យទាំងអស់ គឺផ្អែកលើទិន្នន័យចាស់របស់អគ្គីសនីកម្ពុជា

៣. ចំពោះទីតាំងធំៗ ដែលមន្ត្រីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង ចុះស្រង់ព័ត៌មាន គឺការចូលរួមសហការនៅមានកម្រិតទាប ធ្វើឲ្យមានផលវិបាកក្នុងការកំណត់ថ្លៃសេវាថ្មី។

៤. ប្រជាពលរដ្ឋចង់បានការផ្តល់សេវាល្អស្អាត ប៉ុន្តែឆន្ទៈចូលរួមបង់ថ្លៃសេវាសំរាម នៅមានកម្រិតទាប។[27]

### ៣.២.២.បញ្ហាប្រឈមរបស់ក្រុមហ៊ុន ស៊ីនទ្រី

ក្នុងពេលប្រតិបត្តិការសម្អាត ប្រមូល និងដឹងជញ្ជូនសំរាម ក្រុមហ៊ុនបានជួបបញ្ហាលំបាកជាច្រើនក្នុងការគ្រប់គ្រងកាកសំណល់រឹងក្នុងរាជធានីភ្នំពេញឱ្យមានប្រសិទ្ធភាព បញ្ហាសំខាន់ៗទាំងអស់នោះរួមមានៈ

- ផ្ទះជួល បន្ទប់ជួល មិនមានទីតាំងសម្រាប់ទុកដាក់សំរាមត្រឹមត្រូវ
- អ្នកលក់ដូរចល័តលួចយកសំរាមទៅបោះចោលតាមដីឡូតិ៍ទំនេរ និងដីឯកជន បង្កើតជាដេប៉ូសំរាមអនាធិបតេយ្យ
- ការដ្ឋានសាងសង់មួយចំនួនធំគ្មានការវេចខ្ចប់សម្ភារៈ សំណល់សំណង់ឱ្យបានត្រឹមត្រូវ និងមិនទាន់យល់ដឹងពីការចោលសំរាមប្រភេទសំណល់នៅឡើយ
- ផ្លូវធំភាគច្រើនត្រូវប្រមូលសំរាមចេញខុសកម្មវិធី ពីរដងទៅបីដងក្នុងមួយថ្ងៃ

[26] កិច្ចសម្ភាសន៍ អ្នកស្រី រ៉ន សារួម ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងបណ្តុះបណ្តាល នៃក្រុមហ៊ុន 800 ស៊ូភើ-ហ្កា-អ៊ី.យ៉ា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ នៅ White Coffee ទួលគោក

[27] របាយការណ៍ស្តីពីវឌ្ឍនភាពនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជននៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែ ធ្នូឆ្នាំ២០២១

- គ្មានទីតាំងសម្រាប់ផ្ទុកធុងដាំស្វ័រ ជាផលវិបាកក្នុងការទុកដាក់សំរាមរបស់រទេះ ដែលបានប្រមូលសំរាមបញ្ចេញខុសម៉ោង ឬខុសកម្មវិធីប្រមូល និងរទេះដែលអូសសំរាមចេញពីផ្លូវជឿងហែម
- បញ្ហាអេតចាយកាយ និងការហែកស្បោងសំរាម ធ្វើឱ្យសំរាមរាយប៉ាយខុសសភាពដើម និងគ្មានសណ្តាប់ធ្នាប់
- ផ្សារមួយចំនួននៅមិនទាន់មានកន្លែងទុកដាក់សំរាម និងមិនទាន់មានធុងដាំស្វ័រសំរាមផ្ទុកសំរាម (សំរាមផ្សារ) ដែលធ្វើឱ្យសំរាមនៅតែបន្តចោលនៅមុខផ្សារ ឬផ្លូវក្បែរផ្សារ
- បញ្ហាចរាចរយានយន្តគ្មានសណ្តាប់ធ្នាប់សងខាងផ្លូវ ធ្វើឱ្យប៉ះពាល់ដល់ការបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ជាពិសេសការប្រមូលសំរាមវេនយប់ក្នុងខណ្ឌបឹងកេងកង និងខណ្ឌចំការមន
- ហេដ្ឋារចនាសម្ព័ន្ធផ្លូវមួយចំនួននៅតាមជាយក្រុងនៅមានកម្រិត ដែលបង្កបញ្ហាលំបាកដល់ផ្នែកសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម (តូចចង្អៀត មានខ្សែភ្លើងរញ៉េរញ៉ៃ លិចទឹកនៅរដូវវស្សា)
- ពេលយប់អ្នកបើកបរ (សំដៅដល់អ្នកចេញមកពីតាមក្លឹបផ្សេងៗ) ស្រវឹងច្រើន ដែលបង្កគ្រោះថ្នាក់ដល់កម្មករ ដែលកំពុងបម្រើការ
- ធុងសំរាម និងរទេះអូសសំរាម ដែលបានដាក់នៅតាមសួនច្បារ និងទីសាធារណៈ ត្រូវបានជនខិលខូចវាយបំផ្លាញ និងលួចៗ[28]

**៣.២.៣.បញ្ហាប្រឈមរបស់ក្រុមហ៊ុន**800 Super/GAEA

- ប្រជាជនមិនទាន់យល់ពីការញែកសំរាម ការវេចខ្ចប់ និងការទុកដាក់សំរាម
- ប្រជាជនបោះសំរាមពាសវាលពាសកាល
- ប្រជាពលរដ្ឋបញ្ចេញសំរាមខុសម៉ោង និងថ្ងៃដែលឡានទៅយក
- ការដុតសំរាមដោយខ្លួនឯង
- បញ្ហាសំរាមអនាធិបតេយ្យពិបាកក្នុងការប្រមូលត្រូវចំណាយកម្លាំង ពេលវេលាយូរ និងធនធានច្រើន
- ផ្លូវតូចចង្អៀត ប្រឡាយ មាត់ទន្លេពិបាកប្រមូល ដែលសុទ្ធតែជាកន្លែងពិបាកប្រមូល
- បញ្ហាបច្ចេកទេសគ្រឿងចក្រ
- កង្វះធនធានដែលមានចំណេះដឹងលើជំនាញៗ[29]

## ៣.៣. បញ្ហាប្រឈមនៃលទ្ធផលសិក្សា

### ៣.៣.១.បញ្ហាប្រឈមនៃការសិក្សាទ្រឹស្តី

[28] របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រុមហ៊ុន ស៊ីនទ្រី ទំព័រ៩

[29] កិច្ចសម្ភាសន៍ អ្នកស្រី រ៉ន សារួម ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងបណ្តុះបណ្តាល នៃក្រុមហ៊ុន 800 ស៊ូភើ-ហ្គា-អ៊ី.យ៉ា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ នៅ White Coffee ទួលគោក

- យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង មាត្រា៧ បានចែងថា ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។ តែបើចំពោះទិដ្ឋភាពជាក់ស្តែងវិញ គឺមានប្រជាពលរដ្ឋមួយចំនួននៅតែបន្តបោះ និងចាក់ចោលសំរាមនៅទីសាធារណៈ ដូចជាតាមចិញ្ចើមថ្នល់ ក្នុងទឹក និងសួនច្បារជាដើម ដែលវាផ្ទុយទៅនឹងមាត្រាដែលចែងនៅក្នុងអនុក្រឹត្យនេះ។
- យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មាត្រា១៥ បានចែងថា ម្ចាស់សំរាមសំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុងស្រុក ខណ្ឌ។ តែចំពោះការអនុវត្តជាក់ស្តែងប្រជាពលរដ្ឋមិនបានធ្វើការញែកសំរាមឱ្យដាច់ពីគ្នានោះទេ ដោយដាក់សំរាម សំណល់រឹងទាំងអស់នៅលាយឡំគ្នា ហើយការវេចខ្ចប់ទៀតសោតក៏មិនបានត្រឹមត្រូវផងដែរ។
- យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មាត្រា១៦ បានចែងថា ម្ចាស់សំរាមសំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាមសំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុកខណ្ឌ។ ទោះជាយ៉ាងណាក៏ដោយក្នុងការអនុវត្តជាក់ស្តែងមានប្រជាពលរដ្ឋមួយចំនួននៅតែធ្វើការវេចខ្ចប់មិនបានល្អ ដែលនាំឱ្យមានការធ្លាយថង់ និងបញ្ចេញនូវក្លិនស្អុយ ក៏ដូចជាទឹកកខ្វក់ដែលចេញពីសំរាម។ ប្រការនេះ ធ្វើឱ្យប៉ះពាល់ដល់សុខភាព បរិស្ថាន និងមានការពិបាកក្នុងការប្រមូលសំរាម សំណល់រឹង។
- យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មាត្រា១៧ វាក្យខណ្ឌ១បានចែងថា ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលវេលាម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។ បើសង្កេតមើលជាក់ស្តែងមានប្រជាពលរដ្ឋមួយចំនួនមិនបានរក្សាទុកសំរាមឱ្យបានត្រឹមត្រូវទេ តែគឺយកទៅបោះចោលនៅតាមទីសាធារណៈដូចជាចិញ្ចើមថ្នល់ ដីដែលទំនេរជាដើម។ ហើយចំពោះការបញ្ចេញសំរាមវិញ គឺមានប្រជាពលរដ្ឋមួយចំនួនមិនបានបញ្ចេញសំរាមទៅតាមពេលដែលបានកំណត់ ដែលធ្វើឱ្យអ្នកប្រមូលត្រូវធ្វើការប្រមូលពីរ ទៅបីដង។

- យោងតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មាត្រា១៧ ចែងថា ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុកខណ្ឌ។ ជាក់ស្ដែង គឺនៅតែមានប្រជាពលរដ្ឋមិនបានបង់ថ្លៃសំរាមជាច្រើន ដោយប្រជាពលរដ្ឋមួយចំនួនបានយកលេសថា ថ្លៃសំរាមមានតម្លៃថ្លៃ និងខ្លះទៀតក៏មិនបានដឹងពីការបង់ថ្លៃសេវា។
- យោងតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មាត្រា១៩ វាក្យខណ្ឌ៣បានចែងថា រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងនៅក្នុងកថាខ័ណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។ ទោះជាយ៉ាងណាក៏ដោយនៅពេលបច្ចុប្បន្នការផ្សព្វផ្សាយនេះ នៅតែមិនទាន់បានទូលំទូលាយនៅឡើយ ដោយប្រជាពលរដ្ឋនៅតែមិនទាន់ដឹង ឬមិនទាន់យល់ច្បាស់ពីដីកា និងលិខិតបទដ្ឋានទាំងនេះដែលធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋនៅមានចំនួនតិចតួចនៅឡើយ។

### ៣.៣.២. លទ្ធផលនៃការសម្ភាសន៍អ្នកជំនាញ

- បុគ្គលទី១៖ តាមរយៈកិច្ចសម្ភាសន៍ គាត់បាននិយាយថា នៅតំបន់ដែលគាត់រស់នៅ ការគ្រប់គ្រងសំរាមសំណល់រឹង គឺមានភាពល្អប្រសើរច្រើន។ ដោយការវេចខ្ចប់សំរាមបានជិតល្អ ការទុកដាក់សំរាមក៏បានត្រឹមត្រូវ ហើយធុងសំរាមក៏មានចំនួនគ្រប់គ្រាន់។ ហើយចំពោះរថយន្តដែលមកប្រមូលសំរាមវិញក៏ត្រូវទៅតាមពេលវាលា គឺពីរទៅបីថ្ងៃមកយកម្ដង។

  គាត់បាននិយាយថាពេលខ្លះសឹងតែគ្មានសំរាម ដើម្បីឱ្យប្រមូលដោយសារតែការប្រមូលបានទៀងពេលវេលា និងស្អាតល្អ។ គាត់ក៏បានបន្តទៀតថា នៅទីតាំងដែលគាត់ជួលផ្ទះឱ្យគេនៅ ក៏មានភាពល្អប្រសើរ ព្រោះថាគាត់បានរៀបចំដាក់ធុងសំរាមបានត្រឹមត្រូវ និងតម្រូវឱ្យអ្នករស់នៅទីនោះមានថង់ដើម្បីវេចខ្ចប់សំរាម សំណល់រឹង។

  គាត់នៅបន្តទៀតថា បន្ទាប់ពីមានការដេញថ្លៃដើម្បីជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមថ្មី និងមានការបែងចែងតំបន់ក្នុងការប្រតិបត្តិការ គាត់ឃើញថា ការប្រមូលមានភាពប្រសើរជាងមុនច្រើន ដោយឡានប្រមូលសំរាមមកយកសំរាមបានទៀងពេលវេលា និងមិនមានសំរាមសល់។
- បុគ្គលទី២៖ បាននិយាយថា ការវេចខ្ចប់សំរាម ត្បិតតែស្ដាប់ទៅងាយស្រួល ប៉ុន្ដែវាពិបាកនៅក្នុងការបែងចែកទៅតាមប្រភេទសំរាម។ការដែលមិនទាន់មានមូលដ្ឋានគ្រឹះក្នុងការបែងចែកសំរាមទៅតាម

ប្រភេទរបស់ប្រជាជននេះហើយ ដែលជាកត្តារាំងស្ទះនៅការរក្សាសណ្តាប់ធ្នាប់ទីក្រុងឱ្យបានស្អាត រួមទាំងអនាម័យ។ គាត់បានបន្តថា សម្រាប់ខ្លួនគាត់ផ្ទាល់គាត់បានយល់ដឹងពីការញែក និងការវេចខ្ចប់សំរាមទៅតាមប្រភេទតាមការណែនាំហើយ។

តែគាត់នៅតែបានសង្កេតឃើញថាមានប្រជាជនដែលមិនទាន់បានធ្វើការញែក វេចខ្ចប់និងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។ គាត់បន្ថែមថា មូលហេតុដែលនៅតែបែបនេះ ទីមួយ គឺមកពីកត្តាប្រជាជនខ្លួនឯង ដែលមិនបានយកចិត្តទុកដាក់ និងចូលរួមតាមដានព័ត៌មានដែលទាក់ទងទៅនឹងសំរាម សំណល់រឹង មិនថាអាជ្ញាធរមានសមត្ថកិច្ច ឬក៏ក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយ ណែនាំយ៉ាងណាក៏ប្រជាពលរដ្ឋមិនបានយកចិត្តទុកដាក់។

គាត់នៅបន្ថែមទៀតថា កត្តាទីពីរ គឺបណ្តាលមកពីការផ្សព្វផ្សាយមិនបានទូលំទូលាយ ដែលភាគច្រើនការផ្សព្វផ្សាយមិនបានទៅដល់ប្រជាជនដែលមិនមានបណ្តាញសង្គមប្រើប្រាស់ និងប្រជាជនដែលមានជីវភាពលំបាក។ ជាធម្មតា ការប្រមូលសំរាមនៅមូលដ្ឋានដែលខ្ញុំរស់នៅ ខ្ញុំសង្កេតឃើញថា ច្រើនតែមកប្រមូលពេលថ្ងៃត្រង់ និងពេលល្ងាចរៀងរាល់ថ្ងៃ ក៏ប៉ុន្តែក៏មានថ្ងៃខ្លះខកខានផងដែរ។ តាមការសង្កេតជាទូទៅការប្រមូលសំរាមសព្វថ្ងៃថ្មីត្បិតតែមានភាពល្អប្រសើរឡើងបន្តិចក្តី ក៏ប៉ុន្តែបើនិយាយពីការបន្តចោលរបស់អ្នកប្រើប្រាស់ទូទៅនៅតែមាន ជាពិសេសការចោលសំរាមមិនត្រូវនឹងទីតាំងដែលក្រុមហ៊ុនប្រមូលសំរាមត្រូវប្រមូល បូករួមទាំងការទុកដាក់ និងវេចខ្ចប់មិនបានល្អ ត្រឹមត្រូវផងដែរ។

យើងបានឃើញជាករណីជាក់ស្តែង ដែលសំរាមបន្តមាននៅតាមសួនច្បារ សំរាមអណ្តែតនៅតាមមាត់ទន្លេ ក្រោមស្ពាន។ អ្វីដែលលើសពីនេះទៅទៀត ភាពមានចេតនាក្នុងការចោលសំរាមយ៉ាងអត់សណ្តាប់ធ្នាប់របស់អ្នកប្រើប្រាស់ទូទៅ ដូចជា ករណីដែលការពិសាភេសជ្ជៈដប ឬកំប៉ុងរួចហើយបោះចោលតាមដងផ្លូវ ការពិសាបារីរួច បោះចោលយ៉ាងរប៉ាត់រប៉ាយជាដើម។ ទង្វើបែបនេះ នៅតែជាបញ្ហាប្រឈមដល់អនាម័យសង្គម។

- ❖ បុគ្គលទី៣៖ តាមរយៈកិច្ចសម្ភាសន៍ គាត់បានលើកឡើងថា ការទុកដាក់សំរាមនៅពេលបច្ចុប្បន្ននៅមិនទាន់មានភាពល្អប្រសើរនោះទេ បើទោះបីមានក្រុមហ៊ុនដេញថ្លៃប្រមូលសំរាមក៏ដោយ ការប្រមូលសំរាមនៅមានភាពយឺតយ៉ាវមិនទៀងទាត់ដោយពេលខ្លះឃើញមកប្រមូលនៅពេលព្រឹក ថ្ងៃខ្លះប្រមូលនៅពេលរសៀលជាដើម មិនតែប៉ុណ្ណោះមិនទាន់ញែកសំរាមបានល្អ ដោយការប្រមូលសំរាមដាក់ចូលគ្នានៅរថយន្តដឹកសំរាមតែមួយ ដោយគ្មានការបែងចែកសំរាមទៅតាមប្រភេទនៃសំរាមនោះទេ។

គាត់បានបន្តដដែលទៀតថា ការប្រមូលសំរាមនៅមិនទាន់មានប្រសិទ្ធភាពល្អប្រសើរនោះទេ ដោយពេលខ្លះការប្រមូលសំរាមមានការធ្លាក់រប៉ាត់រប៉ាយនៅតាមដងផ្លូវក៏មាន។ បន្ថែមពីលើនេះទៅទៀត បញ្ហានៃការទុកដាក់សំរាមមិនបានត្រឹមត្រូវនេះ វាមិនមែនជាកំហុសរបស់ក្រុមហ៊ុនទទួលប្រមូលសំរាមតែម្ខាងនោះទេ គឺវាក៏មានការចូលរួមពីប្រជាពលរដ្ឋផងដែរ។

តាមការសង្កេតឃើញរបស់ខ្ញុំប្រជាពលនៅមិនទាន់មានភាពសហការប៉ុន្មាននោះទេ នៅក្នុងការទុកដាក់ និងញែកសំរាមឱ្យបានត្រឹមត្រូវ ថែមទាំងពេលខ្លះខ្ញុំសង្កេតឃើញថា ពួកគាត់បានចោលសំរាមពាសវាលពាសកាលទៀតផង ទាំងអស់នេះជាកត្តាមួយធ្វើឱ្យការគ្រប់គ្រងសំរាមមិនបានល្អ បំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធ និងប៉ះពាល់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្ត ទៀតផង។

### ៣.៣.៣. លទ្ធផលនៃការសម្ភាសន៍ក្រុមគោលដៅ

**ក. កិច្ចសម្ភាសន៍ក្រុមហ៊ុន800Super/GAEA**

តាមរយៈកិច្ចសម្ភាសន៍ អ្នកស្រី រ៉ន សារួម ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងបណ្តុះបណ្តាលនៃក្រុមហ៊ុន 800Super/GAEA គាត់បានមានប្រសាសន៍ថា បញ្ហាប្រឈមខ្លាំងដែលទាក់ទងទៅនឹងការប្រមូលសំរាម គឺចំណេះដឹងរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងសំរាមនៅមានកម្រិតនៅឡើយ គឺប្រជាជនមិនបានញែកសំរាមដោយបានដាក់សំរាមគ្រោះថ្នាក់លាយជាមួយសំណល់ផ្ទះបាយ ការបោះសំរាមចោលពាសវាលពាសកាល គ្មានការទុកដាក់ឱ្យបានត្រឹមត្រូវ ការបញ្ចេញសំរាមខុសពេលវេលា ព្រមទាំងការដុតសំរាមដោយខ្លួនឯង ដែលនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថាន។

គាត់បានបន្តថា ក្រុមហ៊ុនក៏បានធ្វើការចុះផ្សាយ ណែនាំពីការញែក ការវេចខ្ចប់ ការទុកដាក់សំរាម និងកាលវិភាគនៃការប្រមូលសំរាម តាមសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ។ ប៉ុន្តែគាត់បានបន្ថែមថា ជួនកាលយើងបានផ្សព្វផ្សាយនៅផ្លូវនោះរួចហើយ ហើយឡានប្រមូលសំរាមបានទៅប្រមូលសំរាមនៅទីតាំងនោះ តែបន្ទាប់ពីប្រមូលរួចហើយ គាត់បានយកសំរាមថ្មីមកទៀត។ គាត់បាននិយាយបន្តថា ប្រជាពលរដ្ឋមិនបានភ្ញាក់រលឹកថា ការបញ្ចេញសំរាមមិនបានត្រឹមត្រូវ និងខុសពេលវេលាធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់ផ្លូវថ្នល់។

**ខ. កិច្ចសម្ភាសន៍ក្រុមហ៊ុនស៊ីនទ្រី**

តាមរយៈការសម្ភាសន៍លោក នៅ ឧត្តម អនុប្រធានការិយាល័យប្រតិបត្តិនៃក្រុមហ៊ុន ស៊ីនទ្រី គាត់បានមានប្រសាសន៍ថា ភាគច្រើននៅពេលដែលយើងឃើញសំរាមតាមផ្លូវ ឬតាមប្រឡាយ អ្នកដែលយើងបន្ទោសមុនគេ គឺរដ្ឋាភិបាល ឬក្រុមហ៊ុនប្រមូលសំរាម។ គាត់បានចោទជាសំនួរថា ហេតុអ្វីត្រូវបន្ទោសរដ្ឋាភិបាល ឬក្រុមហ៊ុន

ប្រមូលសំរាម ខណៈដែលសំរាមនៅតាមដងផ្លូវ និងប្រឡាយទឹកទាំងនោះ គឺប្រជាពលរដ្ឋជាអ្នកបោះចោល។ ដូច្នេះដើម្បីឱ្យរាជធានីភ្នំពេញស្អាត គឺចាប់ផ្តើមពីប្រជាពលរដ្ឋខ្លួនឯង។

គាត់ក៏បានលើកឡើងថា នៅពេលដែលប្រជាជនចេះ ញែក ចេះវេចខ្ចប់ និងបញ្ចេញសំរាមតែម្តងក្នុងមួយថ្ងៃ នឹងធ្វើឱ្យរាជធានីភ្នំពេញស្អាត។ គាត់បានសង្កត់ធ្ងន់ថា ដើម្បីឱ្យរាជធានីភ្នំពេញស្អាត គឺត្រូវបញ្ចេញសំរាមមួយថ្ងៃតែម្តងប៉ុណ្ណោះ បើទោះបីជាមានសំរាមច្រើនយ៉ាងណាក៏ដោយ ហើយបើមានសំរាមសល់ ត្រូវទុកបញ្ចេញស្អែកទៀត។

**គ. កិច្ចសម្ភាសន៍រដ្ឋាករស្វយ័ត គ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ**

លោក នួន សំណាវុធ នាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន និងជា អភិបាលរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញបានមានប្រសាសន៍ថា ប្រសិនបើយើងមិនបានធ្វើការញែកសំរាម សំរាមទាំងអស់ដែលលាយឡំគ្នាហើយយកទៅដល់ទីលានផ្ទេរសំរាម ធ្វើឱ្យមានការពិបាកញែក។ តែបើយើងបានចូលរួមញែកសំរាមតាំងពីដំបូងហើយសំរាមតិចតួចដែលមិនបានញែកទុកឱ្យអ្នកប្រមូល និងដឹកជញ្ជូនជាអ្នកញែក វានឹងមានការចំណេញ និងមានភាពងាយស្រួល។ បើយើងមិនបានញែកដោយខ្លួនឯង ហើយទុកសំរាមឱ្យនៅលាយឡំគ្នា គឺត្រូវការចំណាយកម្លាំង និងឧបករណ៍ច្រើនដើម្បីធ្វើការញែក។ គាត់បានបន្តថា ការញែកសំរាមដោយខ្លួនឯងនេះ គឺជាការជួយចូលរួមកាត់បន្ថយការចំណាយរបស់រដ្ឋ ហើយការញែកនេះក៏ជាការចូលរួមជួយសង្គម ដោយវាធ្វើឱ្យមានភាពងាយស្រួលដល់អ្នកដែលត្រូវយកសំរាមទៅកែច្នៃ និងជួយការពារដល់បរិស្ថាន។

គាត់បានមានប្រសាសន៍បន្ថែមថា បច្ចុប្បន្នប្រជាពលរដ្ឋបានសាទរចំពោះការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម ដោយហេតុថាការប្រមូលមានភាពប្រសើរជាងមុន ប៉ុន្តែមានប្រជាពលរដ្ឋមួយចំនួនមិនទាន់បានចូលរួមបង់ថ្លៃសេវា។ គាត់នូវបន្តទៀតថា បើចង់ឱ្យរាជធានីភ្នំពេញស្អាត លុះត្រាណាតែភាគីពាក់ព័ន្ធ គឺអ្នកដែលបង្កើតសំរាមជាអ្នកចូលរួម បើពួកគាត់ឈប់បង្កើតសំរាមនឹងមិនមានការពិបាកទៀតទេ បើយើងទាំងអស់គ្នាពេលដែលយើងហូបអីហើយ ហើយយើងកុំបោះសំរាមចោល តែត្រូវដាក់ក្នុងហោប៉ៅ ឬវេចខ្ចប់ដាក់ក្នុងថង់សិនចាំពេលដល់កន្លែងណាមានធុងសំរាមចាំបោះចោលក្នុងធុងសំរាម។ តែបើយើងហូបហើយបោះចោលដោយគ្មានសណ្តាប់ធ្នាប់ អ្នកសម្អាតនឹងត្រូវសម្អាតរហូត ដូច្នេះហើយទាល់តែយើងឈប់បោះទើបក្រុមហ៊ុនអាចសម្អាតបានស្អាត។ គាត់បានលើកឡើងដើម្បីឱ្យរាជធានីភ្នំពេញស្អាតលុះត្រាណាតែមានការចូលរួមពីយើងទាំងអស់គ្នា។

### ៣.៣.៤.លទ្ធផលនៃករណីសិក្សា

**ក. ករណីសិក្សាទី១**

កំណាត់ផ្លូវប្រវែងជាង២០ម៉ែត្រជាប់អតីតទីលានចាក់សំរាមចាស់ ស្ថិតក្នុងភូមិព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ បច្ចុប្បន្នកំពុងក្លាយជាកន្លែងដែលគេយកសំរាមទៅបោះចោលយ៉ាងអនាធិបតេយ្យ ធ្វើឱ្យសំរាមគរពាសពេញនៅលើដងផ្លូវបេតុងមួយនេះ និងបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។ ពិសេសប៉ះពាល់ការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋ ព្រោះសំរាមនៅចំណុចខាងលើច្រើន រហូតរាយមកលើចំណែកផ្លូវបេតុងស្ទើរតែ១០០ភាគរយ។

ប្រជាពលរដ្ឋដែលធ្វើដំណើរឆ្លងកាត់ផ្លូវខាងលើ បានសម្តែងនូវអារម្មណ៍មិនពេញចិត្ត និងរិះគន់ធ្ងន់ៗទៅលើអាជ្ញាធរមូលដ្ឋាន អំពីការមិនយកចិត្តទុកដាក់ទៅលើបញ្ហានេះ ដោយបណ្តែតបណ្តោយឱ្យសំរាមចេះតែមានចំនួនច្រើនឡើងជាបន្តបន្ទាប់ ពាសពេញលើដងផ្លូវបេតុង រហូតកកណែនណាន់តាន់តាប់ស្ទើររកផ្លូវធ្វើដំណើរទៅមុខលែងបានទៅហើយ។[30]

តាមករណីខាងលើនេះ បញ្ហាប្រឈមនៅក្នុងការគ្រប់គ្រងសំរាម គឺប្រជាពលរដ្ឋនៅមានចំណេះដឹងទាប ឬគ្មានចំណេះដឹងទាក់ទងទៅនឹងការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញចោលសំរាម និងមិនយល់ដឹងពីផលប៉ះពាល់នៃសំរាមចំពោះសុខភាព សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន ដោយនៅតែបន្តបោះសំរាមចោលយ៉ាងអនាធិបតេយ្យ។ នៅក្នុងករណីខាងលើនេះក៏បានបង្ហាញពីភាពធ្វេសប្រហែសនៃអាជ្ញាធរមូលដ្ឋាន ដោយមិនបានតាមដាន ត្រួតពិនិត្យការចោលសំរាមរបស់ប្រជាពលរដ្ឋបានល្អ។ ការចោលសំរាមអនាធិបតេយ្យនេះវានាំឱ្យមានការប៉ះពាល់ខ្លាំងទៅលើសុខភាពរបស់ប្រជាពលរដ្ឋ ដែលរស់នៅទីតាំងក្បែរៗនោះ និងប៉ះពាល់ទៅដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ។ ហើយបើសង្កេតមើលទៅលើករណីនេះ ក៏អាចប្រឈមមុខនឹងការបាត់បង់ផ្លូវផងដែរ ដោយសារតែការបន្តចោលសំរាមនៅលើផ្លូវជាបន្តបន្ទាប់។ ដើម្បីដោះស្រាយបញ្ហានេះបាន គឺចាំបាច់ណាស់ដែលត្រូវផ្តើមចេញពីប្រជាពលរដ្ឋជាមុន ព្រោះថាប្រជាពលរដ្ឋជាអ្នកចោលសំរាម។

**ខ. ករណីសិក្សាទី២**

សំរាមប្រមាណ១៥០០តោន ក្នុងនោះភាគច្រើនជាសំរាមប្លាស្ទិក ត្រូវបានកាយចេញពីប្រឡាយទឹកស្អុយបឹងត្របែក ក្នុងរយៈពេលជាងកន្លះខែ ប៉ុន្តែមន្ត្រីថា ចំនួនសំរាមនេះ គឺមានការថយចុះជាងមុន ប៉ុន្តែនៅតែស្ថិតក្នុងបរិមាណច្រើនដដែល។

ក្រុមកាងារបានចាប់ផ្តើមដំណើរការស្តារ ឬកាយសំរាមដែលនៅកកស្ទះចេញពីប្រឡាយទឹកស្អុយនេះ តាំងពីថ្ងៃទី១០ ខែមីនា ហើយសំរាមនេះត្រូវបានស្តាររួចជាស្ថាពរនៅថ្ងៃទី៣១ មីនា ដើម្បីសម្រួលផ្លូវទឹកហូរ កាត់បន្ថយការលិចលង់នៅរដូវវស្សាខាងមុខ។ ក្នុងពេលជាងកន្លះខែ ក្រុមការងារបានស្តារសំរាមចេញពីប្រឡាយនេះបាន៣៨០ឡាន ឬស្មើនឹង ១៩០០ម៉ែត្រគូប ដែលមានប្រមាណ ១៥០០តោន លើប្រវែងប្រឡាយបឹងត្របែង

[30] **https://kohsantepheapdaily.com.kh/article/715297.html** ចូលមើលថ្ងៃចុងក្រោយ១៨ ខែកក្កដា ឆ្នាំ២០២២

៩០០ម៉ែត្រ ទទឹង ៣០ម៉ែត្រ។ សំរាមដែលត្រូវបានស្តារចេញពីប្រឡាយទាំងនេះ គឺបានហូរមកពីគ្រប់ទិសទី ជាពិសេសតាមរយៈពលរដ្ឋមិនបានទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។[31]

ករណីប្រឡាយបឹងត្របែកនេះ យើងសង្កេតឃើញថាសំរាមជាច្រើននៅតែមាននៅក្នុងប្រឡាយនេះ បើទោះបីជាមានការណែនាំ ផ្សព្វផ្សាយមិនឱ្យមានការបោះចោលសំរាមទៅក្នុងប្រឡាយ និងមានការស្តារសំរាមចេញពីប្រឡាយនេះជាប្រចាំក៏ដោយ ក៏នៅតែមានប្រជាពលរដ្ឋមួយចំនួន នៅតែបន្តបោះចោលដដែល។ ការបោះចោលសំរាមនៅក្នុងប្រឡាយនេះធ្វើឱ្យប៉ះពាល់ទៅដល់សោភ័ណភាព ធ្វើឱ្យលូមានការកកស្ទះ មិនអាចហូរទឹកបាន ជះក្លិនមិនល្អ និងប៉ះពាល់ទៅដល់បរិស្ថាន ជាពិសេស គឺគុណភាពទឹក។

ចំពោះករណីនេះ បញ្ហាប្រឈម គឺនៅតែកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងការគ្រប់គ្រងសំរាមដដែល។ ដោយសារតែពួកគាត់មិនបានយល់ដឹងពីផលប៉ះពាល់នៃសំរាម ការញែក ការវេចខ្ចប់ និងការទុកដាក់សំរាមទើបពួកគាត់មួយចំនួននៅតែបន្តបោះចោលសំរាមទៅក្នុងប្រឡាយ។ ដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវមានការណែនាំ និងផ្សព្វផ្សាយបន្ថែមឱ្យបានទូលំទូលាយអំពីការគ្រប់គ្រងសំរាម សំណល់រឹង និងធ្វើការផាកពិន័យចំពោះអ្នកដែលបោះចោលសំរាមនៅក្នុងប្រឡាយឱ្យបានតឹងរឹង។

យើងអាចសង្កេតមើលទៅលើករណីទាំងពីរខាងលើឃើញថា ករណីទាំងពីរនេះ គឺសុទ្ធតែបណ្តាលមកពីប្រជាពលរដ្ឋ ដែលពួកគាត់បោះចោលសំរាមទាំងលើគោក និងក្នុងទឹក។ ពួកគាត់មិនបានយល់ដឹងពីការគ្រប់គ្រងសំរាម សំណល់រឹងឱ្យបានល្អ មិនបានយល់ដឹងពីផលប៉ះពាល់នៃសំរាម ទើបពួកគាត់នៅតែបន្តបោះចោលបែបនេះ។ បើពួកគាត់ឈប់បោះចោល ហើយវេចខ្ចប់សំរាមឱ្យបានត្រឹមត្រូវ ក៏មិនមានសំរាមបែបនេះទៀតដែរ។ ដូចនេះហើយ ដើម្បីដោះស្រាយបញ្ហានេះបាន គឺត្រូវមានការចូលរួមពីប្រជាពលរដ្ឋគ្រប់រូបជាចាំបាច់។

### ៣.៣.៥.សំយោគ

សរុបមកវិញ បញ្ហាប្រឈមធំបំផុតដែលកើតមានក្នុងការប្រមូលសំរាម គឺប្រជាពលរដ្ឋមិនទាន់យល់ដឹងពីការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញចោល និងពេលវេលានៃការប្រមូលសំរាម ដោយដាក់សំរាមនៅលាយឡំគ្នាទាំងសំរាមសើម សំរាមស្ងួត និងសំរាមមានគ្រោះថ្នាក់ ដែលធ្វើឱ្យការប្រមូលសំរាមចំណាយពេលយូរ ពិបាកប្រមូល និងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រមូល។ ហើយប្រជាពលរដ្ឋក៏មិនបានយល់ដឹងពីផលប៉ះពាល់នៃសំរាម ដោយមានប្រជាពលរដ្ឋមួយចំនួននៅតែបោះចោលសំរាមពាសវាលពាសកាល និងមិនបានចូលរួមអនុវត្តគោលការណ៍៣R ដែលរួមមាន ការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ។ បញ្ហាប្រឈមមួយទៀតនោះ គឺហេដ្ឋារចនាសម្ព័ន្ធ ដោយផ្លូវមួយចំនួនឡានប្រមូលសំរាមមិនអាចចូលរួច

[31] **https://www.postkhmer.com** ចូលមើលថ្ងៃចុងក្រោយ១៨ ខែកក្កដា ឆ្នាំ២០២២

ព្រោះតូចពេក។ ហើយចំពោះទីតាំងមួយចំនួន គឺគ្មានកន្លែងដាក់ធុងសំរាម ជាពិសេសកន្លែងសម្រាប់ដាក់ធុងដាំស្ទ័រ។ ព្រមទាំងការផ្សព្វផ្សាយអំពីវិធានការកាត់បន្ថយសំរាម សំណល់រឹងទីប្រជុំជន នៅមានកម្រិត។

## ៣.៤.ដំណោះស្រាយ

ដំណោះស្រាយចំពោះបញ្ហាការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញមានដូចជាៈ

- បង្កើនការផ្សព្វផ្សាយណែនាំដល់ប្រជាពលរដ្ឋ អំពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញចោលការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ តាមរយៈការធ្វើសិក្ខាសាលា និងការចុះទៅណែនាំផ្ទាល់ដល់ទីកន្លែង ជាពិសេសគឺតំបន់ជាយរាជធានី ក្នុងមួយខែចំនួន៣ដង។ ព្រមទាំងការផ្សព្វផ្សាយតាមបណ្ដាញសង្គមដូចជាហ្វេសប៊ុក តេលេក្រាមឱ្យបានទូលំទូលាយ។
- សិក្សា និងពិភាក្សាជាមួយប្រជាពលរដ្ឋដើម្បីស្វែងរកទីតាំងសម្រាប់ដាក់ធុងដាំស្ទ័រនៅផ្លូវធំ ដែលមានទីតាំងនៅជាប់ផ្លូវតូចដែលឡានមិនអាចចូលប្រមូលបាន ដើម្បីឱ្យប្រជាពលរដ្ឋនៅតំបន់នោះយកសំរាមទៅដាក់នៅក្នុងធុងដាំស្ទ័រនេះ ហើយក៏ងាយស្រួលឱ្យឡានប្រមូលសំរាមទៅប្រមូល និងប្រើរទេះប្រមូលសំរាម ដើម្បីប្រមូលសំរាមនៅផ្លូវដែលតូចចង្អៀត និងមានទីតាំងឆ្ងាយពីធុងដាំស្ទ័រ។
- លើកទឹកចិត្តឱ្យប្រជាពលរដ្ឋដោយធ្វើការកែច្នៃឡើងវិញនូវរបស់ណាដែលអាចប្រើប្រាស់ឡើងឱ្យទៅជាវត្ថុផ្សេង ដែលអាចប្រើប្រាស់បាន
- លើកទឹកចិត្តទៅដល់ក្រុមហ៊ុនឯកជន ក្នុងការវិនិយោគទៅលើការកែច្នៃសំរាមឡើងវិញ ចំពោះសំរាមដែលអាចកែច្នៃបាន
- តម្លើងប្រាក់ខែទៅដល់អ្នកប្រមូលសំរាម ដើម្បីឱ្យពួកគាត់កាន់តែមានទឹកចិត្តក្នុងការធ្វើការ
- រឹតបន្តឹងការផាកពិន័យចំពោះអ្នកដែលចតរថយន្តនៅលើដងផ្លូវ ដែលបណ្ដាលឱ្យរថយន្តប្រមូលសំរាមចូលទៅប្រមូលមិនបាន
- កំណត់ឱ្យមានការដាក់ធុងសំរាមនៅគ្រប់ទីកន្លែង
- បង្កើតក្រុមការងារចាំឃ្លាំមើលអ្នកបោះសំរាមចោលនៅតាមទីសាធារណៈ ដើម្បីធ្វើការផាកពិន័យ
- ពង្រឹងការអនុវត្តច្បាប់ ចំពោះការផាកពិន័យទៅដល់អ្នកដែលមិនអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត និងសេចក្ដីណែនាំពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹង។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្វែងយល់អំពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញរួចមក យើងសង្កេតឃើញថា ការគ្រប់គ្រងសំរាម សំណល់រឹង គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ បើការគ្រប់គ្រងសំរាម សំណល់រឹងបានល្អនឹងធ្វើឱ្យរាជធានីភ្នំពេញស្អាត មានសោភ័ណភាព អនាម័យ និងមានសណ្តាប់ធ្នាប់ល្អ។ ហើយសុខភាពរបស់ប្រជាពលរដ្ឋ និងបរិស្ថានជុំវិញក៏មានភាពល្អប្រសើរផងដែរ។ ផ្ទុយទៅវិញបើការគ្រប់គ្រងសំរាមមិនបានល្អ នោះជាមូលហេតុដែលនាំឱ្យប៉ះពាល់ទៅដល់សុខភាពមនុស្ស បរិស្ថាន សេដ្ឋកិច្ច និងសណ្តាប់ធ្នាប់សាធារណៈ។

ការគ្រប់គ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញកាន់តែមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ តែទោះជាយ៉ាងណាក៏បញ្ហាប្រឈមនៅតែកើតមានឡើង ដែលបញ្ហាប្រឈមសំខាន់ គឺប្រជាពលរដ្ឋមិនទាន់មានការយល់ដឹងពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញចោលសំរាម សំណល់រឹងឱ្យបានត្រូវពេលវេលា។ ទន្ទឹមនឹងនោះទៀតសោត ប្រជាពលរដ្ឋក៏មិនទាន់បានចូលរួមអនុវត្តគោលការណ៍៣Rsនៅឡើយ។ ពោលគឺ ការបង្កើតសំរាមមានការកើនឡើងជារៀងរាល់ឆ្នាំ ហើយសំរាមភាគច្រើនក៏មិនបានធ្វើការប្រើប្រាស់ឡើងវិញឡើយ។ ហើយសំរាមទាំងនោះ គឺមានភាគតិចប៉ុណ្ណោះដែលបានយកទៅកែច្នៃ។

បន្ទាប់ពីមានកំណែទម្រង់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងមក រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញត្រូវបានបង្កើតឡើង ដែលមានតួនាទី រៀបចំនីតិវិធីឱ្យមានក្រុមហ៊ុនច្រើនចូលរួមដេញថ្លៃឈរលើគោលការណ៍ប្រកួតប្រជែង ក្នុងការផ្តល់សេវាប្រមូល សម្អាត និងដឹងជញ្ជូនសំរាម សំណល់រឹង និងមានតួនាទីគ្រប់គ្រង ឃ្លាំមើល ត្រួតពិនិត្យ និងវាយតម្លៃលើក្រុមហ៊ុនប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង។ ហើយក្រុមហ៊ុនឯកជនដែលទទួលបានសិទ្ធិក្នុងការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ គឺមានចំនួនបី។ បន្ទាប់ពីមានការបែងចែកតំបន់ជាបីតំបន់ ដើម្បីឱ្យក្រុមហ៊ុនទាំងបីចែកគ្នាសម្អាត យើងសង្កេតឃើញថា ការប្រមូលសំរាមទៀងពេលជាងមុន ប្រមូលសំរាមអស់ៗ និងការសម្អាតតាមដងផ្លូវក៏មានភាពប្រសើរជាងមុន។ ក្រុមហ៊ុនក៏បានចូលរួមផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញចោលសំរាមឱ្យបានត្រឹមត្រូវផងដែរ។ ហើយតួនាទីក្នុងការប្រមូលថ្លៃសេវាប្រមូល និងទុកជញ្ជូនសំរាម សំណល់រឹង គឺរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញជាអ្នកមានតួនាទី។ តាំងពីមានកំណែទម្រង់ រហូតមកដល់បច្ចុប្បន្ន នាំឱ្យការគ្រប់គ្រងសំរាមមានភាពល្អប្រសើរច្រើន។

ទន្ទឹមនឹងភាពល្អប្រសើរនេះ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលកើតមានឡើង និងមិនទាន់បានដោះស្រាយ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះបាន លុះត្រាតែមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងអស់

ដែលមានរាជរដ្ឋាភិបាល ក្រុមហ៊ុនឯកជនដែលទទួលបានសិទ្ធិក្នុងការផ្តល់សេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹង និងតួអង្គសំខាន់ គឺប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋ គឺជាអ្នកដើរតួសំខាន់បំផុតក្នុងការកាត់បន្ថយសំរាម សំណល់រឹង។ បញ្ហានៃការគ្រប់គ្រងសំរាម សំណល់រឹងភាគច្រើនកើតឡើងមកពីប្រជាពលរដ្ឋ ដូចជាការចោលសំរាមនៅតាមទីសាធារណៈ មិនបានញែកសំរាមទៅតាមប្រភេទ វេចខ្ចប់សំរាមមិនបានត្រឹមត្រូវ ការបញ្ចេញសំរាមខុសម៉ោងប្រមូល និងការមិនបានចូលរួមអនុវត្តវិធានការណ៍៣Rs។ ដូច្នេះហើយដើម្បីឱ្យការគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងរាជធានីភ្នំពេញបានល្អប្រសើរ គឺត្រូវចាប់ផ្តើមពីប្រជាពលរដ្ឋ។

ខ្លឹមសារនៃសារណាទាំងមូលនេះក៏បានឆ្លើយតបទៅនឹងសំណួរនៃចំណោទបញ្ហាទាំងមូលផងដែរ។ ដែលបានបង្ហាញពីទ្រឹស្តីនានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងដូចជា លិខិតបទដ្ឋានគតិយុត្ត របាយការណ៍ ក៏ដូចជាស្នាដៃរបស់សិស្សច្បងមុនៗដែលបានចងក្រងអំពីការគ្រប់គ្រងសំរាមសំណល់រឹងក្នុងរាជធានីភ្នំពេញនេះ។ ហើយក៏បានបង្ហាញពីស្ថាប័នដែលមានសមត្ថកិច្ចក្នុង ការគ្រប់គ្រងសំរាម សំណល់រឹង និងតួនាទីភារកិច្ចរបស់ស្ថាប័នទាំងនោះពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ។ នៅក្នុងនោះដែរខ្លឹមសានៃសារណានេះ ក៏បានបង្ហាញពីបញ្ហាប្រឈមរបស់ស្ថាប័ននីមួយៗនៅពេលអនុវត្តនូវតួនាទីភារកិច្ចរបស់ខ្លួននៅក្នុងដំណើរការនៃការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ហើយក៏មានភ្ជាប់នូវដំណោះស្រាយចំពោះបញ្ហាប្រឈមដែលស្ថាប័នទាំងនោះបានជួបប្រទះផងដែរ។

នៅក្នុងដំណើរការនៃការស្រាវជ្រាវឯកសារ ដែលមានប្រធានបទ"ការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងរាជធានីភ្នំពេញ" ក៏មានជួបនៅបញ្ហានៃការលំបាកមួយចំនួនមានដូចជា៖

- ខាងសាលាមានភាពយឺតយ៉ាវក្នុងការចេញពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារតាមស្ថាប័នពាក់ព័ន្ធ
- រយៈពេលខ្លីក្នុងដាក់ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ
- ការដាក់ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារមានភាពពិបាក ទីតាំងនៅឆ្ងាយ បុគ្គលិកស្ថាប័នមិនសូវមានការសហការក្នុងការទទួលស្វាគមន៍ ផ្តល់ជាបទសម្ភាសន៍សុទ្ធមិនមានឯកសារភ្ជាប់ជាមួយ
- ក្រុមហ៊ុនមួយចំនួនមិនអនុញ្ញាតឱ្យចុះស្រាវជ្រាវឯកសារ ដោយគ្មានការជូនដំណឹងត្រឡប់មកវិញ
- មិនស្គាល់ទីតាំងត្រូវចុះទៅដាក់ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ
- បញ្ហាខាងបច្ចេកទេសកុំព្យូទ័រមានភាពរអាក់រអួល។

# អនុសាសន៍

ដើម្បីចូលរួមដោះស្រាយបញ្ហាដែលជួបប្រទះ នៅក្នុងដំណើរការនៃការស្រាវជ្រាវឯកសារក៏ដូចជាផលពិបាកនានាដែលបានលើកឡើងខាងលើក យើងខ្ញុំមានជាសំណូមពរនិងមតិផ្ដាំផ្ញើមួយចំនួនដូចជា ៖

- ក្រុមហ៊ុនគួតែមានការទទួលស្វាគមន៍ មានការសហការ និងផ្ដល់ឯកសារដែលពាក់ព័ន្ធក្នុងការចុះស្រាវជ្រាវឯកសារ
- ក្រុមហ៊ុនដែលមិនសហការអនុញ្ញាតឱ្យចុះស្រាវជ្រាវឯកសារ គួតែផ្ដល់ដំណឹងត្រឡប់មកនិស្សិតវិញតាមរយៈលេខទំនាក់ទំនងដែលបានភ្ជាប់ជាមួយពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ
- សាកលវិទ្យាល័យគួរតែ ចេញពាក្យចុះស្រាវជ្រាវឯកសារអោយបានលឿនដល់និស្សិតដើម្បីបង្ករឱ្យមានភាពងាយស្រួលក្នុងដំណើរការចុះស្រាវជ្រាវឯកសារ និស្សិតមានរយៈពេលយូរក្នុងការយកពាក្យចុះស្រាវជ្រាវឯកសារទៅដាក់នៅស្ថាប័នដែលពាក់ពន្ធ
- សាលាគួតែ មានវិធានការសម្របសម្រួលក្នុងការដាក់ពាក្យស្រាវជ្រាវឯកសារ ក៏ដូចជាស្ថាប័នដែលនិស្សិតត្រូវចុះទៅស្រាវជ្រាវឯកសារ ដើម្បីសម្រួលដល់ការចុះស្រាវជ្រាវឯកសាររបស់និស្សិត
- ចំពោះសិស្សប្អូនជំនាន់ក្រោយដែលមានបំណងចង់សរសេរសារណាបញ្ចប់ការសិក្សា ករណីមិនទាន់ស្គាល់ទីតាំងដែលត្រូវចុះទៅស្រាវជ្រាវឯកសារ គួរតែស្វែងរកតាមរយៈផែនទី និងធ្វើការទៅមើលទីកន្លែងមុនដើម្បីបង្កភាពងាយស្រួល
- ត្រួតពិនិត្យលើកុំព្យូទ័រដើម្បីបញ្ជាក់ថាគ្មានបញ្ហាមិនបង្កផលវិបាកក្នុងពេលសរសេរ និងស្រាវជ្រាវឯកសារ។

# ឯកសារយោង

# ឯកសារយោង

❖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

➢ អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

➢ អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក ចុះដថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

➢ ប្រកាស ស្តីពីការបង្កើតរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង នៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ, លេខ១១៩៩0ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

➢ ដីកា ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ, លេខ២២៤/១៩ដក.តត.ឆ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

➢ សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ, លេខ០២៥/២១

➢ សណន.ស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

❖ របាយការណ៍

➢ របាយការណ៍ ស្តីពីវឌ្ឍភាពការងារនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២១

➢ របាយការណ៍ បូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ ២០២២

❖ កិច្ចសម្ភាសន៍

➢ លោក នួន សំណាវុធ នាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន និងជា អភិបាលរដ្ឋាករស្វយ័ត គ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ

➢ លោក នៅ ឧត្តម អនុប្រធានការិយាល័យប្រតិបត្តិនៃក្រុមហ៊ុន ស៊ីនទ្រី

➢ អ្នកស្រី រ៉ន សារួម ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងបណ្តុះបណ្តាល នៃក្រុមហ៊ុន 800 ស៊ូភើ-ហ្កា-អ៊ី.យ៉ា

❖ សៀវភៅ

➢ សហត្ថិភាពរដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជា សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ ២០១៨

❖ សារណា

➢ ស៊ុម ច័ន្ទតារា (ការគ្រប់គ្រងកាកសំណល់រឹង នៅរាជធានីភ្នំពេញ) ឆ្នាំ២០១៧

➢ រ៉ុន ជូឌី និងទ្រី វ័ណ្ណឌី (ការគ្រប់គ្រងសំរាម នៅរាជធានីភ្នំពេញ) ឆ្នាំ២០១៩

- សេង សុខតី និងគង់ ដារី (ការគ្រប់គ្រងកាកសំណល់រឹង នៅក្នុងរាជធានីភ្នំពេញ) ឆ្នាំ២០២១

- គេហទំព័រ

- https://phnompenh.gov.kh/phnom-penh-city/facts/
- https://kohsantepheapdaily.com.kh/article/715297.html
- https://www.postkhmer.com
- https://sokankeng.wordpress.com/2013/12/03/
- https://clubniset.wordpress.com/2011/05/31

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១** រូបភាព
- **ឧបសម្ព័ន្ធទី២**
  - អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ខែសីហា ឆ្នាំ២០១៥
  - អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក ចុះដថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
  - ប្រកាស ស្តីពីការបង្កើតរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង នៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ, លេខ១១៩៩០ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩
  - ដីការ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ, លេខ២២៤/១៩ដក.គត.ឆ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩
  - សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ, លេខ០២៥/២១សណន.ស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១
- **ឧបសម្ព័ន្ធទី៣**
  - របាយការណ៍ ស្តីពីវឌ្ឍភាពការងារនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២១
  - របាយការណ៍ បូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រុមហ៊ុនស៊ីនទ្រី

# ឧបសម្ព័ន្ធទី១



ទិដ្ឋភាពទីក្រុងភ្នំពេញ



គំនរសំរាមជើងឯក



ទីលានចាក់សំរាមក្នុងខណ្ឌដង្កោ



ការដុតសំរាម



ការទុកដាក់សំរាមមិនបានត្រឹមត្រូវ






ការបែងចែកសំរាមទៅតាមប្រភេទ ការបែងចែកសំរាមនៅតាមគេហដ្ឋាន




គោលការណ៍៤Rsក្នុងការកាត់បន្ថយសំរាម










ប្រើប្រាស់ឡើងវិញ







ដបទឹកបរិស្ថាន





សកម្មភាពប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ីនទ្រី

សកម្មភាពបោសសម្អាតសំរាមតាមដងផ្លូវ





សកម្មភាពប្រមូលសំរាមរាមដងផ្លូវ

ការប្រមូលសំរាមរបស់ក្រុមហ៊ុនផ្តល់សេវា

# ឧបសម្ព័ន្ធទី២

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការផ្ទេរប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខ័ណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្ដាលមកពីភាពអសកម្មនៃអ្នកផ្ដល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្ដល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់ភក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្ដល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។
គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។
ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ត៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២( ដប់ពីរ )ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព អាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០-**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

១១- **ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

១២- **ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

១៣- **អាងស៊ិបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

១៤- **ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើសទៅនឹងបញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

១៥- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

# អនុក្រឹត្យ លេខ ៣៦ អនក្រ.បក
## ស្តីពីការគ្រប់គ្រងសំណល់រឹង

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៤ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១** .– អនុក្រឹត្យនេះ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេស សមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវចំរុះ ។

**មាត្រា ២** .– អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣** .– និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក- “**សំណល់រឹង** “ គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវអោយបោះបង់ចោល ។

ខ- “**សំរាម** “ គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅដ្ឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ ល ។

ត- "**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬ សារធាតុគីមីដទៃទៀត ដែលអាចនាំអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និង សេវាកម្មអាជីវកម្មដ៏ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## ការគ្រប់គ្រងសំរាម

**មាត្រា ៤ .-** ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពីគោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

**មាត្រា ៥ .-** ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី១ នៃមាត្រា ៥ នេះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦ .-** ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧ .-** ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរ មានសមត្ថកិច្ច ។

**មាត្រា ៨ .-** ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន ។

**មាត្រា ៩ .-** ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលើកណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០ .-** ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

មាត្រា ១១ .-ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

មាត្រា ១២ .-ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬ សារធាតុគ្រោះថ្នាក់នៅក្នុងសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវចំរុះ ។

មាត្រា ១៣ .-ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព ។

មាត្រា ១៤ .-ម្ចាស់សំណល់ ត្រូវធ្វើនិងផ្ញើរបាយការណ៍រៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក- ប្រភេទ និង បរិមាណសំណល់

ខ- វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ- វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬ បំបាត់សំណល់ ។

មាត្រា ១៥ .-ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬ ចាក់ចោលសំណល់ ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តនីតាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬ ការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬ បណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

មាត្រា ១៦ .-ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ ក្លីនិក សម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តនីវាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពីគោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

មាត្រា ១៧ .-ការដឹកជញ្ជូន ឬ សាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ១៨ .-ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើនិងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក- ប្រភេទ និង បរិមាណសំណល់

ខ- ប្រភពដើមរបស់សំណល់

គ- ការដឹកជញ្ជូន និង មធ្យោបាយវេចខ្ចប់

ឃ- ដំណើរការ និងការគ្រប់គ្រង សំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

មាត្រា ១៩ .-ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ២០ .-ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទបញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាន នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

មាត្រា ២១ .-ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច

## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

មាត្រា ២២ .-ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្ម សំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

មាត្រា ២៣ .-ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា ២៣ នេះ ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

មាត្រា ២៤ .- ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ច ត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា ២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា ២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

មាត្រា ២៥ .-ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ច ដល់ទីកន្លែងនោះ ដោយអនុវត្តតាមនីតិវិធីដែលមានចែងខាងក្រោម :

ក- បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬ ទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ- ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬ ការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ- ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

មាត្រា ២៦ .- ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ បង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥

## ទោសបញ្ញត្តិ

មាត្រា ២៧ .-ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និង មាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ២៨ .-មន្ត្រី ឬ ភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទបញ្ជារបស់ក្រសួង ឬ រួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

មាត្រា ២៩ .-កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

មាត្រា ៣០ .–បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣១ .–រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣២ .–អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត

***

## <u>ឧបសម្ព័ន្ធ</u>

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១- សំណល់សរសៃអំបោះ និង កំទេចក្រណាត់ដែលមានពណ៌ (ក្នុងករណីយកទៅដុត)

២- សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស

៣- សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និង ទឹកល្ង

៤- សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡ ឧស្សាហកម្ម

៥- សំណល់ប្លាស្ទិច “ ប៉ូលីវីនីលក្លរ “

៦- សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីស (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញេ ។ល។

៧- សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុ ប៉ូលីម៉ែប៉ុយទីលិន

៨- សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩- សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០- សំណល់ដែលមានផ្ទុកជាតិបាស

១១- សំណល់ លោហៈ និងសមាសធាតុរបស់វា រួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |

| | | | |
|---|---|---|---|
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាលយ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរីយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១២- ល្បាយផ្សេង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣- សំណល់ អំពូលអគ្គិសនី និង បន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១៤- សំណល់អាគុយ និងថ្មពិល

១៥- សំណល់ថ្នាំលាប និង ថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦- សំណល់បានមកពីការផលិត និង ការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧- សំណល់ គ្រឿងផ្ទុះ

១៨- សំណល់ ដែលនាំអោយមានការចំលងមេរោគ ឬ ជំងឺ

១៩- សំណល់ ដែលសល់ពីការផលិតថ្នាំពុល កសិកម្ម និងសំភារៈវេចខ្ចប់

២០- សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១- ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២- សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្ស តាមមន្ទីរពេទ្យ ។

២៣- សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤- សំណល់ដែលបានមកពីការផលិតឱសថ និង ឱសថដែលខូចគុណភាព

២៥- សំណល់ដែលជាសមាសធាតុសរីរាង្គភ្លុយអរីន

២៦- សំណល់ ដែលជាសមាសធាតុស៊ីអានីត

២៧- សំណល់ ដែលជាសមាសធាតុអាសបេស្តូស

២៨- សំណល់ ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩- សំណល់ ដែលជាសមាសធាតុអេទែ ($R\text{-}COO\text{-}R_1$)

៣០- សំណល់ ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១- សំណល់ ដែលជាសមាសធាតុ ឌីអុកស៊ីន និងហ្វូរ៉ាន

៣២- សំណល់ ធាតុវិទ្យុសកម្ម

៣៣- សារធាតុ ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី ៣២

★★★

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលរាជធានីភ្នំពេញ
លេខ: ៥៥៤/១៩ ដក.ភត.ឆ

# ដីកា
## ស្តីពី
## ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/០៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការប្រោសប្រទានបង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាល ហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅនៃរដ្ឋាករខេត្ត ក្រុង
- បានឃើញប្រកាសលេខ ១១៩៩០ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង នៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ
- យោងលិខិតលេខ១១១២៣ សហវ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

**សម្រេច**

**ប្រការ ១._**

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ក្នុងរចនាសម្ព័ន្ធរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | លោក | ខួន សំណាងចុច | ជាអភិបាលរដ្ឋាករ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២. | លោក | កែច ចាន់ណារិទ្ធ | ជាអនុអភិបាលរដ្ឋាករ | បន្ថែមលើមុខងារបច្ចុប្បន្ន |

**ប្រការ ២._**

ត្រូវបានតែងតាំងលោក ឡាយ រើមិន ជាអនុអភិបាលរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង។ ✓

មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦៦៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

CS CamScanner

Scanned with CamScanner

**ប្រការ ៣._**

អភិបាល និងអភិបាលរងរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង មានតួនាទី និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងប្រតិបត្តិការប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹងពីលើក្រុមហ៊ុន ស៊ីនទ្រី នៅក្នុងរយៈពេលអន្តរកាល
- រៀបចំប្រព័ន្ធប្រមូល និងបង់ចំណូល
- ទូទាត់ថ្លៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹងដល់ក្រុមហ៊ុនដែលបម្រើសេវា
- គ្រប់គ្រងប្រតិបត្តិការទុកដាក់សំរាម និងសំណល់រឹងនៅទីលានចាក់សំរាមរបស់រដ្ឋបាលរាជធានីភ្នំពេញ
- រៀបចំកែសម្រួលតារាងតម្លៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង ដើម្បីដាក់ជូនអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញពិនិត្យ និងសម្រេច
- រៀបចំនីតិវិធីចូលរួមដេញថ្លៃ ដើម្បីស្វែងរកដៃគូដែលមានសមត្ថភាពក្នុងការផ្តល់សេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង ដោយឈរលើគោលការណ៍ប្រកួតប្រជែង ដើម្បីដាក់ជូនអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញពិនិត្យ និងសម្រេច
- សហការជាមួយក្រសួង-ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតទីលានសុវត្ថិភាពសម្រាប់ទុកដាក់សំរាម និងសំណល់រឹង
- រៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីត្រួតពិនិត្យ និងតាមដានការងាររបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង
- មានសិទ្ធិស្នើជ្រើសរើស តែងតាំង ដកហូតអំណាច ឬបញ្ឈប់ការងារបុគ្គលិក និយោជិតក្របខណ្ឌរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង
- ធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម និងសំណល់រឹង
- បំពេញមុខងារក្នុងវិស័យខាងលើផ្សេងទៀត តាមការចង្អុលបង្ហាញពីអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។

**ប្រការ ៤._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីដីកានេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥._**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ មានភារកិច្ចអនុវត្តដីកានេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៣ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

អភិបាលរាជធានីភ្នំពេញ

ឃួង ស្រេង

***កន្លែងទទួល៖***
*- ទីស្តីការគណៈរដ្ឋមន្ត្រី*
*- ក្រសួងមហាផ្ទៃ*
*- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*"ដើម្បីជូនជ្រាប"*
*- ដូចប្រការ៥*
*"ដើម្បីអនុវត្ត"*
*- ឯកសារ-កាលប្បវត្តិ*




CamScanner
Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ: ០២៥/២១ សណន.ស

# សេចក្តីណែនាំ
## ស្តីពី
## ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

ការធ្វើកំណែទម្រង់នៃការគ្រប់គ្រងសំរាម និងសំណល់រឹង នៅរាជធានីភ្នំពេញ ចាប់ពីដើមខ្សែរហូតដល់ចុងខ្សែ ទទួលបានលទ្ធផលគួរជាទីមោទនៈ ក្នុងនោះ ការដេញថ្លៃជ្រើសរើសក្រុមហ៊ុនថ្មី ដើម្បីផ្តល់សេវាសំអាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ក៏បានធ្វើរួចរាល់ផងដែរ ដែលកន្លងមក ក្រុមហ៊ុនចំនួន០៣ ត្រូវបានជ្រើសរើស ហើយបានចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១។ ក្រុមហ៊ុនទាំង០៣នោះ គឺទី១ ក្រុមហ៊ុន 800 Super/Global Action for Environment Awareness Public Limited បានផ្តល់សេវា ក្នុងតំបន់ទី១ ដែលមាន០៥ខណ្ឌ រួមមាន ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌឬស្សីកែវ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ។ ទី២ ក្រុមហ៊ុន Mizuda Group Co., Ltd បានផ្តល់សេវាក្នុងតំបន់ទី២ ដែលមាន០៥ខណ្ឌ រួមមាន ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌដង្កោ ខណ្ឌកំបូល និងខណ្ឌពោធិ៍សែនជ័យ។ ទី៣ ក្រុមហ៊ុន CINTRI (Cambodia)/Everbright (China) បានផ្តល់សេវា ក្នុងតំបន់ទី៣ ដែលមាន០៤ខណ្ឌ រួមមាន ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ។

ដើម្បីឱ្យការអនុវត្តប្រព័ន្ធថ្មីនៃការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រដ្ឋបាលរាជធានីភ្នំពេញ សូមធ្វើការណែនាំអំពី**ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹង** ដូចខាងក្រោម៖

១. សំរាម និងសំណល់រឹង មុននឹងបញ្ចេញ ត្រូវសម្រិតទឹកចេញដាក់ចូលទៅក្នុងប្រព័ន្ធលូឱ្យបានត្រឹមត្រូវ។

២. ត្រូវញែកសំរាម សំណល់រឹង ជា០២ប្រភេទ គឺ**សំរាមសើម** និង**សំរាមស្ងួត** ដោយដាក់នៅក្នុងថង់ដាច់ដោយឡែកពីគ្នា៖

- **សំរាមសើម៖** សំណល់ម្ហូបអាហារ សំណល់សរីរាង្គ ផ្លែឈើ ផ្កា ត្រូវដាក់ នៅក្នុង<u>**ថង់ពណ៌ខ្មៅ**</u>
- **សំរាមស្ងួត៖** ក្រដាស ក្រដាសកាតុង ឡាំង គ្រឿងប្លាស្ទីក ហ្វូម ជ័រ ដែក កំប៉ុង ដប...ត្រូវដាក់ក្នុង <u>ថង់ពណ៌ស</u>។

<u>បញ្ជាក់</u>៖ ក្រុមហ៊ុននឹងធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ដែលបានដាក់ក្នុងថង់ដែលបានកំណត់ទាំង០២ប្រភេទនេះតែប៉ុណ្ណោះ ទៅតាមកម្មវិធីដាច់ដោយឡែកពីគ្នា។ ការដាក់សំរាម សំណល់រឹង ក្នុងថង់ពណ៌ផ្សេងក្រៅពីពណ៌ខ្មៅ និងពណ៌ស ក្រុមហ៊ុននឹងមិនប្រមូលឡើយ។ បងប្អូនប្រជាពលរដ្ឋ អាចរកទិញថង់ទាំង០២ពណ៌ខាងលើនេះ នៅតាមបណ្តាទីផ្សារនានា។

៣. ហាមវេចខ្ចប់សំណល់ដែលបង្កគ្រោះថ្នាក់ ដូចជា អំបែងកញ្ចក់ និងសំណល់មុតស្រួចនានា លាយឡំជាមួយនឹងសំរាមសើម និងសំរាមស្ងួត។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**បញ្ជាក់៖** ត្រូវទុកដាក់សំណល់ដែលបង្កគ្រោះថ្នាក់ទាំងនេះចូលក្នុងធុងសំរាម ឬប្រអប់ដោយឡែកឱ្យបានត្រឹមត្រូវ ក្រុមហ៊ុននឹងប្រមូលនៅរៀងរាល់ **ថ្ងៃអាទិត្យ**។ ក្នុងករណីទុកដាក់ខុសពីការណែនាំនេះ ក្រុមការងារផាកពិន័យ នឹងធ្វើកំណត់ហេតុអំពីកំហុសឆ្គងលើកទី១។ បើនៅតែទុកដាក់ខុសទៀត នឹងទទួលការផាកពិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ព្រមទាំងប្ដឹងទៅតុលាការតាមកំហុសជាក់ស្ដែង។

៤. ចង់សំរាម សំណល់រឹង ត្រូវចងមាត់ឱ្យបានជិតត្រឹមត្រូវ និងមិនត្រូវហែកឡើយ។

៥. **ក្រុមតម្រូវ៖** មានដូចជា ផ្សារទំនើប ផ្សាររដ្ឋ ផ្សារឯកជន អគារពាណិជ្ជកម្ម សណ្ឋាគារ ផ្ទះសំណាក់ អាគារស្នាក់នៅ ភោជនីយដ្ឋាន កន្លែងកំសាន្ត សាលារៀន មន្ទីរពេទ្យ លំនៅដ្ឋានក្នុងបុរី សហគ្រាស រោងចក្រ សិប្បកម្ម អគារក្រសួង ស្ថាប័នរដ្ឋ **ត្រូវមានកាតព្វកិច្ចដាក់ធុងសំរាមដោយខ្លួនឯងជាចាំបាច់**។

៦. **ក្រុមលើកទឹកចិត្ត៖** មានដូចជា វត្តអារាម ព្រះវិហារ អាជីវកម្មលក់ដូរចល័ត ផ្ទះស្នាក់នៅទូទៅ និងផ្សារក្រមួន...អាចមាន០២ប្រភេទ៖ **ទី១. មានធុងសំរាមខ្លួនឯងស្រាប់ និងទី២. មានធុងសំរាមដែលផ្ដល់ឱ្យដោយប្រតិបត្តិករថ្មី ដែលអាចត្រូវបានរៀបចំដាក់ពង្រាយជាពិសេសនៅតាមតំបន់ផ្ទះល្វែងខ្ពស់ៗ**។

៧. ត្រូវទុកដាក់សំរាម សំណល់រឹងរបស់ខ្លួនឱ្យបានត្រឹមត្រូវទៅតាមទីកន្លែងដែលបានកំណត់ (ទីតាំងទុកដាក់សំរាមនឹងត្រូវបានកំណត់ដោយអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករប្រមូលសំរាម តាមការជាក់ស្ដែង)។

៨. ហាមចោលសំរាម សំណល់រឹង នៅមាត់អណ្ដូងលូ ប្រឡាយ តាមទីសាធារណៈ និងតាមអាងស្តុកទឹក និងហាមដុតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ជាកំហិត។

៩. **កម្មវិធីបញ្ចេញសំរាម សំណល់រឹង៖**

**សំរាមសើម**

- ខណ្ឌកណ្ដាលរាជធានី ចំនួន០៥ រួមមាន៖ ខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌបឹងកេងកង៖ ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូន**រៀងរាល់ថ្ងៃ នៅពេលយប់ ចាប់ពីម៉ោង ៩ ដល់ម៉ោង ៥ ទៀបភ្លឺ** ដូច្នេះ **ម៉ោងបញ្ចេញសំរាមមាន៣ម៉ោង គឺ៦-៩យប់។ បញ្ចេញសំរាមខុសពីម៉ោងនេះ នឹងទទួលការផាកពិន័យ**។
- ខណ្ឌជាយរាជធានី ចំនួន០៩ រួមមាន៖ ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ ខណ្ឌដង្កោ ខណ្ឌព្រែកព្នៅ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូន ដូចខាងក្រោម៖
  - ផ្លូវជាតិ៖ ត្រូវប្រមូល និងដឹកជញ្ជូន**រៀងរាល់ថ្ងៃ នៅពេលយប់ វេលាម៉ោង ៩យប់** ដូច្នេះ ការបញ្ចេញសំរាមត្រូវចាប់ផ្ដើមចន្លោះពីម៉ោង៦យប់ រហូតដល់ម៉ោង ៩យប់
  - ផ្លូវធំ៖ ត្រូវប្រមូល និងដឹកជញ្ជូន**រៀងរាល់ថ្ងៃ (ពេលថ្ងៃ វេលាម៉ោង ៨ព្រឹក ឬ ពេលយប់ វេលាម៉ោង ៩)**
  - ផ្លូវលំ៖ ត្រូវប្រមូល និងដឹកជញ្ជូន**រៀងរាល់ ០២ថ្ងៃ/១ម្ដង (ពេលថ្ងៃ វេលាម៉ោង ៨ព្រឹក ឬ ពេលយប់ វេលាម៉ោង ៩)**

  **បញ្ជាក់៖** ម៉ោងពេលបញ្ចេញសំរាម សំណល់រឹង នឹងត្រូវកំណត់ដោយអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករប្រមូលតាមការជាក់ស្ដែង។

  **សំរាម សំណល់រឹងស្ងួត៖** ក្រុមហ៊ុននឹងប្រមូល និងដឹកជញ្ជូន ២ដង/១សប្ដាហ៍ គឺនៅ**រៀងរាល់ថ្ងៃចន្ទ និងថ្ងៃសុក្រ**។

១០. ក្នុងករណីខកខានមិនបានបញ្ចេញសំរាម សំណល់រឹងតាម**ម៉ោងពេលកំណត់ (ពេលថ្ងៃត្រឹមម៉ោង ៨ព្រឹក និងពេលយប់ ត្រឹមម៉ោង ៩យប់)** ត្រូវរង់ចាំបញ្ចេញនៅវេនក្រោយ ហើយមិនត្រូវយកសំរាមនេះមកទុកគ្មានសណ្ដាប់ធ្នាប់ឡើយ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

១១. ចំពោះសំណល់ដើមឈើ និងមែកឈើ ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០៨១ ៦៤៦២២២ ឬ ០១១ ៦៤៦២២២ ឬកម្មវិធីទូរស័ព្ទដៃរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ (PPSWMA) ដើម្បីធ្វើការស្នើសុំប្រមូល និងដឹកជញ្ជូនចេញ។

១២. ចំពោះសំណល់សំណង់ អាចម៍ដី កំទេចថ្ម ខ្សាច់... ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០៨១ ៦៤៦២២២ ឬ ០១១ ៦៤៦២២២ ឬកម្មវិធីទូរស័ព្ទដៃរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ (PPSWMA) ដើម្បីធ្វើការស្នើសុំប្រមូល និងដឹកជញ្ជូនចេញ។

១៣. ចំពោះសំណល់ជាគ្រឿងសង្ហារឹម គ្រឿងអេឡិចត្រូនិក គ្រឿងអគ្គិសនី សំបកកង់ និងវត្ថុកែច្នៃឡើងវិញបាន ត្រូវទុកដាក់ដោយឡែកឱ្យបានត្រឹមត្រូវ រួចធ្វើការទំនាក់ទំនងមករដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០៨១ ៦៤៦២២២ ឬ ០១១ ៦៤៦២២២ ឬកម្មវិធីទូរស័ព្ទដៃរបស់រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម សំណល់រឹង រាជធានីភ្នំពេញ (PPSWMA) ដើម្បីធ្វើការស្នើសុំប្រមូល និងដឹកជញ្ជូនចេញ។

ក្នុងករណីមិនអនុវត្តតាមសេចក្តីណែនាំនេះ រដ្ឋបាលរាជធានីភ្នំពេញ នឹងធ្វើការដាកពិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ព្រមទាំងអនុវត្តវិធានការរដ្ឋបាល និងវិធានការនានាតាមការចាំបាច់ដទៃទៀត ដូចជា ការបិទការធ្វើអាជីវកម្មជាបណ្តោះអាសន្ន...។ល។

ទទួលបានសេចក្តីណែនាំនេះ រដ្ឋបាលរាជធានីភ្នំពេញ សង្ឃឹមថា បងប្អូនប្រជាពលរដ្ឋទាំងអស់នៅរាជធានីភ្នំពេញ នឹងចូលរួមចំណែកក្នុងការពង្រីកវប្បធម៌ចូលរួម ក៏ដូចជាការរក្សាអនាម័យ បរិស្ថាន សោភ័ណភាព រាជធានីភ្នំពេញឱ្យកាន់តែស្រស់ស្អាត និងត្រូវអនុវត្តសេចក្តីណែនាំនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

***សេចក្តីណែនាំនេះ នឹងត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ។***

ថ្ងៃព្រហស្បតិ៍ ១០កើតខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន

«ដើម្បីជូនជ្រាប»
- រដ្ឋបាលខណ្ឌទាំង ១៤
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- គ្រប់មន្ទីរ អង្គភាពជុំវិញសាលារាជធានីភ្នំពេញ
- ប្រតិបត្តិករថ្មីទាំង០៣

«ដើម្បីសហការអនុវត្ត»
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

«ដើម្បីផ្សព្វផ្សាយ»
- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

# ឧបសម្ព័ន្ធទី៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ:០៩៦/២២.របក សក

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២២

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ✓

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីវឌ្ឍនភាពការងារនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ ចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្នុងការអនុវត្តនូវកំណែទម្រង់របស់រាជរដ្ឋាភិបាល លើការគ្រប់គ្រងសំរាម សំណល់រឹង ពីដើមខ្សែរហូតដល់ចុងខ្សែ រដ្ឋបាលរាជធានីភ្នំពេញ បានខិតខំបំពេញភារកិច្ចនៃកំណែទម្រង់នេះ ដោយទទួលលទ្ធផល ចាប់ពីខែកក្កដា ដល់ធ្នូ ឆ្នាំ២០២១ ដូចខាងក្រោម៖

I. វឌ្ឍនភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

១. ការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង

ការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងតាមប្រព័ន្ធថ្មី របស់ប្រតិបត្តិករទាំង០៣ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ដោយបានប្រើប្រាស់មធ្យោបាយប្រតិបត្តិការ និងកម្លាំង រួមមាន៖

- ក្រុមហ៊ុន 800 Super GAEA (Cambodia) Co., Ltd ៖ រថយន្តប្រមូលសំរាមចំនួន ៧៤គ្រឿង រថយន្តដាំស្ទូរចំនួន ១៤គ្រឿង (ជួលបន្ថែមចំនួន ០៣គ្រឿង) រថយន្តលាងសម្អាតថ្នល់ចំនួន ០៥គ្រឿង ធុងសំរាមចំនួន ១៩១ធុង និងកម្លាំងប្រតិបត្តិការចំនួន ៦៩៨នាក់។
- ក្រុមហ៊ុន Mizuda Sanitation (Cambodia) Co., Ltd ៖ រថយន្តប្រមូលសំរាមចំនួន ១០៥គ្រឿង រថយន្តដាំស្ទូរចំនួន ០៥គ្រឿង រថយន្តបោសថ្នល់ចំនួន ០៥គ្រឿង រថយន្តលាងថ្នល់ចំនួន ០៣គ្រឿង ម៉ូតូចាប់ធុងសំរាមចំនួន ១១គ្រឿង ម៉ូតូដោះដូរធុងចំនួន ១៧គ្រឿង ម៉ូតូរ៉ឺម៉កកង់បី (អាតុយ) ចំនួន ៥៩គ្រឿង កង់បី (ធាក់ដោយជើង) ចំនួន ១៣០គ្រឿង ធុងសំរាមចំនួន ៣១.៨០០ធុង និងកម្លាំងប្រតិបត្តិការសរុបចំនួន ៧១៥នាក់ ។
- ក្រុមហ៊ុន CINTRI/Everbright ៖ រថយន្តប្រមូលសំរាមចំនួន ៨៥គ្រឿង និងត្រៀមបម្រុង ២០គ្រឿង សរុបចំនួន ១០៥គ្រឿង រថយន្តដាំស្ទូរចំនួន ០៦គ្រឿង រថយន្តលាងសម្អាតថ្នល់ចំនួន ០៤គ្រឿង រថយន្តបោសថ្នល់ចំនួន ០៤គ្រឿង រថយន្តបែនចំនួន ០៣គ្រឿង (សម្រាប់ការប្រមូលឧសកម្មវិធី) សាស៊ី (ចុកសំរាម) ចំនួន ០៤គ្រឿង ម៉ូតូរ៉ឺម៉កកង់បី (អាតុយ) ចំនួន ២០គ្រឿង រទេះរ៉ឺម៉កចំនួន ៩១គ្រឿង កង់បោសចំនួន ១២០គ្រឿង ធុងសំរាមចំនួន ៣.០០០ធុង ធុងដាំស្ទូរ ចំនួន៤០ធុង និងកម្លាំងប្រតិបត្តិការសរុបចំនួន ៩១០នាក់។



CS Scanned with CamScanner
Scanned with CamScanner

ជាមួយនឹងមធ្យោបាយប្រតិបត្តិការ និងកម្លាំងដែលប្រតិបត្តិករទាំង០៣បានរៀបចំ ធ្វើឱ្យការអនុវត្តការងារផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ក៏ដូចជាការបោសសម្អាតថ្នល់ ការលាងថ្នល់ បានត្រឹមត្រូវតាមកម្មវិធី និងពេលវេលាដែលបានកំណត់ក្នុងតំបន់នីមួយៗប្រកបដោយមានលក្ខណៈល្អប្រសើរ ដោយទទួលបានការសាទរពីប្រជាពលរដ្ឋ។ ទន្ទឹមនឹងការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ប្រតិបត្តិករទាំង០៣ បានរៀបចំសិក្ខាសាលា ស្តីពីការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក្នុងគោលបំណងផ្សព្វផ្សាយអនុក្រឹត្យលេខ ១១៣ អនក្រ.បក សេចក្តីណែនាំ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ដោយក្នុងនោះមានដូចជា៖

- ក្រុមហ៊ុន 800 Super GAEA (Cambodia) Co., Ltd បានធ្វើសិក្ខាសាលា សរុបចំនួន ៣៥លើក (ថ្នាក់ខណ្ឌ ១២លើក ថ្នាក់សង្កាត់ ១៨លើក និងសាលារៀន ៥លើក) និងមានការចែកខិតប័ណ្ណផ្សព្វផ្សាយតាមខ្នងផ្ទះ សរុបចំនួន ៣២.២៦៥ផ្ទះ និងបានដាក់ពង្រាយធុងសំរាម ចំនួន ១៩១ធុង។
- ក្រុមហ៊ុន Mizuda Sanitation (Cambodia) Co., Ltd បានធ្វើសិក្ខាសាលា សរុបចំនួន ១២លើក និងបានដាក់ពង្រាយធុងសំរាម ចំនួន ៥.០០០ធុង។
- ក្រុមហ៊ុន CINTRI/Everbright បានធ្វើសិក្ខាសាលា សរុបចំនួន ៩លើក (ថ្នាក់ខណ្ឌ ៤លើក ថ្នាក់សង្កាត់ ៥លើក) និងបានដាក់ពង្រាយធុងសំរាម ចំនួន ៦៩១ធុង។

## ២.បរិមាណសំរាម សំណល់រឹងដែលបានប្រមូល និងដឹកជញ្ជូនដោយប្រតិបត្តិករទាំង០៣

បន្ទាប់ពីអនុវត្តការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមតាមកម្មវិធីថ្មីឃើញថា បរិមាណសំរាម ដែលបានដឹកទៅចាក់នៅទីលានចាក់សំរាមដង្កោ មានការកើនឡើងជាមធ្យមប្រមាណជា ៣.០៥០តោន/១ថ្ងៃ ដែលកាលពីមុនមានប្រមាណ ២.៧០០តោន/១ថ្ងៃ ប៉ុណ្ណោះ។

| ល.រ | ខែ ឆ្នាំ | ក្រុមហ៊ុន 800Super តំបន់១ | | | ក្រុមហ៊ុន Mizuda តំបន់២ | | | ក្រុមហ៊ុន Cintri តំបន់៣ | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | គ្រឿង | ជើង | សរុប(តោន) | គ្រឿង | ជើង | សរុប(តោន) | គ្រឿង | ជើង | សរុប(តោន) | គ្រឿង | ជើង | សរុប(តោន) |
| 1 | កក្កដា ឆ្នាំ2021 | 77 | 4,980 | 29,411.19 | 61 | 3,691 | 33,040.51 | 140 | 4,729 | 27,641.54 | 278 | 13,400 | 90,093.24 |
| 2 | សីហា ឆ្នាំ2021 | 75 | 4,719 | 28,243.43 | 62 | 3,692 | 33,986.30 | 102 | 4,388 | 25,598.93 | 239 | 12,799 | 87,828.66 |
| 3 | កញ្ញា ឆ្នាំ2021 | 74 | 4,833 | 29,559.65 | 61 | 3,684 | 34,922.32 | 94 | 4,258 | 25,786.54 | 229 | 12,775 | 90,268.51 |
| 4 | តុលា ឆ្នាំ2021 | 123 | 4,606 | 28,780.94 | 62 | 3,720 | 34,327.90 | 90 | 4,125 | 25,589.03 | 275 | 12,451 | 88,697.87 |
| 5 | វិច្ឆិកា ឆ្នាំ2021 | 104 | 5,389 | 32,116.71 | 61 | 3,950 | 37,328.17 | 89 | 4,173 | 27,187.24 | 254 | 13,512 | 96,632.12 |
| 6 | ធ្នូ ឆ្នាំ2021 | 70 | 6,143 | 33,421.41 | 74 | 4,133 | 37,067.17 | 94 | 4,356 | 27,596.08 | 238 | 14,632 | 98,084.66 |
| សរុប | | | 30,678 | 181,533.33 | | 22,870 | 210,672.37 | | 26,029 | 159,399.38 | | 79,577 | 551,605.06 |

## ៣.ការងារទុកដាក់សំរាម នៅទីលានចាក់សំរាមដង្កោ

ក្រោយពីទទួលបានគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងបរិក្ខារ សម្រាប់រយៈពេល ០២ឆ្នាំ (២០២១-២០២២) ទីលានចាក់សំរាមដង្កោ បានពង្រឹងកិច្ចប្រតិបត្តិការបច្ចេកទេសក្នុងការឈូសឆាយ និងទុកដាក់សំរាម សំណល់រឹងដែលបានដឹកមកចាក់ប្រចាំថ្ងៃ ដោយបានបែងចែកក្រុមការងារជា០២វេន (វេនថ្ងៃ និងវេនយប់) គ្រឿងចក្រសរុប ១២គ្រឿង (ប៊ុលដូស័រ ៩គ្រឿង និងអិចស្កាវ៉ាទ័រ ៣គ្រឿង) ជញ្ជីងថ្លឹងសំរាម ៣កន្លែង ទីតាំងចាក់សំរាម ៤កន្លែង។ ចាប់តាំងពីត្រីមាសទី២ ឆ្នាំ២០១៩ រហូតដល់ទល់បច្ចុប្បន្ននេះ ដំណើរការប្រតិបត្តិការនៅទីលាន មានលក្ខណៈល្អប្រសើរ ដោយចរន្តនៃការចូលចាក់សំរាមមានប្រក្រតីភាពធម្មតា ដោយមិនមានកកស្ទះនោះទេ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦១៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh
Scanned with CamScanner

Scanned with CamScanner

៤. ការងារប្រមូលចំណូលថ្លៃសេវាសំរាម សំណល់រឹង

| ល.រ | បរិយាយ | ដុល្លារ | រៀល | សរុប ២០២១ |
|---|---|---|---|---|
| ១ | ខែ កក្កដា | 178,774.50 ដុល្លា | 3,364,333,145 រៀល | $ 1,019,857.79 |
| ២ | ខែ សីហា | 142,897.63 ដុល្លា | 3,566,609,006 រៀល | $ 1,034,549.88 |
| ៣ | ខែ កញ្ញា | 192,189.47 ដុល្លា | 3,550,195,280 រៀល | $ 1,079,738.29 |
| ៤ | ខែ តុលា | 126,777.77 ដុល្លា | 3,493,954,450 រៀល | $ 1,000,266.38 |
| ៥ | ខែ វិច្ឆិកា | 221,409.40 ដុល្លា | 3,736,959,345 រៀល | $ 1,155,649.24 |
| ៦ | ខែ ធ្នូ | 546,588.50 ដុល្លា | 2,822,902,012 រៀល | $ 1,252,314.00 |
| សរុប | | 1,408,637.27 ដុល្លា | 20,534,953,238 រៀល | $ 6,542,375.58 |

ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ បានដាក់អនុវត្តនូវតារាងកម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹង (ថ្មី) នៅរាជធានីភ្នំពេញ ដោយក្នុងនោះ បានធ្វើការកែតម្លៃក្នុងប្រព័ន្ធបង់ប្រាក់ស្វ័យប្រវត្តិ ដែលជាប្រភេទផ្ទះស្នាក់នៅធម្មតា សរុបចំនួន ២៦៤.៥៤១ ទីតាំង។ ទន្ទឹមនឹងនេះ ដើម្បីជំរុញ និងបង្កើនការប្រមូលចំណូលថ្លៃសេវាសំរាម សំណល់រឹង ក្រុមការងារបានចុះពិនិត្យទីតាំង និងដោះស្រាយជាមួយអតិថិជនលើការងារដូចខាងក្រោម៖

- បានចុះពិនិត្យទីតាំង សរុប ២.៦៦៣ទីតាំង
- កំណត់ឡើងវិញចំនួន ៧.៩៤៤ទីតាំង
- ចេញលិខិតទារបំណុលអតិថិជន ១.៤៨៩ទីតាំង
- បានកំពុងធ្វើការបញ្ចូលទិន្នន័យអតិថិជនថ្មី ដែលបានមកពីទិន្នន័យរបស់អគ្គីសនីកម្ពុជា (អតិថិជនតភ្ជាប់បណ្តាញថ្មី) ចំនួន ៦៩.៧៨៥ទីតាំង និងសេវាករឯកជន ចំនួន ៤២.២២៦ទីតាំង។ សម្រាប់ការបញ្ចូលទិន្នន័យទាំងអស់នេះ នឹងគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២២ ខាងមុខ។
- បានកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងថ្មី ដែលប្រព័ន្ធនឹងផ្តល់ភាពងាយស្រួល និងអត្ថប្រយោជន៍ ដូចជា ការទូទាត់ថ្លៃសេវាសំរាមបានឆាប់រហ័ស ការគ្រប់គ្រងទិន្នន័យអតិថិជន ការធ្វើស្វ័យប្រកាស ការស្នើ/ការផ្លាស់ប្តូរសេវាសំរាម ការរាយការណ៍ពីភាពយឺតយ៉ាវរបស់ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូន ការទទួលព័ត៌មាន និងការស្នើសុំផ្សេងៗពាក់ព័ន្ធនឹងសេវាសំរាម តាមរយៈប្រព័ន្ធ Software និងMobile Application។ ប្រព័ន្ធគ្រប់គ្រងថ្មីនេះក៏ជាយន្តការតាមដាន ត្រួតពិនិត្យ លើការផ្តល់សេវាសំរាមទាំងមូលរវាងរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនប្រមូលសំរាម និងប្រជាពលរដ្ឋ។

II. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើ រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន និងបានដាក់ចេញនូវដំណោះស្រាយ និងទិសដៅ ដូចខាងក្រោម៖

១. ប្រជាពលរដ្ឋមួយចំនួនតូចនៅបន្តលួចបញ្ចេញ ឬចោលសំរាម ខុសកម្មវិធី និងទីកន្លែងកំណត់។

២. សន្ទុះនៃការបង់ថ្លៃសេវាប្រមូលសំរាមរបស់អតិថិជននៅមានកម្រិតទាបនៅឡើយ បានប្រមាណជា ៣០% នៃទីតាំងទាំងអស់នៅរាជធានីភ្នំពេញ។ យើងអាចដឹងពីលេខសម្គាល់អតិថិជន (ID) ដែលខកខានបង់ ប៉ុន្តែពិបាកក្នុងការចុះរកទីតាំងនោះ គឺត្រូវចំណាយពេលយូរ ដោយមូលហេតុមិនមានព័ត៌មានគ្រប់គ្រាន់ និងព័ត៌មានដែលមានមិនបានធ្វើបច្ចុប្បន្នភាព ព្រោះទិន្នន័យទាំងអស់ គឺបានផ្អែកលើទិន្នន័យចាស់របស់អគ្គិសនីកម្ពុជា។



Scanned with CamScanner

៣. ចំពោះទីតាំងធំៗ ដែលមន្ត្រីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង ចុះស្រង់ព័ត៌មាន គឺការចូលរួមសហការនៅមានកម្រិតទាប ធ្វើឱ្យមានផលវិបាកក្នុងការកំណត់តម្លៃសេវាថ្មី។

៤. ប្រជាពលរដ្ឋចង់បានការផ្តល់សេវាល្អស្អាត ប៉ុន្តែឆន្ទៈចូលរួមបង់ថ្លៃសេវាសំរាម នៅមានកម្រិតទាប។

III. ដំណោះស្រាយ និងទិសដៅ

១. បន្តជំរុញការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង របស់ប្រតិបត្តិករទាំង០៣ ឱ្យបានស្អាតល្អតាមកម្មវិធីកំណត់។

២. បន្តជំរុញការអប់រំផ្សព្វផ្សាយសេចក្តីណែនាំនានា ក្នុងន័យធ្វើយ៉ាងណាដើម្បីបញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋ ទាំងការញែក ការវេចខ្ចប់ ការបញ្ចេញ ការទុកដាក់សំរាម ក៏ដូចជានីតិវិធីនៃការបង់ថ្លៃសេវាប្រមូលសំរាម សំណល់រឹង និងតារាងកម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹង (ថ្មី) នៅរាជធានីភ្នំពេញ។

៣. បន្តជំរុញការអប់រំផ្សព្វផ្សាយសេចក្តីណែនាំ សេចក្តីជូនដំណឹងនានា ក្នុងន័យបង្កើនការយល់ដឹងលើការគ្រប់គ្រងសំរាម សំណល់រឹងដល់ប្រជាពលរដ្ឋ។

៤. ត្រៀមអនុវត្តនូវយន្តការផាកពិន័យ ដែលបានរៀបចំរួច តាមរយៈសេចក្តីសម្រេចបង្កើតគណៈកម្មការអនុវត្ត ការពិន័យអន្តរការណ៍ថ្នាក់រាជធានី ក្រុមការងារអនុវត្តការផាកពិន័យអន្តរការណ៍ថ្នាក់ខណ្ឌ និងភ្នាក់ងារផាកពិន័យថ្នាក់សង្កាត់ ដើម្បីធានាបាននូវការចូលរួមទាំងអស់គ្នា លើប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម និងសំណល់រឹង នៅរាជធានីភ្នំពេញ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងគោរពស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  «ដើម្បីជូនជ្រាប»
- ឯកសារ - កាលប្បវត្តិ



Scanned with CamScanner

Scanned with CamScanner

ក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា)
CINTRI (CAMBODIA) LTD.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# បូកសរុបលទ្ធផលការងារឆ្នាំ ២០២១
# និង ទិសដៅការងារឆ្នាំ ២០២២

## I. សេចក្តីផ្តើម

ក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា) បានទទួលសិទ្ធិវិនិយោគលើសេវាកម្មសំអាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ពីរដ្ឋបាលរាជធានីភ្នំពេញ នៅតំបន់ ៣ (ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ) និងចាប់ផ្តើមអនុវត្តផ្តល់សេវារបស់ខ្លួន ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ។

ក្រុមហ៊ុនបានខិតខំបំពេញការងារតាមកាតព្វកិច្ចរបស់ខ្លួន នឹងគួរអោយមោទនភាពក្នុងការថែរក្សាបរិស្ថានស្អាតក្នុងរាជធានី ទោះបីមានការចោល និងបញ្ចេញសំរាម ២៤ម៉ោង ឥតឈប់ឈរក៏ដោយ ។ ជាមួយគ្នានេះដែរ ចំពោះការថែរក្សាទីក្រុងស្អាតជានិរន្ត អាស្រ័យដោយមានការចូលរួមសហការពីប្រជាពលរដ្ឋ ជាមួយការវេចខ្ចប់ទុកដាក់សំរាម អោយបានត្រឹមត្រូវ និយាយជារួមសំអាតរាជធានីគឺយើងទាំងអស់គ្នា ។ ហើយក្រុមហ៊ុនបានបែងចែកកំលាំងការងារជាពីរវេណ គឺវេណពេលយប់ និងវេណពេលថ្ងៃ។

ក្រុមហ៊ុនបានបង្កើនប្រសិទ្ធិភាព លើសេវាកម្មឱ្យកាន់តែប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ ដោយបែងចែកការងារប្រតិបត្តិការផ្សេងពីគ្នា គឺការបោសសំអាតតាមដងមហាវិថី និងវិថីនានា និងការប្រមូលសំរាមនៅតាមទីផ្សារ ផ្ទះ ភោជនីយដ្ឋាន និងតំបន់អាជីវកម្មនានា ដែលស្ថិតនៅក្នុងតំបន់ ៣ ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនបាននឹងកំពុងតែធ្វើការងារយ៉ាងហ្មត់ចត់ ដើម្បីកែលំអប្រព័ន្ធផ្តល់សេវាកម្មឱ្យកាន់តែប្រសើរ ដោយប្រើនូវធនធានឱ្យចំទិសដៅ និងតាមឯកទេសសំរាប់តម្រូវការនៃការងារជាក់លាក់ ។

## II. រចនាសម្ព័ន្ធគ្រប់គ្រង

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ក្នុងនោះមានការិយាល័យសរុបទាំងអស់ចំនួន ០៥ ការិយាល័យ រួមមានការិយាល័យរដ្ឋបាល និងធនធានមនុស្ស ការិយាល័យហិរញ្ញវត្ថុ ការិយាល័យព័ត៌មានវិទ្យា ការិយាល័យសំអាតក្រុង ការិយាល័យយានដ្ឋាន និងផ្គត់ផ្គង់ ។






អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

## III. ស្ថិតិកំលាំង និងសំភារៈប្រើប្រាស់

| ល.រ | ឧបករណ៍សំភារៈ និងកំលាំងពលកម្ម | ទិន្នន័យប្រចាំខែនិមួយ ក្នុងឆ្នាំ២០២១ | | | | | |
|---|---|---|---|---|---|---|---|
| | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| 1 | បុគ្គលិក-កម្មករ | 910 | 880 | 820 | 760 | 690 | 642 |
| 2 | រថយន្តប្រមូលសំរាម (គ្រប់ប្រភេទ&គ្រប់វេន) | 85 | 80 | 77 | 75 | 75 | 75 |
| 3 | រថយន្តបំរុងប្រមូលសំរាម (គ្រប់ប្រភេទ&គ្រប់វេន) | 20 | 25 | 25 | 25 | 25 | 25 |
| 4 | ហ្សាស៊ីរ | 4 | 4 | 4 | 4 | 4 | 4 |
| 5 | រថយន្តបោស | 4 | 4 | 4 | 4 | 4 | 4 |
| 6 | រថយន្តលាងផ្លូវ | 4 | 4 | 4 | 4 | 4 | 4 |
| 7 | រថយន្តបែន (ប្រមូលខុសកម្មវិធី) | 3 | 3 | 3 | 3 | 3 | 3 |
| 8 | រថយន្តដាំស្តូរ | 6 | 6 | 6 | 6 | 6 | 6 |
| 9 | រទេះដឹកសំរាម | 91 | 91 | 91 | 91 | 91 | 73 |
| 10 | ធុងដាំស្តូរ | 40 | 40 | 40 | 40 | 40 | 40 |
| 11 | ធុងសំរាមសម្រាប់ពង្រាយ | N/A | N/A | N/A | 1000 | 700 | 515 |
| 12 | ធុងសំរាមសម្រាប់កម្មករបោស | 150 | 150 | 30 | 30 | 30 | 30 |
| 13 | ម៉ូតូអាតុយប្រមូលសំរាម | 0 | 0 | 0 | 0 | 0 | 20 |
| 14 | កង់បោស | 0 | 0 | 120 | 120 | 120 | 120 |

### ១. រូបភាពកំលាំងបុគ្គលិក-កម្មករ



### ២. រូបភាពរថយន្តប្រមូលសំរាម

#### ក. ប្រភេទរថយន្តគាបសំរាម



ប្រភេទ ៥តោន



អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner



ប្រភេទ ៨តោន



ប្រភេទ ៨តោន

៣. រូបភាពហ្សាស័រ



៤. រូបភាពរថយន្តបោស





អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

៥. រូបភាពរថយន្តលាងផ្លូវ



៦. រូបភាពរថយន្តបែន



៧. រូបភាពរថយន្តដាំស្វ៊ែរ



៨. រូបភាពរទេះដឹកសំរាម



៩. រូបភាពធុងដាំស្វ៊ែរ



ប្រភេទ ៥តោន



ប្រភេទ ១០តោន



អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

១០. រូបភាពធុងសំរាមសម្រាប់ពង្រាយ



១១. រូបភាពម៉ូតូអាគុយប្រមូលសំរាម








អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

១២. រូបភាពកង់បោស



## IV. លទ្ធផលការងារដែលសម្រេចបាន

### ១. ទំងន់សំរាមដែលរថយន្តដឹកចូលចាក់ទីលានប្រចាំខែ

| ខណ្ឌ | ទំងន់សំរាម (តោន) ប្រចាំខែ ក្នុងឆ្នាំ២០២១ | | | | | | សរុប |
|---|---|---|---|---|---|---|---|
| | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| ចំការមន | 6,200.00 T | 5,428.00 T | 5,700.00 T | 5,735.00 T | 6,270.00 T | 6,200.00 T | 35,533.00 T |
| បឹងកេងកង | 4,340.00 T | 4,197.00 T | 4,200.00 T | 4,190.00 T | 4,440.00 T | 4,495.00 T | 25,862.00 T |
| មានជ័យ | 10,546.00 T | 10,084.00 T | 10,170.00 T | 10,084.00 T | 10,477.50 T | 10,762.89 T | 62,124.39 T |
| ច្បារអំពៅ | 6,510.00 T | 5,890.00 T | 5,716.50 T | 5,580.30 T | 6,000.00 T | 6,138.00 T | 35,834.80 T |
| ចំនួនសរុប | 27,596.00 T | 25,599.00 T | 25,786.50 T | 25,589.30 T | 27,187.50 T | 27,595.89 T | 159,354.19 T |
| មធ្យមភាគ | 919.87 T | 853.30 T | 859.55 T | 852.98 T | 906.25 T | 919.86 T | 5,311.81 T |

### ២. ការធ្វើពលកម្មផ្ទៃក្នុង (កន្លែងកខ្វក់)

| ល.រ | ខណ្ឌ | ទិន្ន័យប្រចាំខែនិមួយៗ ក្នុងឆ្នាំ២០២១ (គិតជាចំនួនដង) | | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| 1 | ចំការមន | 20 | 25 | 28 | 30 | 30 | 30 | 163 |
| 2 | បឹងកេងកង | 18 | 20 | 22 | 25 | 25 | 21 | 131 |
| 3 | មានជ័យ | 30 | 35 | 35 | 40 | 45 | 50 | 235 |
| 4 | ច្បារអំពៅ | 18 | 20 | 25 | 30 | 30 | 36 | 158 |
| សរុប | | 86 | 100 | 110 | 125 | 130 | 136 | 687 |

### ៣. ការធ្វើពលកម្ម ទទួលថ្នាក់ដឹកនាំ និងគណៈប្រតិភូ

| ល.រ | ខណ្ឌ | ទិន្ន័យប្រចាំខែនិមួយៗ ក្នុងឆ្នាំ២០២១ (គិតជាចំនួនដង) | | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| 1 | ចំការមន | 2 | 3 | 3 | 3 | 4 | 4 | 19 |
| 2 | បឹងកេងកង | 2 | 3 | 3 | 3 | 4 | 4 | 19 |
| 3 | មានជ័យ | 2 | 3 | 3 | 3 | 4 | 4 | 19 |
| 4 | ច្បារអំពៅ | 0 | 1 | 1 | 1 | 2 | 2 | 7 |
| សរុប | | 6 | 10 | 10 | 10 | 14 | 14 | 64 |



អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

## ៤. ការបំបាត់ដេប៉ូសំរាមអនាធិបតេយ្យ

| ល.រ | ខណ្ឌ | ទិន្នន័យប្រចាំខែនិមួយ ក្នុងឆ្នាំ២០២១ (ទីតាំង) | | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| 1 | ចំការមន | 1 | 1 | 0 | 0 | 0 | 0 | 2 |
| 2 | បឹងកេងកង | 1 | 0 | 0 | 0 | 0 | 0 | 1 |
| 3 | មានជ័យ | 3 | 4 | 3 | 3 | 4 | 5 | 22 |
| 4 | ច្បារអំពៅ | 3 | 3 | 4 | 1 | 1 | 1 | 13 |
| សរុប | | 8 | 8 | 7 | 4 | 5 | 6 | 38 |

ការលុបបំបាត់ដេប៉ូសំរាមអនាធិបតេយ្យ គឺជាផែនការយុទ្ធសាស្រ្តចំបងដ៏សំខាន់មួយរបស់ក្រុមហ៊ុនក្នុងគោលបំណងបំបាត់ទាំងស្រុងនូវគំនរសំរាម ឬដេប៉ូសំរាម ក្នុងតំបន់៣ ដែលក្រុមហ៊ុនបានដេញថ្លៃឈ្នះ។ ជាលទ្ធផលយើងបានលុបបំបាត់ទាំងស្រុង ហើយពុំមានដេប៉ូសំរាមអនាធិតេយ្យពុំរ៉ែមានវត្តមានក្នុងតំបន់០៣ (ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ) ទៀតឡើយ ចាប់ពីឆ្នាំ២០២១ នេះតទៅ។

## ៥. តំបន់សេវាថ្មី និងការពង្រីកសេវាបន្ថែម

ក្នុងគោលបំណងអនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយតាមកិច្ចសន្យាថ្មីរវាងក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា) និងរដ្ឋបាលរាជធានីភ្នំពេញ ក្រុមហ៊ុនបានគ្រប់ដណ្តប់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម បាន ១០០% ស្មើនឹង ២៧សង្កាត់ ក្នុងតំបន់ ០៣ (ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ ) ។ បើទោះបីជាហេដ្ឋារចនាសម្ព័ន្ធផ្នែកខ្លះនៃសង្កាត់ព្រែកថ្មី និងសង្កាត់ក្បាលកោះ នៃខណ្ឌច្បារអំពៅនៅមានបញ្ហាប្រឈមក្តី ក៏ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការផ្តល់សេវាសម្អាតប្រមូល និងដឹកជញ្ជូនសំរាម សម្រេចបាន ១០០% ។

## ៦. កំណែទម្រង់កម្មវិធីប្រមូលសំរាម

ក. ខណ្ឌកណ្តាលរាជធានី រួមមាន ខណ្ឌចំការមន និងខណ្ឌបឹងកេងកង ៖ ប្រមូលជារៀងរាល់ថ្ងៃ នៅវេនយប់ ម៉ោងបញ្ចេញ ចាប់ពីម៉ោង ១៨:០០ ដល់ ២១: ០០ និងម៉ោងប្រមូលចាប់ពីម៉ោង ២១:០០ ដល់ ០៥:០០ ភ្លឺ (គ្រប់ដណ្តប់វិសាលភាពវេនយប់ប្រមាណជា ៩៥%)។ លើកលែងការប្រមូលតាមសួនច្បារ និងតំបន់ប្លុកជៀងហែម ឬផ្លូវទាល់ ដែលត្រូវប្រមូលវេនថ្ងៃតាមកម្មវិធីដូចខាងក្រោម ៖

- ទីតាំងសួនច្បារ ៖ ប្រមូលចាប់ពីម៉ោង ០៦:០០ព្រឹកតទៅ ។
- ប្រភេទផ្លូវតូចៗ និងផ្លូវជៀងហែមដែលរថយន្តមិនអាចចូលយកបាន ៖ ម៉ោងបញ្ចេញ ១៩:០០-០៦:០០ ម៉ោងប្រមូល: ចាប់ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១៦:០០ ។

ខ. ខណ្ឌជាយរាជធានី រួមមាន ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ បានកំណែទម្រង់កម្មវិធីប្រមូលដូចខាងក្រោម ៖

- ផ្លូវជាតិ និងផ្លូវធំ ៖ ប្រមូលជារៀងរាល់ថ្ងៃ នៅវេនយប់ ម៉ោងបញ្ចេញចាប់ពីម៉ោង ១៨:០០ ដល់ ២១: ០០ និងម៉ោងប្រមូលចាប់ពីម៉ោង ២១:០០ ដល់ ០៥:០០ ភ្លឺ។
- ផ្លូវលំ ឬផ្លូវតូច ៖ ប្រមូល និងដឹកជញ្ជូនជារៀងរាល់ ០២ថ្ងៃ/ម្តង (កំណត់ថ្ងៃសេស និងថ្ងៃគូ) ម៉ោងបញ្ចេញសំរាម ចាប់ពីម៉ោង ១៩:០០ ដល់ ០៦: ០០ និងម៉ោងប្រមូលចាប់ពីម៉ោង ០៨:០០ ដល់ ១៦:០០ ភ្លឺ ។


អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

(៧) កម្មវិធីគម្រោងការលើកកំពស់ ការយល់ដឹងជាសាធារណៈ:

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតិពីរដ្ឋបាលរាជធានីភ្នំពេញលេខ 075/21 PPCH ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ក្រុមហ៊ុនបានចាប់ផ្ដើមអនុវត្តគម្រោងខាងលើចាប់ពីខែវិច្ឆិកា រហូតដល់បច្ចុប្បន្ន ដោយបានសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

| ល.រ | បរិយាយសកម្មភាព | លិទ្ធផលប្រចាំខែ (ចំនួនដង) | | | សំភារៈប្រើប្រាស់ | កំណត់សំគាល់ |
|---|---|---|---|---|---|---|
| | | វិច្ឆិកា | ធ្នូ | សរុប | | |
| ១ | រៀបចំសិក្ខាសាលាអប់រំ ក្រោមប្រធានបទ ការលើកកំពស់ការយល់ដឹងជាសាធារណៈ ស្តីពី ការគ្រប់គ្រងសំរាម និងសំណល់រឹង ។ | 02ដង | 02ដង | 04ដង | - Sticker = 200<br>- ខិតបណ្ណ = 100<br>- ថង់គំរូ = 400<br>- អាវយឺត = 200 | |
| ២ | កម្មវិធីចុះចែក Sticker កម្មវិធីប្រមូលសំរាម ខិតប័ណ្ណអប់រំ និងថង់គំរូ ។ | 02ដង | 02ដង | 04ដង | - Sticker = 800<br>- ខិតបណ្ណ = 400<br>- ថង់គំរូ = 800 | |
| ៣ | ចូលរួមក្នុងទិវាបរិស្ថានជាតិនិងបានចែកថង់គំរូជូនដល់អ្នកចូលរួម | 01ដង | | 01ដង | - ថង់គំរូ = 200 | |
| ៤ | ប្រារព្ធយុទ្ធនាការសំអាតបរិស្ថាន និងធ្វើអនាម័យលើមហាវិថីសម្តេច តេជោ ៦០ម និងផ្សព្វផ្សាយ ស្តីពីកម្មវិធីសំអាត និងប្រមូល ។ | 01ដង | | 01ដង | - Banner = 05pcs<br>- អាវយឺត = 100<br>- ថង់គំរូ = 400<br>- ពង្រៀប = 100 | |
| ៥ | បង្កើតក្រុមការងារដោះស្រាយបញ្ហារបស់អតិថិជន តាមប្រព័ន្ធបណ្តាញសង្គម ៖<br>1. Facebook Page<br>2. Telegram | | | | | |
| 6 | កម្មវិធីពង្រាយធុងសំរាម | 06ដង | 06ដង | 12ដង | ធុងសំរាម = 485 | |

(៨) សកម្មភាពការងារផ្សេងៗជាមួយអាជ្ញាធរមូលដ្ឋាន

មួយឆ្នាំកន្លងទៅនេះ ក្រុមហ៊ុនស៊ីនទ្រី បានចូលរួមអនុវត្តការងារជាច្រើនក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងថែរក្សាសោភ័ណភាព និងសំអាតរាជធានី ។ សរុបរួមយើងឃើញថា សមិទ្ធផលការងារ ទាំងនោះគឺទទួលបានជោគជ័យជាច្រើន និងខ្លះទៀតក៏ជួបឧបសគ្គផងដែរ សកម្មភាពទាំងនោះរួមមាន ៖

ក. សហការជាមួយជាមួយអាជ្ញាធរមូលដ្ឋានតាមខណ្ឌនីមួយៗ

ចុះសហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំខណ្ឌនិមួយៗដើម្បីអនុវត្តនូវភារៈកិច្ច ៖

- ផ្សព្វផ្សាយពីកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមដល់ផ្ទះប្រជាពលរដ្ឋ ។
- ផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ និងអាជីវករ សេវាករ អោយចេះញែក វេចខ្ចប់ និងទុកដាក់សំរាម អោយបានត្រឹមត្រូវតាមម៉ោងពេល និងទីកន្លែងកំណត់ ឬតាមរូបភាពឃោសនាតាម ឃោសនសព្ទ ឬចែកលិខិតប័ណ្ណ អប់រំតាមលំនៅដ្ឋាន និងនៅតាមទីតាំងមួយចំនួនដូចជា ទីផ្សារ ចំណតរថយន្ត កន្លែងកំសាន្ត សួនច្បារ និងតាមភោជនីយដ្ឋាន ។
- ចុះពិនិត្យមើលទីតាំងគំនរសំរាម ដែលប្រជាពលរដ្ឋបោះចោលខុសម៉ោងពេលកំណត់ និង គំនរសំរាមគរសល់ជាយូរមកហើយនៅតាមដងផ្លូវសាធារណៈ ។
- ទទួលខុសត្រូវថែរក្សាការពារទីតាំងដេប៉ូសំរាមដែលបានសម្អាតរួចកុំអោយកើតមានឡើងវិញ។

ខ. ការរៀបចំផែនការណ៍បុណ្យជាតិធំៗ

ចាប់តាំងពីខែកក្កដារហូតដល់ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុនបានរៀបចំផែនការ និងអនុវត្តការម្អាត ប្រមូល និងដឹកជញ្ជូនបានយ៉ាងជោគជ័យ ដោយរួមមានពិធីបុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យអុំទូក និងពិធីបុណ្យឆ្លងឆ្នាំសកល ដោយមិនមានការកកស្ទះសំរាម ឬគំនរសំរាម តាមបណ្តា


អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

មហាវិថីសំខាន់ៗ ឬផ្លូវតូចៗនោះឡើយ។ ការជោគជ័យនេះក៏អាស្រ័យលើការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរតាមមូលដ្ឋានផងដែរ ក្នុងការសហការ និងសម្រួលគ្នាទៅវិញទៅមក។

៩. ការចូលរួមការងារសង្គមនិងការងារខាងក្រៅ

ក្នុងទស្សនៈចែករំលែក និងសហការគ្នាដើម្បីរាជធានីស្អាតនៅឆ្នាំ២០២១ នេះ ក្រុមហ៊ុនស៊ីនទ្រីបានបង្កើត/ចូលរួម សកម្មភាពជាច្រើនក្នុងសង្គម ដើម្បីបើកទូលាយក្នុងការចែកចាយបទពិសោធន៍ផ្សេងៗ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសំរាម ការបង្កើតព្រឹត្តិការណ៍បញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋលើផ្នែកបរិស្ថានជាដើម ។ ដូចនេះសកម្មភាពទាំងនោះរួមមានដូចខាងក្រោម ៖

ក. ក្រុមហ៊ុនបានសហការជាមួយនិងសាលាខណ្ឌ និងមន្ទីបរិស្ថានខណ្ឌទាំង០៨ ៖ ចុះធ្វើទិវាបរិស្ថាន ដោយដាក់ កំលាំង និងគ្រឿងចក្រធ្វើការបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមតាមតំបន់កខ្វក់ខ្លាំង តំបន់មានដេប៉ូសំរាមអនាធិប្បតេយ្យ ដែលបងប្អូនប្រជាពលរដ្ឋបញ្ចេញសំរាមខុសកម្មវិធីប្រមូល ដើម្បីធ្វើការពញ្ញាក់អារម្មណ៍ ក៏ដូចជាការដាស់តឿន អប់រំទៅដល់បងប្អូនប្រជាពលរដ្ឋ ស្តីពីការទុកដាក់សំរាម និងការបញ្ចេញសំរាមអោយត្រឹមត្រូវតាមកម្មវិធី។

ខ. ក្រុមហ៊ុនបានចាត់ចែងបុគ្គលិក-កម្មករធ្វើពលកម្ម ចាំងស្មៅតាមចិញ្ចើមផ្លូវ ចូកដី ប្រមូលសំរាមតាមប្រឡាយទឹក និងបោសសម្អាតតាមច្រាំងទន្លេ (មុខកោះពេជ្រ) បន្ថែមពីលើតួនាទីភារៈកិច្ចក្នុងគោលបំណង់ចូលរួមចំណែកលើកកំពស់អនាម័យបរិស្ថាន សុខមាលភាពសាធារណៈនិងសោភ័ណភាពរាជធានីភ្នំពេញ អោយកាន់តែល្អប្រសើរថែមមួយកំរិតទៀត។

គ. ក្រុមហ៊ុនបានចូលរួមប្រជុំជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងជាមួយរដ្ឋបាលខណ្ឌទាំង០៨ ចំនួនប្រហែល ៨០លើក (ប្រជុំតាម Zoom និង ប្រជុំផ្ទាល់) ។

## V. បញ្ហាប្រឈម

ក្នុងពេលប្រតិបត្តិការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ក្រុមហ៊ុនបានជួបបញ្ហាលំបាកជាច្រើនក្នុងការគ្រប់គ្រងកាកសំណល់រឹងក្នុងរាជធានីភ្នំពេញអោយមានប្រសិទ្ធភាព បញ្ហាសំខាន់ៗទាំងអស់នោះរួមមាន ៖

១. ផ្ទះជួល បន្ទប់ជួល មិនមានទីតាំងសម្រាប់ទុកដាក់សម្រាមត្រឹមត្រូវ ។

២. អ្នកលក់ដូរចល័តលួចយកសម្រាមទៅបោះចោលតាមដីឡូត៍ទំនេរ និងដីឯកជន បង្កើតជាដេប៉ូសំរាមអនាធិបតេយ្យ។

៣. ការដ្ឋានសាងសង់មួយចំនួនធំគ្មានការវេចខ្ចប់ទុកដាក់សំភារៈ សំណល់សំណង់ អោយបានត្រឹមត្រូវ និងមិនទាន់យល់ដឹងពីការចោលសំរាមប្រភេទសំណង់នៅឡើយ។

៤. ផ្លូវធំភាគច្រើនត្រូវប្រមូលសម្រាមចេញខុសកម្មវិធី ពីរដងទៅបីដងក្នុងមួយថ្ងៃ។

៥. គ្មានទីតាំងសម្រាប់ផ្ទុកធុងដាំស្វ័រ ជាផលវិបាកក្នុងការទុកដាក់សំរាមរបស់រទេះ ដែលបានប្រមូលសំរាមបញ្ចេញខុសម៉ោង រឺខុសកម្មវិធីប្រមូល និងរទេះដែលអូសសំរាមចេញពីផ្លូវជៀងហែម។

៦. បញ្ហាអេតចាយកាយ និងការហែកស្បោងសំរាមធ្វើអោយសំរាមរាយប៉ាយខុសសភាពដើម និងគ្មានសណ្តាប់ធ្នាប់។

៧. ផ្សារមួយចំនួននៅមិនមានកន្លែងទុកដាក់សំរាម និងមិនទាន់មានធុងដាំស្វ័រសម្រាប់ផ្ទុកសំរាម (សំរាមផ្សារ) ដែលធ្វើអោយសំរាមនៅតែបន្តចោលនៅមុខផ្សារ រឺផ្លូវក្បែរផ្សារ ។

៨. បញ្ហាចតរថយន្តគ្មានសណ្តាប់ធ្នាប់សងខាងផ្លូវ ធ្វើអោយប៉ះពាល់ដល់ការបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ជាពិសេសការប្រមូលសំរាមវេនយប់ក្នុងខណ្ឌបឹងកេងកង និងខណ្ឌចំការមន។

៩. ហេដ្ឋារចនាសម្ព័ន្ធផ្លូវមួយចំនួន នៅតាមជាយក្រុងនៅមានកំរិត ដែលបង្កបញ្ហាលំបាកដល់ផ្នែកសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ( តូចចង្អៀត មានខ្សែភ្លើងរញ៉េរញ៉ៃ លិចទឹកនៅរដូវវស្សា )។

១០. ពេលយប់អ្នកបើកបរ (សំដៅដល់អ្នកចេញមកពីតាមក្លឹបផ្សេងៗ) ស្រវឹងច្រើនដែលបង្កគ្រោះថ្នាក់ដល់កម្មករ ដែលកំពុងបំរើការងារ។



អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner

១១. ធុងសំរាម និងរទេះអូសសំរាម ដែលបានដាក់នៅតាមសួនច្បារ និងទីសាធារណៈ ត្រូវបានជនខិលខូចវាយបំផ្លាញ និងលួច។

## VI. សំណូមពរ

១. សូមសំណូមពរដល់បងប្អូនប្រជាពលរដ្ឋ ជួយវេចខ្ចប់សម្រាមអោយត្រឹមត្រូវ និងរក្សាសម្រាមទុកក្នុងរបង ឬបរិវេណនៃលំដ្ឋាន អាគារ រងចាំបញ្ចេញតាមកម្មវិធីប្រមូលសម្រាម ។

២. សូមសំណូមពរអាជ្ញាធរពាក់ព័ន្ធ (ក្រសួងបរិស្ថាន មន្ទីរបរិស្ថាន ការិយាល័យគ្រប់គ្រងសំណល់រឹង រដ្ឋបាលក្រុង ខណ្ឌ សង្កាត់ ភ្នាក់ងារអនាម័យតាមសង្កាត់ ) ជួយពង្រឹងបន្ថែមលើកកម្ពស់ការអប់រំផ្សព្វផ្សាយ អោយបានទូលំទូលាយអំពីការវេចខ្ចប់សម្រាម ទុកដាក់សម្រាម ការបញ្ចេញសម្រាម និងការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ ការកែច្នៃ (មាត្រា 8, 9, 13 នៃអនុក្រឹត្យ113) ។

៣. សូមសំណូមពរដល់រដ្ឋបាលខណ្ឌ សង្កាត់ ពង្រឹងការអនុវត្តភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីណែនាំស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹង នៅរាជធានីភ្នំពេញ លេខ: ០២៥/២១ សណន.ស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១។

៤. សូមសំណូមពរដល់អាជ្ញាធរមានចំណាត់ការតាមផ្លូវច្បាប់ចំពោះជនណាដែលបានបោះសម្រាមចោល ឬដុតសម្រាម នៅតាមដងផ្លូវ ទីសាធារណៈ ដីឡូតិ៍ ដីឯកជន ទីវាល តាមប្រព័ន្ធទឹកលូ ( ដោយអនុវត្តតាមអនុក្រឹត្យ 113 ) ។

## VII. ការងារអនុវត្តសម្រាប់ឆ្នាំ២០២២

សម្រាប់ទិសដៅឆ្នាំ២០២២ ក្រុមហ៊ុនមានគម្រោងសិក្សា និងអនុវត្តការងារមួយចំនួនអោយមានភាពកាន់តែប្រសើរឡើង និងដើម្បីកាត់បន្ថយបញ្ហាដែលកើតមានចំពោះមុខ ក្នុងនោះរួមមានចំនុចដូចខាងក្រោម៖

១. បន្តពង្រាយធុងសំរាមតាមទីសាធារណៈ ដើម្បីធ្វើឲ្យការទុកដាក់សំរាមមានសណ្តាប់ធ្នាប់ល្អ។

២. បន្តអភិវឌ្ឍការអនុវត្តគម្រោងការលើកកំពស់ ការយល់ដឹងជាសាធារណៈ ឲ្យកាន់តែមានប្រសិទ្ធខ្ពស់ និងចំទិសដៅ។

៣. បន្តបំពាក់ GPS លើរថយន្តប្រមូលសំរាម និងរថយន្តបំរើការឲ្យប្រតិបត្តិការបោសសំអាត និងលាងថ្នល់អោយបានគ្រប់ចំនួន។

៤. សហការជាមួយមន្ទីរអប់រំ ដើម្បីធ្វើការអប់រំនៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស ពីផលប៉ះពាល់ដែលកើតចេញពីសំរាម ចំពោះសុខភាព បរិស្ថាន និងរបៀបទុកដាក់សំរាមតាមបច្ចេកទេស។

៥. សហការជាមួយមន្ទីរបរិស្ថាន ដើម្បីទប់ស្កាត់សំរាមអនាធិបតេយ្យ និងសំណល់រោងចក្រ។

៦. ធ្វើបច្ចុប្បន្នភាព និងទំនើបកម្មធនធាន និងសំភារៈបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់។

៧. បន្តការចុះត្រួតពិនិត្យលើភូមិសាស្ត្របោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ដើម្បីកែប្រែលក្ខណៈបច្ចេកទេសអោយសមស្របជាមួយទម្លាប់ប្រជាពលរដ្ឋនិងភូមិសាស្ត្រនៃសង្កាត់នីមួយៗ។

៨. បន្តពង្រឹង និងអនុវត្តកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

៩. បន្តសហការជាមួយស្ថាប័នខាងក្រៅ ទាំងជាតិ និងអន្តរជាតិលើបញ្ហាការគ្រប់គ្រងសំរាម និងសំណល់រឹង នៅរាជធានីភ្នំពេញ (ក្នុងតំបន់៣) ។

**ជ. ប្រធានក្រុមហ៊ុន**
**អនុប្រធានក្រុមហ៊ុន**



អគារលេខ ១០ ផ្លូវលេខ ១០៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ : (០២៣) ៨៨ ៥៨ ៥២ E-mail : info@cintri.com.kh / Website : www.cintri.com.kh

Scanned with CamScanner